01096244

E1/293.1

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-May-2015, 11:20
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៧នាទី**

**សវនាការលើកទី២៧៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

លោក ឯម ហ៊ោយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់*(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុឡាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៧:៣៦]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះផ្តើមធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និង -- ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យលោក នួន ជា អវត្តមានដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

បាទ ជាបឋមនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយខ្លួនគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥។

[០៩:០៩:៤០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអការៈវិលមុខពេលអង្គុយយូរ និងឈឺចង្កេះ និងឈឺខ្នង និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាម --ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

*(សម្រាករយៈពេលខ្លី)*

[០៩:១០:៥៧]

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងកំណត់ធ្វើសវនាការដាក់បង្ហាញនូវឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ដូចអង្គជំនុំជម្រះបានជម្រាបជូនកន្លងមកហើយតាមរយៈអ៊ីម៉ែល ដែលបានផ្ញើជូនដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥។ ដូចបានបញ្ជាក់នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះ E315/1 ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា អង្គជំនុំជម្រះបន្តអនុវត្តនីតិវិធីនៃការដាក់បង្ហាញឯកសារគន្លឹះដូចដែលធ្លាប់បានអនុវត្តនៅក្នុងសំណុំរឿង០០២/០១ដែរ ដើម្បីឲ្យភាគីនានាមានឱកាសដាក់បង្ហាញឯក-សារសំខាន់ៗទាំងឡាយដែលពាក់ព័ន្ធនឹងអង្គហេតុនៃការជំនុំជម្រះនៅក្នុងវគ្គនីមួយៗនៅក្នុងសំណុំរឿង ០០២/០២ នេះ។

សវនាការនៃការដាក់បង្ហាញឯកសារនៅក្នុងវគ្គដំបូងនេះនៃសំណុំរឿង០០២/០២ គឺពាក់ព័ន្ធទៅនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ សវនាការនេះក៏ជួយដល់សាធារណជន

ឲ្យយល់អំពីឯកសារនានាពាក់ព័ន្ធទៅនឹងវគ្គនៃសវនាការនីមួយៗបានកាន់តែល្អប្រសើរ និងទូលំទូលាយថែមទៀត។ អង្គជំនុំជម្រះបានស្នើដល់ភាគីឲ្យជ្រើសរើសយកឯកសារក្នុងចំនួនមានកម្រិត ជាពិសេសជៀសវាងជ្រើសរើសឯកសារទាំងឡាយណា ដែលត្រូវបានអង្គជំនុំជម្រះសម្រេចទទួលយក និងបានលើកយកមកបង្ហាញលម្អិតនៅក្នុងសវនាការនាពេលកន្លងមករួចហើយ។ ដើម្បីឲ្យសវនាការនៃការដាក់បង្ហាញឯកសារនេះប្រព្រឹត្តទៅបានល្អ អង្គជំនុំជម្រះបានស្នើភាគីដែលមានបំណងដាក់ឯកសារត្រូវផ្ដល់ឯកសារដែលខ្លួនមានបំណងចង់បង្ហាញមកអង្គជំនុំជម្រះ និងភាគីទាំងអស់ឲ្យបានមុនពេលចាប់ផ្ដើមសវនាការនិងយ៉ាងយូរបំផុតត្រឹមថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥។

[០៩:១៣:០៥]

បន្ថែមពីលើនេះ អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីផងដែរថា ប្រសិនបើភាគីណាមួយមិនមានបំណងកត់សម្គាល់ទៅលើឯកសាររបស់ភាគីផ្សេងទៀត ដែលបានដាក់ជូនទេនោះ ភាគីត្រូវបានស្នើឲ្យជូនដំណឹងមកអង្គជំនុំជម្រះយ៉ាងយូរត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។ អង្គជំនុំជម្រះបានផ្ញើជូនភាគីនានាកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ នូវតារាងបញ្ជីឯកសារដែលអង្គជំនុំជម្រះគ្រោងនឹងចេញសេចក្ដីសម្រេចទទួលស្គាល់នាពេលខាងមុខថា ជាប្រភេទឯកសារដែលមានពាក់ព័ន្ធទៅនឹងសំណុំរឿង ដើម្បីជាជំនួយដល់ភាគីក្នុងការជ្រើសរើសឯកសារគន្លឹះៗមួយចំនួនបន្ថែមទៀត ដែលពួកគេមានបំណងដាក់បង្ហាញក្នុងសវនាការថ្ងៃនេះ។

បញ្ជីកែសម្រួលថ្មីត្រូវបានបញ្ជូនទៅភាគីនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ភាគីនានាបានដាក់ឯកសារគន្លឹះរបស់ខ្លួនទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយអង្គជំនុំជម្រះ។ ហើយគ្មានភាគីណាមួយបានដាក់ជូនដំណឹងមកអង្គជំនុំជម្រះអំពីចេតនារបស់ខ្លួនមិនធ្វើការកត់សម្គាល់ទៅលើឯកសាររបស់ភាគីផ្សេងទៀតនោះទេ។

នៅក្នុងសវនាការនៃការដាក់បង្ហាញឯកសារគន្លឹះនេះសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលសរុបមួយថ្ងៃ ហើយដែលពេលវេលាជាក់ស្ដែងសម្រាប់ភាគីនីមួយៗអាស្រ័យទៅតាមការបែងចែករវាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ទាប់មកក្រុមមេធាវីការពារក្ដី នួន ជា និងក្រុមមេធាវីការពារក្ដី ខៀវ សំផន មានរយៈពេលកន្លះថ្ងៃសម្រាប់ក្រុមនីមួយៗ ដើម្បីបង្ហាញឯកសារគន្លឹះរបស់ខ្លួន។ ក្រោយមកបង្ហាញឯកសារ -- ក្រោយការបង្ហាញឯកសាររបស់មេធាវីទាំងពីរក្រុមរួចមក សហព្រះរាជអាជ្ញា និងសហ

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ ដើម្បីធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងឯកសាររបស់ក្រុមមេធាវីការពារក្តីទាំងពីរក្រុម ហើយចុងក្រោយបង្អស់នៃសវនាការ មេធាវីការពារក្តីទាំងពីរក្រុមមានរយៈពេលកន្លះថ្ងៃ សម្រាប់ធ្វើការឆ្លើយតបទៅជាចុងក្រោយទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមជម្រាបជូនភាគីជាថ្មីម្តងទៀតថា សវនាការបង្ហាញឯកសារគន្លឹះ ពុំមែនជាសវនាការស្តីពីភាពអាចទទួលយកបាននៃភស្តុតាងឡើយ ហេតុដូច្នេះ ភាគីពាក់ព័ន្ធមិនគប្បីពិភាក្សាពីភាពទទួលយកបាន ឬមិនអាចទទួលយកបាននៃឯកសារនៅក្នុងសវនាការនេះទេ ពីព្រោះភាគីត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់ ក៏ដូចជាការឆ្លើយតបទៅនឹងការជំទាស់ជាលាយលក្ខណ៍អក្សរ រួចហើយទៅលើឯកសារនានាដែលត្រូវបានដាក់សម្រាប់សំណុំរឿង០០២/០២នេះ សូមមើលឯកសារ E327។ ភាគីនានាគប្បីផ្តោតទៅលើការបង្ហាញឯកសារ និងខ្លឹមសារនៃឯកសារនីមួយៗដែលពាក់ព័ន្ធនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើទម្ងន់នៃភស្តុតាង នៅចុងបញ្ចប់នៃសវនាការសំណុំរឿង០០២/០២។

ជាកិច្ចបន្តទៅទៀតនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីធ្វើការបង្ហាញឯកសារគន្លឹះរបស់ខ្លួន។ សូមអញ្ជើញ!

[០៩:១៦:៣៦]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋម សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ នៅពេលនេះ ការិយាល័យសហព្រះរាជអាជ្ញានឹងធ្វើការដាក់បង្ហាញនូវឯកសារគន្លឹះដែលពាក់ព័ន្ធទៅនឹងដំណាក់កាលទី១ នៃសំណុំរឿង០០២ វគ្គទី២នេះ។ ឯកសារដំបូងដែលខ្ញុំនឹងបង្ហាញនៅពេលនេះគឺមានឯកសារខ្លះដកស្រង់ចេញពីសៀវភៅរបស់លោក ប៉ែន យៀវនិន ដែលមានចំណងជើងថា "របប ប៉ុល ពត" ដែលមាននៅក្នុងឯកសារលេខE3/1593 ដែលបានលើកឡើងអំពីស្រុកត្រាំកក់ និងតំបន់១៣នៃភូមិភាគនិរតី។ ដំបូងគឺទាក់ទងទៅនឹងសហករណ៍ដែលនិយាយអំពីការខ្វះអាហារហូបចុក និងការរើសអើងប្រឆាំងនឹងប្រជាជនថ្មី។ នៅក្នុងឯកសារនេះបានបញ្ជាក់អំពីការផ្តួចផ្តើមរបស់ឈ្មោះ មុត និងឈ្មោះ ខុម ស្តីពីការអនុវត្តហូបបាយរួមនៅស្រុកត្រាំកក់នាដើមខែឧសភាឆ្នាំ១៩៧៣ ប៉ុន្តែគម្រោងការនេះត្រូវបានបរាជ័យទៅវិញ ហើយប្រជាជនទទួលទានស្លឹកចេក ឫសឈើ

ដែលមានជាតិស្ករដូង និងចុងក្រោយរុក្ខជាតិស្មៅនានា ហើយប្រជាជនបាននាំគ្នាធ្វើការបះបោរ។

[០៩:១៩:២០]

ការរៀបរាប់នេះគឺមាននៅត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺត្រង់ 00637490 និងជាភាសាអង់គ្លេស 00678539 និងជាភាសាបារាំង 00638822។ នៅក្នុងឯកសារនេះក៏បានបង្ហាញផងដែរថានៅតំបន់១៣ ប្រជាជនមូលដ្ឋានបានទទួលរបបអាហារហូបចុកល្អប្រសើរជាង ចំណែកឯរបបអង្ករបស់ប្រជាជនថ្មី គឺអាស្រ័យទៅលើថាតើពួកគេធ្វើការលំបាកដល់កម្រិតណា។ ការរៀបរាប់នេះគឺមាននៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00637629 ដល់ 32 និងជាភាសាអង់គ្លេសគឺ 00678585 ដល់ 86 និងERNជាភាសាបារាំងគឺ 00638930 ដល់ 32។ ហើយនៅក្នុងនោះ យើងឃើញមានការលើកឡើងដូចជា ខ្ញុំលើកឧទាហរណ៍ដូចជា ការហូបរួមបានចាប់ផ្ដើមអនុវត្តក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៦ ហើយកុមារត្រូវបានយកទៅដាក់ដោយឡែកពីឪពុកម្ដាយរបស់គេ ហើយក៏ត្រូវបានចុះឈ្មោះចូលក្នុងកងចល័តដែរ។ ការរកត្រី និងដើររកចំណីផ្សេងៗ ត្រូវបានគេនិយាយថា ជាការប៉ុនប៉ងចង់រស់នៅតែឯង ហើយការដាក់កម្រិតទាំងនេះត្រូវបានពង្រឹងជាដរាបដោយកងឈ្លប។ អ្នកឈឺទទួលបានរបបអាហារពាក់កណ្ដាលតែប៉ុណ្ណោះ។ ប្រជាជនហូបតែបបររាវរៀងរាល់ថ្ងៃ ហើយកម្រិតចាំបាច់ដែលអាចរស់នៅបានគឺមានបរិមាណស្ដួចស្ដើងណាស់ ខ្លួនប្រាណហើម ដោយសារការទទួលអាហារមិនបានដិតដល់គ្រប់គ្រាន់។

[០៩:២១:០៤]

ចំណុចមួយទៀតទាក់ទងទៅនឹងឃុំលាយបូរ ដែលជាសហករណ៍គំរូ។ យើងឃើញថានៅក្នុងឃុំលាយបូរ គឺមានការបែងបែងចែកប្រជាជនជាបីប្រភេទ គឺប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងអ្នកបញ្ញើ។ នៅក្នុងឆ្នាំ១៩៧៧ កម្មាភិបាលថ្មីបានមកកាន់កាប់ភូមិលាយបូរ ហើយគេបង្កើតប្រជាជនទាំងបីប្រភេទជាសហករណ៍ដាច់ដោយឡែកពីគ្នា។ ប្រជាជនពេញសិទ្ធិ ត្រូវបានគេដាក់ក្នុងកងទី១។ ចំណែកឯប្រជាជនបញ្ញើ និងប្រជាជនត្រៀមត្រូវបានគេចាត់តាំងទៅក្នុងកងទី៦ កងទី៧ និងកងទី៨។ ហើយការរៀបរាប់នេះមានចែង -- សរសេរនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ00637635 ដល់ 39, ជាភាសាអង់គ្លេស គឺ00678587 ដល់ 88 ជាភាសាបារាំង គឺ00638934 ដល់ 38 ដែលក្នុងនោះយើងឃើញមានការលើកឡើងដូចជា៖ “នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ គឺជាឆ្នាំដែលអាក្រក់ជាងគេបំផុត ប្រជាជនធ្វើការឥតឈប់ឈរ។ ដំបូងរបបហូបចុករួមមានបាយមួយវែកម្នាក់ ប៉ុន្តែក្នុងឆ្នាំ១៩៧៧-៧៨

បបរភាវ១ និងសម្លត្រកួនបានក្លាយជាបទដ្ឋានគំរូនៃរបបអាហារសម្រាប់ប្រជាជនទូទៅ”។

នៅក្នុងឯកសារនេះ ក៏បានបញ្ជាក់ផងដែរថា “បើសិនពុំមានគ្រោះអត់ឃ្លាន នៅឆ្នាំ១៩៧៥ - ១៩៧៦ ទេ ក៏ការបរិភោគអាហារមិនបានគ្រប់គ្រាន់ បានធ្វើឲ្យមានការខូចខាតខ្លាំងដែរនៅឆ្នាំ១៩៧៧ - ៧៨ ជាពិសេសក្នុងចំណោមពួកអ្នកទីក្រុង។ ប៉ុន្តែមានប្រជាកសិករច្រើនណាស់បានស្លាប់ដោយការអត់ឃ្លានដូចគ្នា។ អ្នកទាំងឡាយណាដែលត្អូញត្អែរ សុទ្ធតែត្រូវសម្លាប់ចោល។ ឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ គឺជាឆ្នាំដែលគេកត់ត្រាឃើញការសម្លាប់រង្គាលក្នុងចំនួនមួយយ៉ាងធំ។ ចម្លើយជាសាក្សីរបស់នារីកសិករពេញសិទ្ធិពីរនាក់នៅសហករណ៍គំរូក្នុងស្រុកត្រាំកក់ បានបញ្ជាក់បន្ថែមឲ្យរឹតតែច្បាស់ថែមទៀត។ ការលើកឡើងនេះ គឺមានចែងសរសេរនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ 00638011 និងភាសាអង់គ្លេស គឺ00678719 និងជាភាសាបារាំង គឺ00639222។

[០៩:២៤:៣៨]

ចំណុចមួយទៀត ទាក់ទងទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់។ មន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៣ ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះដំបូងបង្អស់ គឺជាខ្មែរដែលត្រឡប់មកពីទីក្រុងហាណូយ ហើយនៅឆ្នាំ១៩៧៥ ប្រជាជនថ្មីជាច្រើននាក់ស្លាប់នៅទីនោះ។ ចំណុចនេះ គឺដកស្រង់ត្រង់ ទំព័រ ERN ជាភាសាខ្មែរ គឺ 00637634, ជាភាសាអង់គ្លេស គឺ 00678587, ជាភាសាបារាំងគឺ 00638933 ដល់ 34។ ការរៀបរាប់អំពីមន្ទីរក្រាំងតាចាន់នេះ គឺមានមូលដ្ឋានមកពីបទសម្ភាសន៍របស់លោក សុវណ្ណ ឈ្មោះ សុវណ្ណ ជាអតីតនិស្សិតម្នាក់នៅក្រុងភ្នំពេញដែលត្រូវបានគេជម្លៀសពីគិរីវង់ទៅត្រាំកក់ ដែលគាត់ត្រូវបានគេចោទប្រកាន់ថាជានាយទាហានរបស់របបលន់ នល់ ហើយត្រូវបានគេចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨។ ហើយការលើកឡើងចំណុចនេះក៏មាននៅសរសេរនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ 00638012 និងភាសាអង់គ្លេស 00678719 និងជាភាសាបារាំង គឺ 00639223។ ហើយខ្ញុំសូមលើកនូវចំណុចមួយចំនួនដែលមាននៅសរសេរនៅក្នុងហ្នឹងផងដែរ គឺមានដូចជា៖ “សុវណ្ណ ត្រូវបានគេធ្វើការវាយតប់ ដោយសារគាត់បដិសេធ មិនព្រមឆ្លើយសារភាព។ អ្នកដែលត្រូវគេចាប់ខ្លួនជាមួយគាត់ពីរនាក់ទៀត ដែលធ្លាប់បម្រើការក្នុងកងទ័ព លន់ នល់ ត្រូវបានគេសម្លាប់ដោយមិនបង្អង់យូរហើយ។ បន្ទាប់ពីជាប់ឃុំឃាំងមួយខែមក គាត់ត្រូវបានគេចាត់តាំងឲ្យកប់ខ្មោចពួកអ្នកទោសនៅក្បែរៗគុកនោះ ហើយគាត់បានដុតសាកសពជាង២០០ នាក់ក្នុងរយៈពេលពីរខែបន្ទាប់មកទៀត។ មានម្តងនោះ គេបាននាំមនុស្ស៦០នាក់មក ហើយគេសម្លាប់ចោលភ្លាម”។

[០៩:២៧:២៨]

ចំណុចមួយទៀតគឺឯកសារទាក់ទងទៅនឹងខ្មែរក្រោម។ លោក ប៉ែន យៀវនិន បានរៀបរាប់អំពីការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា នៅដើមឆ្នាំ១៩៧៧ ដើម្បីព្យាយាមដណ្ដើមមកវិញនូវទឹកដីកម្ពុជាក្រោម និងការចាប់ផ្ដើមធ្វើសង្គ្រាមជាមួយវៀតណាម ដើម្បីវាយប្រយុទ្ធដណ្ដើមទឹកដីមកវិញ។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ តាសាន ដែលជាកូនប្រសាររបស់ តាម៉ុក បានលើកឡើងនៅក្នុងកិច្ចប្រជុំ ឃុំចំនួនបួន គឺឃុំប៉ៀងញ៉ង ឃុំគុស ឃុំសំរោង និងឃុំត្រាំកក់ ហើយបានប្រកាសថា៖ “គោលបំណងធំបំផុតរបស់បដិវត្តន៍ គឺវាយប្រយុទ្ធដើម្បីដណ្ដើមទឹកដីកម្ពុជាក្រោមមកវិញ”។ ការលើកឡើងនេះគឺមានចែងនៅក្នុងទំព័រ ERN ជាភាសាខ្មែរគឺ 00637907 ដល់ 14, ជាភាសាអង់គ្លេសគឺ00678682 ដល់ 83, ជាភាសាបារាំងគឺ 00639140 ដល់ 42។ ក្នុងស្រុកត្រាំកក់ពួកអ្នកទទួលខុសត្រូវមូលដ្ឋានបានបញ្ចេញសម្ដីនៅចុងឆ្នាំ១៩៧៨ ថា៖ “បើសិនជាពួកវៀតណាមទាំងអស់ចាកចេញប្រជាជនខ្មែរស្ថិតនៅ – បើសិនជាប្រជាជនខ្មែរទាំងអស់ចាកចេញ ពួកវៀតណាមស្ថិតនៅ”។ យោងតាមប្រភពដែលជាកិច្ចសម្ភាសន៍ខ្មែរក្រោមដែលចាប់ខ្លួនដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងខែមីនា ឆ្នាំ១៩៧៨ និងបានបញ្ជូនទៅស្រុកត្រាំកក់។ ចំណុចនេះគឺមានសរសេរនៅក្នុងទំព័រ ERN ជាភាសាខ្មែរគឺ 00637 915, ជាភាសាអង់គ្លេសគឺ 00678685, ជាភាសាបារាំងគឺ 00639146។

[០៩:២៩:៥៦]

“ប្រជាជនខ្មែរ និងវៀតណាមបានរួមរស់ និងជួញដូរជាមួយគ្នាដោយសុខដុមរមនានៅទឹកដីវៀតណាមក្នុងឆ្នាំ១៩៧៥។ តាម៉ុក ចង់បានខ្មែរក្រោមក្នុងចំនួនមួយយ៉ាងច្រើនឲ្យវិលត្រឡប់មកកម្ពុជាប្រជាធិបតេយ្យវិញ ដើម្បីមានកម្លាំងគ្រប់គ្រាន់វាយប្រយុទ្ធទល់នឹងប្រទេសវៀតណាមវិញ”។ ចំណុចនេះ ក៏មានចែងនៅក្នុងទំព័រ ERN ជាភាសាខ្មែរ គឺ00637995 ដល់ 98, ជាភាសាអង់គ្លេស គឺ 00678 714 ដល់15, ជាភាសាបារាំងគឺ 00639211 ដល់ 14។ “កងទ័ពនៅភូមិភាគនិរតីបានឆ្មក់ចូលភូមិនានារបស់វៀតណាម នៅដើមឆ្នាំ១៩៧៨ ហើយចាប់ពង្រត់ខ្មែរកម្ពុជាក្រោមរាប់ពាន់នាក់នាំយកមកកម្ពុជាប្រជាធិបតេយ្យ។ លោក យៀវនិន បានសរសេរថា “ប្រជាជនខ្មែរផ្នែកខាងលើ ឧទាហរណ៍ ប្រជាជនខ្មែរដែលរត់ចេញពីតាកែវ ទៅរស់នៅប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៤ ត្រូវបានពិនិត្យ និងបញ្ជូនទៅរស់នៅស្រុកត្រាំកក់ ក្នុងអំឡុងពេលដែលខ្មែរក្រោមត្រូវបានទុកឲ្យរស់នៅក្នុងស្រុកគិរីវង់។

[០៩:៣១:៣៣]

ឯកសារបន្តទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមនិងខ្មែរក្រោម។ ឥឡូវ ខ្ញុំនឹងបង្ហាញឯកសារមួយចំនួនទាក់ទងទៅនឹងស្រុកត្រាំកក់ និងក្រាំងតាចាន់ ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមនិងខ្មែរក្រោម។ ដំបូង គឺមានឯកសារមួយចំនួនដែលមានយោងអំពីការនិរទេសជនជាតិវៀតណាមពីត្រាំកក់។ គឺឯកសារដែលជាសៀវភៅកំណត់ហេតុដែលមានលេខ E3/2107 ត្រង់ទំព័រERN ជាភាសាខ្មែរគឺ 00068048, ជាភាសាអង់គ្លេសគឺ 00290204, ជាភាសាបារាំងគឺ 00655724 ដល់25។ ឯកសារនេះ មានរៀបរាប់អំពីការកត់ត្រាទាក់ទងទៅនឹងអ្នកទោស ឈ្មោះ ឌុច សំហឿន ថានៅចុងឆ្នាំ១៩៧៥ នៅពេលដែលអង្គការឲ្យយួនវិលត្រឡប់ទៅប្រទេសវិញ គាត់ស្នើសុំទៅវៀតណាមដែរ ដោយហេតុថា ប្រពន្ធរបស់គាត់ជាជនជាតិយួន ហើយគាត់ឮគេនិយាយថា នៅប្រទេសវៀតណាមគេអាចធ្វើការងារជាឯកជន និងអាចប្រើប្រាស់លុយបាន ប៉ុន្តែអង្គការមិនអនុញ្ញាតឲ្យគាត់ទៅទេ។

[០៩:៣៣:១២]

កំណត់ហេតុមួយទៀតគឺកំណត់ហេតុនៅក្រាំងតាចាន់ លេខ D157.7 ត្រង់ទំព័រERN ជាភាសាខ្មែរគឺ 00270859, ជាភាសាអង់គ្លេសគឺ 00866430, ជាភាសាបារាំងគឺ 00872804។ នៅក្នុងកំណត់ត្រារបស់អ្នកទោសឈ្មោះ អ៊ឹង ទ្រី មានរៀបរាប់អំពីការនិរទេសជនជាតិវៀតណាមពីត្រាំកក់ថា ក្នុងខែមករា ឆ្នាំ១៩៧៦ អង្គការបានប្រមូលជនជាតិយួន ហើយបញ្ជូនត្រឡប់ទៅវៀតណាមវិញ។ យួនបានមកទទួលក្រុមគ្រួសារវៀតណាមទាំងនោះ នៅភ្នំដិន ប៉ុន្តែគេទទួលយកតែអ្នកទាំងឡាយដែលជាជនជាតិយួនសុទ្ធតែប៉ុណ្ណោះ។ ពួកគេមិនទទួលអ្នកដែលកូនកាត់ចិនយួនទេ។ នៅពេលនោះ មានក្រុមគ្រួសារចិនយួនចំនួនបួនគ្រួសារត្រូវបានវៀតណាមមិនព្រមទទួលយកនៅពេលនោះទេ។ ដូច្នេះ អង្គការបញ្ជូនពួកគេទៅស្រុកគិរីវង់វិញ។

[០៩:៣៤:៣៨]

ឯកសារបន្ទាប់ គឺឯកសារដែលមានលេខ E3/2435 គឺលិខិតចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧ ផ្ញើពីឃុំអង្គតាសោមជូនទៅមន្ទីរស្រុក ដែលស្នើសុំការណែនាំអំពីការចុះឈ្មោះប្រជាជនកម្ពុជាក្រោមជាពិសេស ឃុំស្នើសុំការណែនាំពីការប្រព្រឹត្តយ៉ាងណាទៅលើក្រុមគ្រួសាររបស់ខ្មែរវៀតណាម និងខ្មែរក្រោម។ លិខិតនោះក៏បានលើកឡើងថា ក្រុមគ្រួសារណាដែលមានតែវៀតណាមសុទ្ធត្រូវបញ្ជូនទៅអង្គការ។ ការកត់ត្រាអំពីត្រាំកក់រួមមានឧទាហរណ៍ចំនួនប្រាំមួយ ដែលមកពីឃុំផ្សេងៗគ្នាស្ដីពីការរៀបចំចុះឈ្មោះកំណត់អត្តសញ្ញាណគ្រួសារកម្ពុជាក្រោមដែលរស់នៅក្នុងឃុំនីមួយៗ ហើយនិងប្រជាជន

ទាំងនោះដែលមានអតីតភាពជាទាហានលន់ នល់ ផងដែរ។

ឯកសារដំបូងមានលេខ E3/2049 និង E3/4082 ជាឯកសាររួមគ្នា គឺចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ដែលរៀបរាប់អំពីអត្តសញ្ញាណកម្ពុជាក្រោមចំនួន២៦គ្រួសារ ដែលបានស្នាក់នៅឃុំអង្គតាសោម។ ផ្នែកទី១ នៅបញ្ជីឈ្មោះនេះមានពីលេខរៀងទី១ដល់លេខរៀងទី៨ ដែលមាននៅក្នុងឯកសារលេខ E3/2049 ហើយផ្នែកទី២ នៃបញ្ជីឈ្មោះនេះគឺមានលេខរៀងពីទី៩ ដល់ទី២៦ ដែលមាននៅក្នុងឯកសារលេខE3/4082។ បញ្ជីឈ្មោះនេះចុះកាលបរិច្ឆេទថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ពោលគឺបួនថ្ងៃបន្ទាប់ពីលិខិតមកពីអង្គតាសោមដែលស្នើសុំការណែនាំពីស្រុកអំពីការរៀបចំបញ្ជីទាំងនេះ ដែលខ្ញុំបាទទើបតែលើកឡើងមុននេះបន្តិចនេះ ហើយខ្ញុំសូមធ្វើការកត់សម្គាល់ផងដែរថា នៅក្នុងកូឡោនផ្សេងៗនៅក្នុងឯកសារហ្នឹងគឺ បើយើងមើលត្រង់លេខរៀងទី៤ គឺបានកត់ត្រាថា “ប្ដីស័ក្តិ៣ យើងកម្ទេចរួចហើយតាំងពីចេញមកដល់”។ ឯកសារមួយទៀតមានលេខ E3/2281 គឺជារបាយការណ៍ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ ដែលមានចំណងជើងថា “បញ្ជីប្រជាជនកម្ពុជាក្រោមឃុំត្រពាំងធំជើង” ដែលបានកំណត់អត្តសញ្ញាណខ្មែរក្រោមចំនួន៧៣គ្រួសារ ដែលរស់នៅក្នុងឃុំនេះរួមទាំងបញ្ជាក់អំពីអតីតភាពការងារ និងឋានន្តរសក្តិអ្នកដែលជាអតីតទាហានផងដែរ។

[០៩:៣៨:០៧]

ឯកសារបន្តទៀតគឺលេខ E3/4083 ត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00068083 និងជាភាសាខ្មែរមួយទៀតគឺ 00068035 ហើយជាភាសាអង់គ្លេសគឺ 00323966 ដល់ 72, ជាភាសាបារាំងគឺ 00778870 ដល់ 74។ គឺជាបញ្ជីឈ្មោះមកពីឃុំស្រែរនោងដែលចុះកាលបរិច្ឆេទថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ ដែលបានកំណត់អត្តសញ្ញាណខ្មែរក្រោមចំនួន៣៧គ្រួសារ ឬអតីតទាហាន ឬក៏មន្ត្រីរដ្ឋការរបបលន់ នល់ ដែលបានបញ្ជាក់អំពីឋានន្តរសក្តិ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ សហព្រះរាជរងជាតិផ្អាកតិចសិន។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ខ្ញុំមិនប្រាកដថា តើខ្ញុំគួរតែលើកឡើងឥឡូវនេះ ឬក៏ទុកទៅដល់ថ្ងៃពុធទេទាក់ទងទៅនឹងបទបង្ហាញមួយនេះ។ តែឥឡូវនេះ ខ្ញុំចង់ឲ្យមានការណែនាំពីអង្គជំនុំជម្រះ ព្រោះថាកន្លងមកគឺតាំងពីព្រឹកមកគឺថា និយាយតែទៅលើកម្ពុជា

ក្រោមប៉ុណ្ណោះ បទបង្ហាញទាំងអស់នេះ។ ហើយអង្គជំនុំជម្រះមិនទាន់បានសម្រេចទាក់ទងទៅនឹងសំណើរបស់យើងខ្ញុំអំពីភាពច្បាស់លាស់ទាំងអស់នេះឡើយ។

ហេតុដូច្នេះហើយទើបខ្ញុំមិនដឹងថា ហេតុអ្វីខាងព្រះរាជអាជ្ញាចំណាយពេលច្រើនទៅលើបញ្ហាមួយនេះ។ យ៉ាងណាក៏ដោយ យើងខ្ញុំមេធាវីការពារក្តីនៅតែរក្សាគោលជំហរដដែលរបស់យើងខ្ញុំ ដែលថានេះគឺជាផ្នែកនៃសវនាការបន្ទាប់ មិនមែនជាផ្នែកនៃសវនាការនេះទេ។ ដូច្នេះហើយប្រសិនបើអង្គជំនុំជម្រះសម្រេចថាទុកការជំទាស់របស់ខ្ញុំទៅថ្ងៃពុធ គឺខ្ញុំនឹងទុកលើកនៅថ្ងៃពុធ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថាអង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចមួយទាក់ទងទៅនឹងអ្វីដែលខ្ញុំបានលើកឡើង។ ខ្ញុំមានមតិពីរបី -- ហេតុផលពីរបី សម្រាប់ការជំទាស់ ប៉ុន្តែយ៉ាងណា ខ្ញុំទុកឲ្យអង្គជំនុំជម្រះសម្រេចសិន។

[០៩:៤០:៤៦]

**លោក ឌេល លីសាក់៖**

លោកប្រធាន តើខ្ញុំអាចអនុញ្ញាតឆ្លើយតបបានទេ? ការជំទាស់នេះគឺមិនមានមូលដ្ឋាននោះឡើយ។ បញ្ហាធំដែលលោក កូប៉េ បានលើកឡើង គឺអំពីបទចោទទាក់ទងទៅនឹងការរើសអើងប្រឆាំងខ្មែរក្រោម ហើយការចោទប្រកាន់គឺធ្វើឡើងអំពីត្រាំកក់ និងក្រាំងតាចាន់ ដែលនៅក្នុងនោះរួមបញ្ចូលទាំងខ្មែរក្រោមដែលមានទាំងអ្នកទោសត្រូវបានគេបញ្ជូនទៅត្រាំកក់។ ដូច្នេះ ទោះបីជាហេតុផលអ្វីក៏ដោយបញ្ហានេះជាផ្នែកនៃសំណុំរឿងមួយនេះ។ យើងមិនមានអ្វីមន្ទិលសង្ស័យនោះឡើយ ទាក់ទងទៅនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

[០៩:៤១:៤៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:១២]

**ប្រធានអង្គជំនុំ៖**

បាទប្រគល់ភារៈជូនទៅលោកស្រី ក្លូឌា ហ្វៃនស៍ ដើម្បីឆ្លើយបញ្ជាក់ជូនទៅមេធាវីការពារក្តីលោក នួន ជា។ បាទ សូមអញ្ជើញលោកស្រីចៅក្រមហ្វៃនស៍!

**ចៅក្រម ក្លូឌា ហ្វៃនស៍៖**

បញ្ហាពីរគឺទាក់ទងទៅនឹងការរៀបចំថាតើមេធាវីការពារក្តីអាចលើកនៅថ្ងៃនេះ ឬក៏លើកនៅថ្ងៃពុធ យើងសូមនិយាយថាប្រសិនបើអាចរង់ចាំបានគឺចាំដល់ថ្ងៃពុធដើម្បីធ្វើការបង្ហាញជាទូទៅ។ បញ្ហា

ទី២ ទាក់ទងទៅនឹងសេចក្ដីសម្រេច យើងនឹងចេញនៅក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន ហើយវាជាអាទិភាពទី១របស់យើង។ ហើយការសម្រេចរបស់យើងគឺទាក់ទងទៅនឹងបញ្ហាខ្មែរក្រោមដូចដែលយើងនិយាយរួចមកហើយ គឺដោយសារតែមិនមានការសម្រេចផ្ទុយពីនេះ យើងនឹងយោងទៅលើអ្វីៗដែលព្រះរាជអាជ្ញាបានលើកឡើង គឺថាខ្មែរក្រោមគឺជាអ្នកទោសមួយដែរ។ ដូច្នេះខ្មែរក្រោមគឺមានភាពពាក់ព័ន្ធ។ ហើយចំណុចទី៣ ដូចដែលយើងបានបញ្ជាក់នៅក្នុងអ៊ីម៉ែល គឺថាយើងផ្ដល់ យើងទុកសិទ្ធិឲ្យភាគីដើម្បីធ្វើការសម្រេចនៅក្នុងពេលវេលាដែលពួកគេបានទទួល។ ដូច្នេះ ខ្ញុំគិតថាខ្ញុំបានឆ្លើយទៅនឹងអ្វីដែលលោកបានលើកឡើងរួចរាល់ទៅហើយ។ សូមអរគុណ។

[០៩:៤៤:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងជាតិ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបន្តឡើងវិញ ខ្ញុំបន្តត្រង់ឯកសារលេខ E3/4083 ដែលមាននៅត្រង់ទំព័ ERN ជាភាសាខ្មែរ គឺ00068033 និង 35, ជាភាសាអង់គ្លេស គឺ00323966 ដល់ 72, ជាភាសាបារាំង គឺ00778870 ដល់ 74 គឺជាបញ្ជីឈ្មោះមកពីឃុំស្រែរនោង ដែលចុះកាលបរិច្ឆេទថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ ដែលបានកំណត់អត្តសញ្ញាណខ្មែរក្រោមចំនួន៣៧គ្រួសារ ឬអតីតទាហាន ឬក៏មន្ត្រីរដ្ឋការនៃរបបលន់នល់ ដែលបញ្ជាក់អំពីឋានន្តរសក្តិ និងអ្នកដែលមកពីភ្នំពេញផងដែរ។ ហើយឯកសារមួយទៀត គឺឯកសារលេខ E3/2438 គឺជារបាយការណ៍ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ ដែលមានចំណងជើងថា "បញ្ជីប្រជាជនកម្ពុជាក្រោមពីឃុំគុស" ដែលបានកំណត់អត្តសញ្ញាណខ្មែរក្រោមចំនួន៣៥គ្រួសារ ដែលស្នាក់នៅឃុំគុស និងមានបញ្ជាក់អំពីឋានន្តរសក្តិអ្នកដែលជាអតីតទាហានរបបសាធារណរដ្ឋ និងបញ្ជាក់អំពីប្រជាជនជម្លៀស១៧មេសា ផងដែរ។

[០៩:៤៧:០៣]

ឯកសារមួយទៀត គឺលេខ E3/2262 គឺជាផ្នែកឯកសារមួយដែលថតចម្លងពីបញ្ជីឈ្មោះដែលបានកំណត់អត្តសញ្ញាណខ្មែរក្រោមចំនួន៦៤គ្រួសារ ដែលស្នាក់នៅឃុំពពេល រួមទាំងបញ្ជាក់អំពីអតីតភាពការងារ និងទីកន្លែងដែលពួកគេត្រូវបានជម្លៀសផងដែរ។

អង្គជំនុំជម្រះធ្លាប់បានជ្រាបរួចហើយ អំពីរបាយការណ៍ចុះថ្ងៃទី -- ចុះខែឧសភា ឆ្នាំ១៩៧៧

ដែលផ្ញើពីឃុំពពេលដែលសំដៅទៅលើខ្មែរក្រោមចំនួន៦៤គ្រួសារ ដែលមានមនុស្សសរុបចំនួន២២៨នាក់ ដែលធ្លាប់បានទទួលមកដោយសារការដោះដូរជាមួយវៀតណាម គឺនៅក្នុងឯកសារលេខ E3/2080 ត្រង់ទំព័រERN ជាភាសាខ្មែរ គឺ00079090, ជាភាសាអង់គ្លេស គឺ00276563 ដល់ 64 និងជាភាសាបារាំង គឺ00611660។ ខ្ញុំកត់សម្គាល់ឃើញដែលថា ឯកសារនេះគឺបានបង្ហាញអំពីបញ្ជីឈ្មោះថាតើក្រុមគ្រួសារចំនួន៦៤នោះ នៅក្នុងឃុំពពេលនេះបានមកពីណា។ ហើយឧទាហរណ៍ចុងក្រោយនៃការរៀបចំបញ្ជីឈ្មោះដោយឃុំនានានៃស្រុកត្រាំកក់នេះ គឺបានកំណត់អត្តសញ្ញាណខ្មែរក្រោម មាននៅក្នុងឯកសារលេខ E3/2428 ដែលជាបញ្ជីឈ្មោះខ្មែរក្រោមចំនួន៥៤គ្រួសារ ដែលរស់នៅក្នុងឃុំសំរោង ហើយនិងរៀបរាប់អំពីឋានន្តរសក្តិអ្នកដែលជាអតីតទាហាននៃរបបសាធារណរដ្ឋផងដែរ។ ឯកសារបានបង្ហាញអំពីថាមានអ្វីកើតឡើងចំនួនប្រជាជនកម្ពុជាក្រោមនៅឃុំសំរោង។ បន្ទាប់ពីបញ្ជីឈ្មោះនេះត្រូវបានរៀបចំរួចនៅក្នុងឯកសារលេខ E3/4084 ត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺ00079083, ជាភាសាអង់គ្លេស គឺ00290264 និងជាភាសាបារាំង គឺ00795281។ ឯកសារនេះចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧។ ដូច្នេះ ឯកសារនេះមានរយៈពេលប្រហែលជាមួយ ឬក៏ពីរអាទិត្យ បន្ទាប់ពីពេលវេលាដែលបញ្ជីឈ្មោះក្រុមគ្រួសារខ្មែរក្រោមត្រូវបានរៀបចំរួចរាល់ដោយឃុំនីមួយៗ។

[០៩:៥០:១៥]

បញ្ជីឈ្មោះរាយការណ៍ទៅអង្គការអំពីប្រជាជនថ្មី មានឈ្មោះ ប៊ុត វីន ដែលធ្លាប់បានប្រាប់ស្ត្រីខ្មែរក្រោមម្នាក់ រស់នៅឃុំតាភេមថា៖ “រាល់ខ្មែរកម្ពុជាក្រោម ត្រូវបានអង្គការយកទៅអស់ហើយ នៅឃុំសំរោងគ្មានសល់មួយទេ។ នៅតែឃុំតាភេម មិនទាន់យក ថ្ងៃក្រោយអង្គការគង់តែយកទេ”។

ហើយឯកសារបន្តមកទៀតនេះ គឺជាឯកសារដែលទាក់ទងនឹងរបាយការណ៍របស់លោក ហង់រី ឡូកា ដែលរៀបរាប់អំពី “ស្រុកត្រាំកក់ស្ថិតក្នុងកណ្តាប់ដៃខ្មែរក្រហម”។ របាយការណ៍នេះគឺមាននៅក្នុងឯកសារលេខ D313/1.2.16។ បើយើងពិនិត្យទៅលើសេចក្តីផ្តើមរបស់គាត់ ជាពិសេសគឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00739029 និងជាភាសាអង់គ្លេសគឺ 00227590 និងជាភាសាបារាំង គឺ 00743 751។ លោក ហង់រី ឡូកា បានសរសេរថាស្រុកត្រាំកក់មានកន្លែងពិឃាដមួយឈ្មោះ “ក្រាំងតាចាន់” អាចចាត់ទុកថាជាគំរូដែលឆ្លុះបញ្ចាំងពីសង្គមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ពិតណាស់ ស្រុកនេះត្រូវបានវិទ្យុខ្មែរក្រហមផ្សព្វផ្សាយថាជាស្រុកគំរូ ដោយជំរុញឱ្យអ្នកស្តាប់យកគំរូតាមសមិទ្ធផល ធ្វើស្រែមហាអស្ចារ្យរបស់ស្រុកត្រាំកក់ និងស្នារតីបដិវត្តន៍មោះមុតរបស់អ្នកស្រុកនេះ។ តាមពិតវាលស្រែដែល

តែងតែមានរាងក្រឡាចក្រត្រង្គនៅស្រុកត្រាំកក់ ហើយក៏អាចឃើញមានរហូតដល់សព្វថ្ងៃនេះគឺជានិមិត្តរូបមួយនៃចក្រវាឡផ្តាច់ការ ដែលតួយ៉ាងដូចជា ខៀវ សំផន ធ្លាប់ស្រមៃចង់បាន។

[០៩:៥៣:០៩]

ហើយនៅក្នុងផ្នែកទី២(ខ) នៃរបាយការណ៍របស់គាត់នេះ ដែលមានចំណងជើងថា "បណ្ណសារអំពីមន្ទីរក្រាំងតាចាន់" កំណត់ហេតុជីវប្រវត្តិ អត្តសញ្ញាណ និងស្ថិតិអំពីអ្នកទោស៤៧៧នាក់ គឺមានសរសេរនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00739047 ដល់ 46, ជាភាសាអង់គ្លេសគឺ 00217700 ដល់ 01, ជាភាសាបារាំង គឺ 00743759 ដល់ 60។ លោក ហង់រី ឡូកា បានសង្ខេបថា សៀវភៅកត់ត្រាអំពីការសួរចម្លើយនៅក្រាំងតាចាន់ដែលគាត់កត់ត្រា គឺមិនទាន់ចប់សព្វជ្រុងជ្រោយនៅឡើយ ដោយសារពេលវេលា។ លោក ហង់រី ឡូកា បានផ្តល់ការវិភាគក្នុងរបាយការណ៍នេះទាក់ទងទៅនឹងអ្នកទោសចំនួន៤៧៧នាក់ ដែលត្រូវកំណត់អត្តសញ្ញាណនៅក្នុងសៀវភៅកត់ត្រានេះដែលមានដូចតទៅ៖ "អាចគិតទុកបានថា ដោយសារតាកែវមានព្រំប្រទល់ជាប់វៀតណាមទើបមនុស្សច្រើន រហូតដល់១០០នាក់ បានព្យាយាមរត់ទៅប្រទេសនេះ។ ចំណែកឯ១១នាក់ សង្ឃឹមថាប្រទេសជិតខាងនេះនឹងឈ្លានពានកម្ពុជាក្នុងរយៈពេលឆាប់ៗ ដើម្បីសង្គ្រោះពួកគេពីកណ្តាប់ដៃអង្គការ។ អ្នកទោស២៨នាក់ ត្រូវបានចាប់ខ្លួន ព្រោះពួកគេបានព្យាយាមបានរត់គេចទៅថៃ ចំណែកឯ១៣នាក់ បានរត់គេចខ្លួនចូលព្រៃភ្នំដំរីរមៀលនៅជិតតំបន់នោះ។ អ្នកខ្លះមកពីតំបន់ឆ្ងាយត្រូវបានចាប់ខ្លួននៅស្រុកត្រាំកក់ នៅពេលធ្វើដំណើរតាមបណ្តោយផ្លូវលេខ៣ ឆ្ពោះទៅវៀតណាម។ នេះមានន័យថា អ្នករត់គេចសរុបចំនួន១៥២នាក់ ដែលត្រូវទាហានខ្មែរក្រហមចាប់ខ្លួនបាន។

[០៩:៥៥:៤៧]

លោក ហង់រី ឡូកា ក៏បានសរសេរទៀតដែរថា "ជនរងគ្រោះមួយក្រុមធំផ្សេងទៀត គឺជនជាតិរងគ្រោះដោយសារមានកំហឹងខឹងអង្គការ ដែលពួកគេទាំងនេះ ជួនកាលអាចជាមនុស្សតែមួយ ជាអតីតនគរបាល ឬទាហានសាធារណរដ្ឋ និងសមាជិកគ្រួសាររបស់ពួកគេ។ ក្នុងចំណោមអ្នកជាប់ឃុំឃាំងទាំងនេះ ដែលមានចំនួន៤៧៧នាក់ គេអាចកំណត់ថាមានអតីតទាហាន ២២៥នាក់ ប្រពន្ធ១៥នាក់ ក្នុងនោះម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថា មានដើមកំណើតជាជនជាតិវៀតណាម និង៦នាក់ជាកុមារ។ ប្រសិនបើគេបូកបញ្ចូលអតីតនគរបាល ឬតម្រួតឃោធា២៧នាក់ទៀត នោះនឹងមានជនរងគ្រោះចំនួន២៧៣នាក់ ជាប់ពាក់ព័ន្ធនឹងកងកម្លាំងសណ្តាប់ធ្នាប់របស់របបមុន។ បន្ទាប់ពីនាយទាហានទាំងរបស់

កងទ័ពលន់នល់ ភាគច្រើនបូករួមទាំងសមាជិកគ្រួសារដែលអាចត្រូវបានតាមដានរកឃើញរួចមក ឥឡូវនេះ គឺដល់វេនទាហាននៅសមរភូមិមុខ និងទាហានគ្រប់ថាននូវសក្តិទាំងអស់។ ទោះយ៉ាងអង្គការក៏បានចាប់ខ្លួនកម្មករ ឬកសិករ ចំនួនប្រហែល១៩នាក់ ដែលទស្សនៈម៉ារីយនិយម ដែលភាសាខ្មែរហៅថាពួកវណ្ណៈអធន និងទាហានខ្មែរក្រហម២៣នាក់ ឬឆ្មាំគុក និងពេទ្យខ្មែរក្រហម៤នាក់។ ដូច្នេះ សរុបមានខ្មែរ៤៦នាក់ ដែលត្រូវបានសន្មតថា ជាអ្នកគាំទ្រ និងជាអ្នកទទួលពីរបបខ្មែរក្រហម ឬក៏ជាដៃជើងផ្ទាល់របបនេះ”។

[០៩:៥៨:០៣]

ម្យ៉ាងវិញទៀត ស្ថិតិទាំងនេះបង្ហាញថា របបនេះពិតជាបំផ្លាញប្រជាជនឯង មិនត្រឹមតែនៅគុកទួលស្លែងទេ ប៉ុន្តែនៅទូទាំងប្រទេសតែម្តង។ លោក ហង់រី ឡូកា ក៏បានសរសេរបញ្ជាក់បន្ថែមដែរថា “២២នាក់ គ្រាន់តែគេកំណត់អត្តសញ្ញាណថា ជាអតីតសិស្ស និស្សិតសម័យ លន់ នល់ ហើយជាទូទៅអ្នកទាំងនោះនៅក្មេង ព្រោះថា១២នាក់ ក្នុងចំណោមអ្នកដែលគេសួរចម្លើយ មានអាយុក្រោម១៨ឆ្នាំ ហើយក្មេងបំផុត គឺអាយុ១១ឆ្នាំ”។ នេះមានន័យថា អ្នកជាប់ឃុំឃាំងសរុបទាំងអស់៤៣០នាក់ ត្រូវបានបង្ហាញពីមុខរបរក្នុងចំណោមអ្នកជាប់ឃុំឃាំង៤៧៧នាក់ នៅក្នុងបញ្ជីដែលយើងមាន។ ៣៨១នាក់ គឺជាប្រជាជនថ្មី និង៤៦នាក់ គឺជាប្រជាជនចាស់។ ក្នុងចំណោមនោះ ២៣នាក់ គឺជាទាហានខ្មែរក្រោម -- ខ្មែរក្រហម (សូមទោស) ២៣នាក់គឺជាទាហានខ្មែរក្រហម និង២៣នាក់ទៀត ជាកម្មករ កសិករ ឬគិលានុបដ្ឋាកយិកា ហើយខ្ញុំ ការបង្ហាញឯកសាររបស់ខ្ញុំនៅពេលនេះ គឺចប់ត្រឹមនេះ ហើយសហការីរបស់ខ្ញុំ នឹងបន្តការបង្ហាញនេះបន្តទៀត បាទ។ សូមអរគុណ។

[០៩:៥៩:៥៤]

**លោក ឌេល លីសាក់៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ប្រធានបទទី១ ដែលខ្ញុំនឹងពិភាក្សានៅថ្ងៃនេះគឺឯកសារពាក់ព័ន្ធទៅនឹងការបោសសម្អាតទាហាន និងមន្ត្រីរដ្ឋការលន់នល់ នៅក្នុងស្រុកត្រាំកក់។ ខ្ញុំសូមចាប់ផ្តើមដោយធ្វើការដកស្រង់នូវសៀវភៅរបស់ អ៊ា ម៉េងទ្រី ដែលមានចំណងជើងថា “ខ្សែរយៈនៃការភ័យខ្លាច”។ ប្រព័ន្ធសន្តិសុខភូមិភាគនិរតី ឯកសារមានលេខ E3/2120។ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយថាឯកសារនេះកំពុងធ្វើការបកប្រែ ដូច្នេះខ្ញុំធ្វើការដកស្រង់តែត្រង់ទំព័រភាសាអង់គ្លេស។ នៅត្រង់ភាសាអង់គ្លេសមានលេខ 00416322។ អ៊ា ម៉េងទ្រី ចាប់ផ្តើមដោយរៀបរាប់អំពីក្រុមដែលគេ

ចាត់ទុកថាជាខ្មាំងដោយបក្សកុម្មុយនីស្តកម្ពុជា។ ហើយគាត់បានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ទី១ គឺអតីតទាហាន និងនគរបាលរបបជំនាន់ លន់ នល់ ដែលគេចាត់ទុកថា ជាសក្តិភូមិនិយម និងមូលធននិយម"។ នៅ ERN មានលេខ 00416327 គាត់បានសរសេរដូចតទៅនេះ ដកស្រង់៖ "ក្នុងពេលជម្លៀស ខ្មែរក្រហមបានប្រកាសថា អ្នកដែលជាទាហាន គ្រូបង្រៀន និងជាមន្ត្រីរដ្ឋការរបប លន់ នល់ ត្រូវប្រមូលផ្តុំមួយកន្លែង ដើម្បីឲ្យអាចបញ្ជូនត្រឡប់ទៅវិញហើយឲ្យបំពេញការងារចាស់។ ផ្ទុយទៅវិញ ពួកគេទុកមន្ត្រីរដ្ឋការយោធា និងរដ្ឋការលន់ នល់ នៅក្នុងមន្ទីរសន្តិសុខបណ្តោះអាសន្នដែលភាគច្រើនជាវត្ត និងសាលារៀន ហើយក្រោយមកបាញ់សម្លាប់ពួកគេនៅទីនោះ ឬក៏នៅព្រៃៗក្បែរនោះ។

[១០:០២:០០]

នៅ ERN មានលេខ 00416322 គាត់បានសរសេរដូចតទៅនេះ សូមខ្ញុំដកស្រង់៖ "ឯកសារមកពីមន្ទីរអប់រំស្រុកត្រាំកក់បង្ហាញថា សឹងតែគ្រប់មេឃុំទាំងអស់នៅក្នុងស្រុកត្រាំកក់ រាយការណ៍ទៅគណៈស្រុក និងប្រធានមជ្ឈិមអំពីទាហាន និងគ្រួសាររបស់ទាហានលន់ នល់។ ហើយបន្តិចទៀតនេះ ខ្ញុំនឹងធ្វើការពិភាក្សាអំពីឯកសារដែលគេពិភាក្សាកន្លងមក។ នៅក្នុងសៀវភៅរបស់ អ៊ា ម៉េងទ្រី នៅត្រង់លេខ 00416381 ដល់ 82 គាត់បានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ភាគច្រើននៃអ្នកដែលត្រូវបានគេចាប់នៅក្នុងពាក់កណ្តាលឆ្នាំ៧៥ និង៧៦ គឺជាទាហាន និងប៉ូលិសលន់នល់។ ក្រោយឆ្នាំ៧៦ ក្រុមនេះពង្រីកទៅដល់ក្រុមគ្រួសារនិងសមាជិករបស់ប្រជាជនជាទូទៅ។ ប្រជាជនជាច្រើនដែលត្រូវបានគេសម្ភាសសម្រាប់ការសិក្សានេះ បានឃើញការចាប់ខ្លួន និងការសម្លាប់ទាហាន និងនគរបាលលន់ នល់ នៅក្នុងពាក់កណ្តាលឆ្នាំ៧៥"។

[១០:០៣:២៨]

ហើយបន្ទាប់មកទៀត គាត់រៀបរាប់អំពីប្រភពមួយចំនួន ហើយខ្ញុំសូមដកស្រង់៖ "ឈិន ដែលជាមេស្រុកបាទីពីឆ្នាំ៧០ ដល់ ៧៥ បានឃើញអ្នកទោសជាច្រើនដែលគេរក្សាទុកនៅមន្ទីរអប់រំកែប្រែស្រុក។ គាត់បានពន្យល់ថា អ្នកដែលស្ថិតនៅក្នុងបញ្ជីត្រូវសម្លាប់ ត្រូវបានគេរៀបរាប់តាមឈ្មោះ និងតួនាទី។ គាត់សង្កេតឃើញថា នៅក្នុងដើមឆ្នាំ៧៦ គឺមានទាហាន និងប៉ូលិសលន់ នល់ កាន់តែច្រើនឡើង គឺច្រើនជាប្រភេទផ្សេងៗទៀត។ នៅក្នុងពាក់កណ្តាលឆ្នាំ៧៥ ធុយ ដែលជាមេឃុំកំពែង បានទទួលផែនការរបស់បក្សស្រុក ដើម្បីធ្វើការឲ្យស្វែងរកចាប់ខ្លួន និងបញ្ជូនទាហានលន់ នល់ ទៅថ្នាក់លើ។ បន្ទាប់ពីទទួលបានប្រវត្តិរូបរបស់ពួកគេ ធុយ បានបញ្ជាឲ្យមានការចាប់មនុស្សជាច្រើន ហើយបញ្ជូន

របាយការណ៍អំពីពួកគេទៅគណៈស្រុកព្រៃកប្បាស"។

លោក លោកស្រីចៅក្រម ខ្ញុំសូមកត់ត្រាថា យើងបានស្តាប់សាក្សីមួយចំនួនដែលជាប្រធានស្រុកព្រៃកប្បាសដែលជាប្អូនប្រុសរបស់ តាម៉ុក ឈ្មោះ ចំ។ ហើយបន្ទាប់មកទៀតគឺមានលេខ 00416383 ខ្ញុំសូមដកស្រង់៖ "អតីតកម្មាភិបាលឃុំពពេល ឈ្មោះតេង បានបញ្ជាក់ថានៅក្នុងពាក់កណ្តាលឆ្នាំ៧៥ មេឃុំរបស់គាត់បានរៀបចំឲ្យមានជាក្រុមភូមិ និងក្រុមដើម្បីស្រង់ប្រវត្តិរូបរបស់ប្រជាជននៅក្នុងឃុំពពេល។ គាត់បានពន្យល់ថាក្នុងការប្រមូលចងក្រងប្រវត្តិរូបនោះ កម្មាភិបាលត្រូវស្វែងរកព័ត៌មានលម្អិតអំពីឈ្មោះ តួនាទី ប្តីប្រពន្ធ កូនចៅ ហើយនិងតួនាទី"។ ហើយបន្ទាប់មកទៀត គាត់បានដកស្រង់ "បន្ទាប់ពីប្រវត្តិរូបត្រូវបានកត់ត្រារួចហើយ ឈន បានបញ្ជូនរបាយការណ៍ទៅគណៈស្រុក ហើយបន្ទាប់ពីនោះមក អ្នកដែលនៅក្នុងឃុំពពេលដែលជាអតីតទាហាន និងនគរបាលលន់ នល់ បានបាត់ខ្លួនជាបន្តបន្ទាប់" សូមបញ្ចប់ការដកស្រង់។

[១០:០៦:០៧]

នៅERNមានលេខ 00416399 គាត់បានសរសេរ ខ្ញុំសូមដកស្រង់៖ "ភាគច្រើននៃអ្នកដែលត្រូវបានគេសម្លាប់នៅក្នុងមន្ទីរអប់រំស្រុកគឺជាទាហាន និង ប៉ូលិសរបស់របប លន់ នល់។ បញ្ជីសម្លាប់មនុស្សនៅស្រុកត្រាំកក់ បង្ហាញថាមនុស្ស៥០០នាក់ត្រូវបានសម្លាប់នៅក្នុងឆ្នាំ៧៧ និងនៅក្នុងឆ្នាំ១៩៧៨។ ២៥២ នាក់ គឺជាទាហាន និងនគរបាលលន់ នល់"។

ឥឡូវនេះ ខ្ញុំសូមបង្ហាញអំពីកំណត់ត្រាអ្នកដែលនៅរស់រានមានជីវិតពីស្រុកត្រាំកក់។ ទាក់ទងទៅនឹងការបោសសម្អាតទាហាន និងមន្ត្រីរាជការលន់ នល់ ហើយខ្ញុំសូមចាប់ផ្តើមអំពីកំណត់ត្រារបស់ក្រាំងតាចាន់។ ឯកសារ E3/4095 – ឯកសារ E3/4095។ នេះគឺជាសៀវភៅកត់ត្រាការសួរចម្លើយនៅក្រាំងតាចាន់ដែលចុះកាលបរិច្ឆេទនៅពាក់កណ្តាលឆ្នាំ៧៦ ប្រហែលជាខែឧសភា ទៅខែកក្កដា ឬក៏ដើមខែកញ្ញាដែលផ្អែកទៅលើការយោងផ្ទៃក្នុងអំពីកាលបរិច្ឆេទ ឬក៏ការយោងទៅលើអ្នកទោសដែលពួកយើងមានឯកសារកន្លងរួចមកហើយ ឬក៏មានភស្តុតាងដែលបង្ហាញអំពីពេលវេលានៃការចាប់ខ្លួន។ ឥឡូវនេះ ខ្ញុំសូមលើកឧទាហរណ៍មួយ នៅក្នុងសៀវភៅនេះ គឺE3/4095 នៅខ្មែរមានលេខ 00271114 អង់គ្លេសមានលេខ 00747274, បារាំងមានលេខ 00721246 គឺមានកំណត់ត្រាពីការសួរចម្លើយរបស់មនុស្សពីរនាក់ ទី១គឺ ថន ធិន ដែលជាជំនួយការលក់បុគ្គលិកពេទ្យ និងទី២ គឺ ឡាយ ធី អតីតទាហានលន់ នល់។ ទាំងពីរនាក់នេះត្រូវបានគេចោទប្រកាន់ថារិះគន់បដិវត្តន៍ហើយមានផែនការរត់ទៅ

ប្រទេសថៃ។ យើងអាចកំណត់កាលបរិច្ឆេទកំណត់ត្រាទាំងអស់នេះបានព្រោះកំណត់ត្រាស្រុកត្រាំកក់ក៏រួមបញ្ចូលនូវរបាយការណ៍សារភាពដែលបញ្ជូនឡើងដោយប្រធានក្រាំងតាចាន់ឈ្មោះ អន -- អ៊ិន -- អាន់ ហើយផ្អែកលើឯកសារទាំងអស់នេះ នោះគឺឯកសារE3/4098 – ឯកសារE3/4098 ដែលមានខ្មែរមានលេខ 00271030 ដល់ 31, អង់គ្លេសមានលេខ 00322114 ដល់ 15 និងបារាំងមានលេខ 00623837 ដល់ 38។ នេះគឺជារបាយការណ៍មកពីប្រធានក្រាំងតាចាន់ឈ្មោះ អាន់ ពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់មនុស្សទាំងពីរនាក់គឺ ឡាយ ធី និង ថន ធិន គឺចុះថ្ងៃទី៤ ខែសីហា ឆ្នាំ៧៦ ដែលនេះ គឺជាពេលវេលាដែលយើងទទួលបានរបាយការណ៍ពីក្រាំងតាចាន់នៅក្នុងសៀវភៅរបស់យើង។

[១០:០៩:៥១]

នៅក្នុងរបាយការណ៍របស់ អាន់ ខ្ញុំសូមដកស្រង់ "កត់សម្គាល់ថាជោគវាសនារបស់បុគ្គលទាំងពីរនេះ ត្រូវបានបង្ហាញដោយកំណត់ត្រាសរសេរដោយដៃ នៅក្នុងផ្នែកខាងលើ ដែលជា--នៃរបាយ-ការណ៍របស់ អន ដែលបញ្ជាក់ថា សួរចម្លើយ បន្ទាប់មកកម្ទេច។ ឯកសារ E3/4095 ដែលជាសៀវភៅដដែលនេះ គឺជាសៀវភៅដែលរួម ដែលកត់ត្រានូវការសួរចម្លើយនៃគ្រួសារសាក្សីឈ្មោះ មាស សុខា ដែលត្រូវបានចាប់ខ្លួន ហើយនាំយកទៅក្រាំងតាចាន់ នៅក្នុងខែមិថុនា ឆ្នាំ៧៦។ ឧទាហរណ៍កំណត់ត្រារបស់ឪពុក មាស សុខា គឺឈ្មោះ មាស គុណ និងបងថ្លៃរបស់គាត់ឈ្មោះ ម៉ម បឿន។ ដែលខ្មែរមានលេខ 00271098, អង់គ្លេសមានលេខ 00747250 និងបារាំងមានលេខ 00721219 ដល់ 20 ដែលយើងបានរៀបរាប់អំពីកំណត់ត្រានេះរួចទៅហើយ ដូច្នេះខ្ញុំមិនរៀបរាប់បន្ថែមទៀតទេ។

សៀវភៅកំណត់ត្រាដដែលនេះ គឺខ្មែរមានលេខ E3/4095 បានកត់ត្រាអំពីឈ្មោះរបស់មនុស្សយ៉ាងតិចបំផុតជាង១០៥នាក់ ដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយនៅក្រាំងតាចាន់។ ក្នុងចំណោមអ្នកទោស១០៥ ដែលមានឈ្មោះនៅក្នុងសៀវភៅនេះ ប្រហែលជាជាងពាក់កណ្ដាលរបស់ពួកគេ គឺ៦២នាក់ គឺជាអតីតមន្ត្រីរដ្ឋការ ទាហាន ប៉ូលិស សាច់ញាតិ ឬក៏មនុស្សដែលពាក់ព័ន្ធជាមួយរបបលន់ នល់ របាយការណ៍កំណត់ត្រាមួយចំនួនបានកត់ត្រាជាពិសេស ដែលថាសាច់ញាតិនៅក្នុងរបបលន់ នល់ ត្រូវបានគេកម្ទេចរួចទៅហើយដោយអង្គការ។ ឧទាហរណ៍ប្រសិនបើយើងមើលទៅលើឈ្មោះ ថាច់ សារ៉ែន ដើម្បីឱ្យជាក់ច្បាស់ជាងនេះទៅទៀតនោះ យើងបែងចែកអ្នកទោស១០៥នាក់ នៅក្នុងឯកសារនេះ ដូចជាតទៅនេះ៖ ២៣នាក់ ជាមន្ត្រីរដ្ឋការ លន់នល់ ដែលមានឋានៈលើសពីអនុសេនីយ៍ រួមមាន វរសេនីយ៍ ៧នាក់ អនុសេនីយ៍ពីរនាក់ ប្រាំនាក់ទៀតជាវរសេនីយ៍ទោស ប្រាំនាក់ទៀតជាវរសេនីយ៍ និងម្នាក់ជា

វរសេនីយ៍ឯក ហើយនិងម្នាក់ទៀត ជាប្រធាន ជាមេស្រុក។

[១០:១២:៤៦]

នេះគឺជាឈ្មោះមនុស្សដែលមាននៅក្នុងក្រាំងតាចាន់ ដែល ៣០នាក់ជាទាហាន ប៉ុន្តែមិនមានបណ្ដាលស័ក្តិអ្វីនោះឡើយ និងជាអតីតប៉ូលិស។ អ្នកទោស៩នាក់ គឺជាសាច់ញាតិ ឬក៏បុគ្គលដែលពាក់ព័ន្ធឬក៏ដែលគាំទ្ររបប លន់ នល់។ ហើយអ្នកដែលនៅសល់គឺ១៧នាក់ គឺជាប្រជាជនថ្មី រួមបញ្ចូលទាំងគ្រូបង្រៀនមួយចំនួនផង ពីរនាក់ជាខ្មែរក្រោម ១០នាក់ជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវគេបោសសម្អាត ដែលពួកគេ ៦នាក់ គឺជាផ្នែកនៃអង្គភាពមួយដែលត្រូវគេបោសសម្អាត។ មនុស្ស ៦នាក់ នៅក្នុងសៀវភៅនេះ គឺជាផ្នែកនៃអ្នកភូមិស្រែគ្រូ ដែលត្រូវបានគេចាប់ខ្លួន បន្ទាប់ពីបោះឆ្នោតដកមេភូមិដែលក្នុងនេះ រួមបញ្ចូលទាំងក្រុមគ្រួសាររបស់ មាស សុខា ផងដែរ ហើយនិងប្រជាជនមូលដ្ឋាន ៧នាក់ទៀត ត្រូវបានគេចាប់ខ្លួន ដោយសារមូលហេតុផ្សេងៗគ្នា។

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសម្រាកហើយ។ ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហព្រះរាអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

សូមអរគុណប្រធាន។ បាទ យើងកំពុងតែពិភាក្សាគ្នាអំពីឯកសារមកពីស្រុកត្រាំកក់ ទាក់ទងទៅនឹងការបោសសម្អាតទាហាន និងនាយទាហាន លន់ នល់ ហើយខ្ញុំទើបតែបញ្ចប់អំពីកំណត់ត្រានៅ

ក្រាំងតាចាន់ គឺE3/495 ហើយខ្ញុំនឹងលើកយកឈ្មោះអ្នកទោសបីនាក់ ដែលមាននៅក្នុងសៀវភៅកត់ត្រានេះ នៅERN ត្រង់ ERN ខ្មែរ 00271094, ERN អង់គ្លេស 00747243, បារាំង 00721212 ជាកំណត់ត្រារបស់ឈ្មោះ ព្រុំ នឹម ជាអតីតគ្រូបង្រៀនដែលបានជួយធ្វើការដើម្បីជួយបោះឆ្នោតដល់ អ៊ិន តាំ ដែលគេចាត់ទុកថាជាមនុស្សម្នាក់ក្នុងពួកមហាក្បត់ប្រាំពីរនាក់ នៅមុនអំឡុងពេលមុនឆ្នាំ១៩៧៥ ហើយកំណត់ត្រានេះបង្ហាញថា គាត់ត្រូវបានចោទប្រកាន់ក្នុងការចែកខិត្តប័ណ្ណប្រឆាំងនឹងបដិវត្តន៍ ដែលនិយាយថា ខ្ញុំសូមដកស្រង់៖ “ក្រោយថ្ងៃរំដោះ យើងហូបបបរ យើងហូបឫសឈើ ហើយយើងឃើញថា ពួកយើងត្រូវបានបំបែកចេញពីកូនចៅ។ យើងមិនមានថ្នាំពេទ្យទេ ហើយយើងក៏ធ្លាក់ខ្លួនឈឺ”។

[១០:៣៣:៤៣]

បាទ ហើយខ្ញុំនឹងបង្ហាញឯកសារដែលពាក់ព័ន្ធទៅនឹងអ្នកដែលបានរិះគន់ ទិតៀនទៅដល់របបនោះ។ អ្នកទោសទី២ -- នៅក្នុងសៀវភៅកត់ត្រានេះ ដែលខ្ញុំលើកយកមកបង្ហាញ គឺអតីតអនុសេនីយ៍ឯករបប លន់ នល់ ឈ្មោះ សួន សាត។ កំណត់ហេតុរបស់គាត់គឺមានត្រង់ ERN 00271100 លើ៣ ដែលជាកំណត់ត្រាសួរចម្លើយ គឺនៅត្រង់ ERN ជាភាសាខ្មែរ 00747254 និង 259, បារាំងគឺ 00721223 ដល់ 24 និង28 ដល់ 30។ នេះគឺពាក់ព័ន្ធទៅនឹងមនុស្សដែលពាក់ព័ន្ធចំនួន១៤នាក់ ហើយអ្នកទាំងអស់នេះក្រោយមកត្រូវបានចាប់ខ្លួនទាំងអស់ ហើយកំណត់ត្រានៃការសួរចម្លើយនេះ ក៏មាននៅក្នុងឯកសារនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកសហព្រះរាជអាជ្ញារង!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ចំណុចនេះ គឺពាក់ព័ន្ធទៅនឹងការពិភាក្សាដែលយើងបានលើកយកមកនិយាយកាលពីសវនាការនៅថ្ងៃសុក្រ គឺកំណត់ត្រាដែលសហព្រះរាជអាជ្ញាបានយោងទៅនេះ គឺពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើអ្នកទោសនៅឯគុកក្រាំងតាចាន់។ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ចំពោះអ្នកទោសនៅក្រាំងតាចាន់ថា ត្រូវបានគេសួរចម្លើយ មិនដឹងថាពិត ឬក៏អត់នោះទេ។ ខ្ញុំនឹងទុកវាសម្រាប់ការពិភាក្សានៅពេលមួយទៀត ហើយខ្ញុំមិនឃើញមានការខុសគ្នានោះទេ ដែលឃើញថា សហព្រះរាជអាជ្ញា គឺអាន

ប្រហែលជាកំពុងតែអានកំណត់ហេតុសួរចម្លើយដែលមានការប្រឡាក់ប្រឡូក ដែលមានការធ្វើទារុណកម្ម។ នេះ គឺថាជាកំណត់ហេតុពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម ដូចនៅស-២១ដែរ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការអានរបស់សហព្រះរាជអាជ្ញា គឺអានចេញអំពីកំណត់ត្រាពីគុកក្រាំងតាចាន់នេះ។

[១០:៣៦:៤៨]

យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការតាំងសំណួរកាលពីថ្ងៃសុក្រ ដើម្បីរាប់បញ្ចូលនូវសេចក្តីសម្រេច ហើយនិងដាក់ចេញជាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរផង ថាតើយើងអានកំណត់ហេតុចេញពីក្រាំងតាចាន់នេះបានដោយរបៀបណា។ ដូចដែលខ្ញុំលើកហើយ មិនមានអ្វីខុសគ្នាទេ រវាងការអានចេញពីកំណត់ហេតុទាំងអស់គ្នានេះ ហើយនិងប្រៀបធៀបទៅនឹងការជំទាស់មកលើការអានរបស់ខ្ញុំ ចំពោះឯកសារស-២១។

**លោក ឌេល លីសាក់៖**

នេះជាការពិភាក្សាដែលយើងគួរតែនិយាយគ្នានៅពេលក្រោយ។ ខ្ញុំនឹងបង្ហាញនូវភាពខុសគ្នាមួយ គឺកំណត់ត្រានេះត្រូវបានប្រើប្រាស់ និងទទួលយកដើម្បីបង្ហាញឲ្យឃើញថា តើអ្នកទោសទាំងអស់នោះជាអ្នកណាដែរ? ហើយការប្រើប្រាស់ឯកសារនេះ គឺដើម្បីបង្ហាញនូវដំណើរការពាក់ព័ន្ធ។ ឧទាហរណ៍ ដូចខ្ញុំបានទើបតែលើកជូន គឺនៅពេលដែលអ្នកទោសម្នាក់ដែលបានបង្ហាញបញ្ជីមួយពាក់ -- ឆ្លើយដាក់ទៅនឹងអ្នកដទៃទៀត ហើយអ្នកទាំងនោះ ក៏ត្រូវបានចាប់ខ្លួននៅពេលក្រោយ។

អ្វីដែលខុសគ្នា គឺថាមេធាវីការពារក្តីប្រើប្រាស់ចម្លើយសារភាពដែលមានការធ្វើទារុណកម្ម គឺយកខ្លឹមសាររបស់វាតែម្តង។ នេះគឺជាចំណុចមួយដែលសំខាន់ ដែលអង្គជំនុំជម្រះត្រូវពិចារណាទៅលើចំណុចនេះ ហើយខ្ញុំគិតថាវាមានតម្លៃណាស់សម្រាប់ការពិភាក្សា។ អង្គជំនុំជម្រះអាចវិនិច្ឆ័យទៅលើភស្តុតាងពាក់ព័ន្ធដើម្បីយកមកពិភាក្សា ពេលដែលយើងពាក់ព័ន្ធទៅដល់ការបង្ហាញឯកសារ ហើយនៅពេលដែលភាគីផ្តល់ជាមតិយោបល់ផ្សេងៗទៅលើឯកសារនោះ។

ខ្ញុំយល់ឃើញថា ភស្តុតាងត្រូវបានប្រើប្រាស់នៅពេញដំណើរការនីតិវិធីនេះតែម្តង ហើយដែលវាខុសគ្នាទៅនឹងចម្លើយសារភាព ដោយសារតែការធ្វើទារុណកម្ម។

[១០:៣៩:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៥:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ដើម្បីឆ្លើយបញ្ជាក់ជូនភាគីអំពីបញ្ហាដែលមានការជំទាស់តវ៉ាពីសំណាក់មេធាវីការពារក្តីលោក នួន ជា លើរបៀបនៃការដាក់បង្ហាញឯកសារចុងក្រោយដែលធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើគោលបំណងពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ត្រានៅក្នុងក្រាំងតាចាន់អាចបង្ហាញអំពីអត្តសញ្ញាណរបស់អ្នកដែលត្រូវបានឃុំនៅក្នុងមន្ទីរសន្តិសុខនោះ អង្គជំនុំជម្រះយល់ឃើញថាមិនមានការជំទាស់ក្នុងការប្រើប្រាស់ឯកសារបែបនេះទេ។ អង្គជំនុំជម្រះចងចាំជានិច្ចពាក់ព័ន្ធនឹងបញ្ហា -- ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលខ្លួនចេញ ពាក់ព័ន្ធនឹងបញ្ហាដែលលើកឡើងដោយលោក កូប៉េ ហើយយើងនឹងចេញសេចក្តីសម្រេចនៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:៤៦:៣២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឯកសារបន្ទាប់ដែលខ្ញុំចង់លើកយកមកសំអាង គឺឯកសារមកពីក្រាំងតាចាន់ គឺឯកសារ E3/2107, ERN ជាភាសាខ្មែរគឺ 00068054, អង់គ្លេស 00290212 និងបារាំង 00655731។ ហើយនៅត្រង់ទំព័រនេះ គឺកំណត់ត្រានេះបង្ហាញនូវប្រពន្ធរបស់មន្ត្រីទាហានលន់ នល់ ពីរនាក់ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅក្រាំងតាចាន់។ ទី១ គឺឈ្មោះ នាង គង់ ជាស្ត្រីដែលមានអាយុ៤៣ឆ្នាំ ហើយប្តីរបស់គាត់គឺជាអនុសេនីយ៍ទោ គាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅក្រាំងតាចាន់ដោយសារបដិសេធមិនព្រមទទួលយកខោអាវដែលអង្គការចែកឲ្យ។ ទី២ ឈ្មោះ ឡាំង ហ៊ ជាស្ត្រីដែលមានអាយុ២៧ឆ្នាំមកពីក្រុងតាកែវ ដែលប្តីរបស់គាត់គឺជាប៉េអឹមពាក់ស័ក្តិ២ ហើយអង្គការបានចាប់ប្តីរបស់គាត់មុនពេលដែលគាត់ចាកចេញពីទីរួមខេត្តតាកែវ។ មូលហេតុនៃការឃុំខ្លួននេះ គឺមានដូចតទៅ សូមដកស្រង់៖ “កូនរបស់គាត់ឈឺ ហើយហើម មិនអាចដើរបាន ហើយគាត់មានកូនច្បងមួយនោះ គឺបានយកបាយមកឲ្យកូនដែលឈឺហ្នឹងហូប”។ បញ្ចប់ការដកស្រង់។

[១០:៤៨:៣៩]

ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ គឺមានឯកសារសំខាន់ៗមួយចំនួននៅអំឡុងពេលពីខែមេសា ដល់ខែឧសភា ១៩៧៧ ដែលក្នុងនេះ ឃុំផ្សេងៗបានរាយការណ៍ជូនទៅថ្នាក់ស្រុក ហើយនិងបានលើកឡើងអំពីការណែនាំរបស់បក្សដើម្បីធ្វើការកំណត់មុខសញ្ញា និងបោសសម្អាតខ្មាំងដែលជាមន្ត្រី ឬអ្នកដែលមានតួនាទីខ្ពង់ខ្ពស់ក្នុងរបបចាស់។ យើងបានពិនិត្យមើលឯកសារនេះមួយចំនួន ដែលត្រូវបានប្រើប្រាស់ពាក់ព័ន្ធជាមួយនឹងសាក្សីទាំងនេះ។ ដូច្នេះ ខ្ញុំនឹងយកឯកសារនេះមកបង្ហាញជូនមួយចំនួនតូច ហើយមានឯកសារមួយចំនួនធំដែលយើងខ្ញុំមិនលើកយកមកបង្ហាញទេ។ យើងខ្ញុំនឹងបង្ហាញឯកសារទាំងអស់នេះរួមជាមួយគ្នាគឺឯកសារមកពីឃុំផ្សេងៗគ្នាដើម្បីឱ្យមើលឃើញទិដ្ឋភាពបានច្បាស់អំពីការបោសសម្អាតក្រុមមនុស្សប្រភេទនេះនៅក្នុងស្រុកត្រាំកក់។ ឃុំទី១ គឺឃុំតាភេម ឯកសារពាក់ព័ន្ធគឺ E3/2048 – E3/2048 នៅត្រង់ERN ជាភាសាខ្មែរ 00079091, អង់គ្លេស 00276564, បារាំង 00611661។ នេះគឺជារបាយការណ៍ចុះថ្ងៃទី២៣ ខែមេសា ១៩៧៧ មកពីប្រធានឃុំតាភេម ឈ្មោះ គិត ផ្ញើជូនអង្គការដោយនិយាយថា "ខ្ញុំបានពិនិត្យមើលនិងបោសសម្អាតខ្មាំង ដែលមានបណ្ដាស័ក្ដិក្រោយពីបានទទួលសេចក្ដីណែនាំអំពីបក្សរួចមក" បញ្ចប់។ របាយការណ៍បានបន្តទៅនិយាយទៀតថា "ការស៊ើបអង្កេតបន្តទៀត ដែលពាក់ព័ន្ធទៅនឹងនាយទាហាន និងអ្នកមានបណ្ដាស័ក្ដិចំនួន ប្រាំមួយនាក់ទៀត ដែលត្រូវបានកំណត់មុខសញ្ញារួចហើយ គឺក្នុងនោះមានស័ក្ដិមួយ ពីរនាក់ និងស័ក្ដិពីរ បីនាក់"។

[១០:៥១:០៤]

ឃុំបន្ទាប់មកទៀត គឺឃុំជាងទង ឯកសារពាក់ព័ន្ធ E3/2048, ត្រង់ ERN ជាភាសាខ្មែរ 0007 9089, អង់គ្លេស 00276562 ដល់ 63 និងបារាំង 00611659។ នេះគឺជារបាយការណ៍មកពីមេឃុំជាងទងឈ្មោះ ហឿន ផ្ញើជូនអង្គការស្រុកត្រាំកក់ ចុះថ្ងៃទី៣០ មេសា ១៩៧៧ ដែលនិយាយដូចតទៅសូមដកស្រង់៖ "ក្រោយពីបានទទួលសេចក្ដីណែនាំជាបន្តបន្ទាប់ពីអង្គការអំពីការតាមដានខ្មាំង និងការបោសសម្អាតខ្មាំង យើងបានតាមដានពិនិត្យមើល និងរកឃើញបុគ្គលដូចតទៅនេះ៖ របាយការណ៍បន្ទាប់មកបានកំណត់មុខសញ្ញាបុគ្គលពីរនាក់ទៀតជាអតីតពាក់ស័ក្ដិពីរ និងមន្ត្រីម្នាក់មកពីក្រសួងអភិវឌ្ឍន៍សង្គមហើយដែលត្រូវបានបញ្ជូនទៅកន្លែងប៉ូលិសស្រុក។ របាយការណ៍ក៏បានលើកឡើងពាក់ព័ន្ធទៅនឹងមន្ត្រីពីរនាក់។ ឪពុករបស់គាត់គឺជាអ្នករៀប -- ជាចីផែនទីនៅក្នុងខេត្តតាកែវ។ នៅពេលរំដោះ គាត់ក៏បានមកវត្តចំប៉ា ហើយអង្គការក៏បានដកខ្លួនគាត់ទៅ"។

[១០:៥២:៤៦]

សម្រាប់ឃុំអង្គតាសោម យើងមានឯកសារ E3/2435 – E3/2435។ នេះជារបាយការណ៍ផ្ញើជូនអង្គការស្រុកមកពីឃុំអង្គតាសោម ចុះថ្ងៃទី២៦ មេសា ១៩៧៧ ដែលបញ្ជាក់ថាសុំដកស្រង់៖ “អ្នកដែលមានបណ្ដាស័ក្តិ គឺដូចជា ស័ក្តិ១ ឬក៏ស័ក្តិ២ ខ្ញុំនឹងទៅទាក់ទងជាមួយ មិត្តយ៉ន ជាយោធាស្រុក ដើម្បីយកពួកគេចេញនៅល្ងាចនេះ”។ បញ្ចប់ការដកស្រង់។

លោកប្រធាន ខ្ញុំបានសួរទៅសហការីរបស់ខ្ញុំ ដើម្បីរកឯកសារមកបង្ហាញជូនសាក្សី។ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ ពីពេលមួយ ទៅពេលមួយ ដូចដែលខ្ញុំបានលើកឡើងហើយ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារដែលលើកឡើងនេះ ជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក ឌេល លីសាក់៖**

ទាក់ទងទៅនឹងឃុំអង្គតាសោម ក៏មានឯកសារមកពីឃុំដដែលនេះនៅចុងឆ្នាំ គឺនៅខែវិច្ឆិកា ឆ្នាំ ១៩៧៧ នេះគឺឯកសារ E3/4123 ៗ, ERN ជាភាសាខ្មែរ 00271044, អង់គ្លេស 00322179, បារាំង 00623855។ ឯកសារនេះបានលើកឡើងដូចតទៅ សូមដកស្រង់៖ “ស្នើសុំឲ្យប្រាប់ទៅសមមិត្ត គិត និងឲ្យទាក់ទងជាមួយសមមិត្ត អាន់ ពាក់ព័ន្ធទៅនឹងឈ្មោះដែលមានបណ្ដាស័ក្តិខ្ពង់ខ្ពស់ អង្គការគឺបានសម្រេចរួចហើយ”។ បញ្ចប់ការដកស្រង់។ ឃុំបន្ទាប់មកទៀតគឺឃុំពពេល។ ឯកសារគឺ E3/4103 ៗ, នៅត្រង់ERN ភាសាខ្មែរ 00143476, អង់គ្លេស 00322133, បារាំង 00612838។ នេះគឺជារបាយ-ការណ៍ចុះថ្ងៃទី១១ ខែមេសា មកពីមេឃុំពពេល ឈ្មោះ ឆន ផ្ញើជូនអង្គការស្រុក ដែលលើកឡើងថា សម្រាប់អ្នកដែលតួនាទីបុណ្យស័ក្តិ យើងខ្ញុំនឹងបញ្ជូនមកឲ្យសមមិត្តជាបន្តបន្ទាប់”។ បញ្ចប់ការដកស្រង់។

មួយខែក្រោយមក នៅខែឧសភា ១៩៧៧ នៅក្នុងឯកសារ E3/2048, នៅត្រង់ ERN ជាភាសាខ្មែរ 00079090, អង់គ្លេស 00276563 ដល់ 64, បារាំង 00611660។ មេឃុំដដែល គឺឃុំពពេល ឈ្មោះ ឆន បានរាយការណ៍មកជូនថ្នាក់ស្រុកដែលថា ក្រុមគ្រួសារទាហាន១០៦គ្រួសារ ដែលមានមនុស្សទាំងអស់ ៣៩៣នាក់ ដែលត្រូវបានអង្គការកម្ទេចរួចហើយ ឬក៏បានស្លាប់អស់ហើយ ហើយឃុំក៏កំពុងពិនិត្យមើលបន្តថែមទៀត ដើម្បីរកឲ្យឃើញ ថាតើពួកគេគឺជាបុគ្គលិកយោធាឬក៏អត់។

[១០:៥៧:១៧]

ឃុំមួយទៀតគឺឃុំញ៉ែងញ៉ង គឺឯកសារ E3/2432។ ជារបាយការណ៍មកពីឃុំដដែល មកពីឃុំពពេល ចុះថ្ងៃទី១៨ ខែមេសា ដែលកំណត់អតីតទាហាន នាយទាហានលន់នល់ចំនួន១១នាក់ ក្នុងនោះ គឺមានស័ក្តិ៤ពីរនាក់ ហើយនិងស័ក្តិ៤កន្លះប្រាំនាក់ ស័ក្តិ២បួននាក់។ យើងក៏មានរបាយការណ៍ពីឃុំពពេលដដែលនេះ មួយផ្សេងទៀតដែរ គឺឯកសារ E3/2450។, ERN ជាភាសាខ្មែរ 00270746, អង់គ្លេស 00322161, បារាំង 00623747។ របាយការណ៍នេះបានបញ្ជាក់ថា អតីតស័ក្តិ -- ទាហានពាក់ស័ក្តិ២របប លន់ នល់ បីនាក់ត្រូវបានបញ្ជូនទៅមេគុកក្រាំងតាចាន់ ឈ្មោះ អាន់ ដែលបក្សបានសម្រេចរួចហើយ ដោយសារអ្នកទាំងអស់នេះ មានបុណ្យបណ្តាស័ក្តិខ្ពស់ ហើយលិខិតនេះក៏បានបញ្ជាក់ឡើងច្បាស់ហើយថា មិនមានការទំនាស់ ឬក៏មានជំទាស់តវ៉ាជាមួយនឹងបុរសទាំងបីនាក់នោះទេ ប៉ុន្តែខ្ញុំសូមដកស្រង់៖ “ពួកគេត្រូវបានចាប់ខ្លួនដោយសារពួកគេមានបណ្តាស័ក្តិ”។ បញ្ចប់ការដកស្រង់។

ឃុំបន្ទាប់មកទៀត ដែលយើងទទួលបានប្រភេទឯកសារដូចគ្នានេះ គឺឃុំគុស។ ឯកសារពាក់ព័ន្ធ E3/2441។ ត្រង់ ERN ជាភាសាខ្មែរ 00270934, អង់គ្លេស 00369464, បារាំង 00611738។ នេះគឺជារបាយការណ៍ចុះថ្ងៃទី៤ ឧសភា ១៩៧៧ មកពីឃុំគុស ដែលកំណត់ សូមដកស្រង់ “អ្នកដែលមានបណ្តាស័ក្តិដែលបានចាប់ខ្លួន និងបញ្ជូនទៅនគរបាល។ រួចហើយ គឺដែលនៅថ្ងៃនោះ មានទី១ មានស័ក្តិ១ម្នាក់ ហើយនិងសក្តិ២ម្នាក់ ដែលជាខ្មែរក្រោមមកពីភ្នំពេញ”។

[១១:០០:២៩]

ឯកសារមួយទៀតមកពីឃុំដដែល ចុះថ្ងៃទី៩ ខែកញ្ញា ១៩៧៧ បង្ហាញថា ការចាប់ខ្លួននាយទាហានលន់ នល់ បានបន្តធ្វើរហូតពេញមួយឆ្នាំ គឺឯកសារ E3/2441។, ERN ជាភាសាខ្មែរ 0027 0952, អង់គ្លេស 00369480, បារាំង 00611755។ នេះ គឺជារបាយការណ៍មកពីឃុំគុស ដែលមានបញ្ជីឈ្មោះទាហានលន់ នល់ ចំនួនប្រាំពីរនាក់។ មួយគឺអនុសេនីយ៍មួយ ស័ក្តិ១ប្រាំនាក់ និងសក្តិ២ពីរនាក់ ដែលត្រូវបានបញ្ជូនទៅអង្គការរួចហើយ។

ឃុំលាយបូរ គឺឯកសារ E3/2423។, ERN ជាភាសាខ្មែរ 00279134, អង់គ្លេស 00322216 បារាំង 00611736។ នេះគឺជារបាយការណ៍ ចុះថ្ងៃទី២៩ មិថុនា ១៩៧៨ មកពីឃុំលាយបូរ ដែលបញ្ជាក់ថាខ្មាំងចំនួនបួននាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅឲ្យមេគុកក្រាំងតាចាន់ឈ្មោះ អាន់ ហើយហើយខ្មាំងចំនួនបួននាក់ គឺពីរនាក់ជាខ្មែរក្រោម ដែលជាអតីតទាហាន ហើយមួយទៀតជាប្រធានគមនាគមន៍ និងស័ក្តិ២ របបអតីត -- ស័ក្តិ២ របបលន់ នល់ ពីរនាក់។ របាយការណ៍នេះ បានបញ្ជាក់ថា

ខ្មាំងទាំងបួននេះត្រូវបានបញ្ជូនដោយសារតែ ដោយអនុវត្តទៅតាមមាគ៌ារបស់អង្គការ ដោយសារតែបក្សគឺបានសម្រេចរួចហើយ ឲ្យបញ្ជូនខ្លួនពួកគេ។

[១១:០៣:០៥]

ឃុំចុងក្រោយនៅក្នុងប្រធានបទនេះ គឺឃុំខ្ពបត្របែក។ ឯកសារពាក់ព័ន្ធ E3/2050ៗ, ERN ជាភាសាខ្មែរ 00079111, អង់គ្លេស 00276576, បារាំង 00858041។ លោក លោកស្រីចៅក្រមនេះគឺជារបាយការណ៍ ចុះថ្ងៃទី៦ ខែឧសភា ១៩៧៧ ផ្ញើទៅថ្នាក់ស្រុក។ របាយការណ៍មកពីមេឃុំខ្ពបត្របែក ឈ្មោះ ចំ គឺជាប្អូនរបស់ តាម៉ុក។ របាយការណ៍បានលើកឡើងដូចតទៅ សូមដកស្រង់៖ “ទាក់ទងទៅនឹងអ្នកដែលធ្លាប់មានបណ្ដាស័ក្តិ និងតួនាទីខ្ពង់ខ្ពស់ នៅមូលដ្ឋានឃុំខ្ពបត្របែក ឈ្មោះរបស់ពួកគេ គឺមានដូចតទៅ...”។ បញ្ចប់ការដកស្រង់។

របាយការណ៍បានបញ្ជាប់ គឺថា មានស័ក្តិ៣ម្នាក់ ស័ក្តិ១ម្នាក់ ស័ក្តិ២ពីរនាក់ -- ស័ក្តិ២ម្នាក់ និងអនុសេនីយ៍ម្នាក់។ ឈ្មោះរបស់នាយទាហាន អតីតរបបលន់ នល់ ពីរនាក់ គឺឈ្មោះ គាត ខាំ និង គង់ បូរ៉ន គឺមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់ ដែលត្រូវបានសម្លាប់ចោលពីរអាទិត្យក្រោយមកទៀត គឺនៅថ្ងៃទី២២ ខែឧសភា ១៩៧៧។ បញ្ជីអ្នកទោសដែលគេប្រហារជីវិតនេះគឺឯកសារ E3/4145ៗ, នៅត្រង់ ERN ជាភាសាខ្មែរ 00068737, អង់គ្លេស 00762845 និងភាសាបារាំង 00761101។ នាយទាហាន លន់ នល់ ទាំងពីរនាក់នេះត្រូវបានប្អូនប្រុសរបស់ តាម៉ុក ដែលជាមេឃុំបានរាយការណ៍ គឺលេខរៀងទី២២ និង២៣ នៅក្នុងបញ្ជីនេះ។

[១១:០៦:២០]

នៅពេលដែលយើងមើលបញ្ជីអ្នកទោសដែលគេសម្លាប់ចោលនេះ លេខរៀង២៩ គឺចុះថ្ងៃទី២២ ខែឧសភា ១៩៧៧ គឺអតីតអនុសេនីយ៍ឯកទាហានលន់ នល់ អាយុ២៧ឆ្នាំ ឈ្មោះ គឹម សេង នាយទាហានរូបនេះត្រូវបានឃុំគុសរាយការណ៍មួយសប្តាហ៍មុននៅក្នុងឯកសារ E3/2441, ត្រង់ ERN ជាភាសាខ្មែរ 00270936 គឺ 00270936, អង់គ្លេស 00369466, បារាំង 00611740។

មួយខែក្រោយមក គឺនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ៧៧ គឺរបាយការណ៍ទៅបក្សស្រុក ដែលជាឯកសារ E3/2052ៗ មេឃុំខ្ពបត្របែកឈ្មោះ ចាំ បានកំណត់អតីតទាហាន ១០រូបមកពីភ្នំពេញរួមទាំងស័ក្តិ១ផងដែរ ហើយស្នើសុំប្រគល់ជូនអង្គការ។ ក្នុងការឆ្លើយតបទៅនឹងរបាយការណ៍នេះ ប្រធានមេស្រុកឈ្មោះ គិត បានសរសេរទៅ អាន់ ដែលជាប្រធានគុកក្រាំងតាចាន់ ដោយបង្គាប់ដូចតទៅនេះ

ដកស្រង់៖ "ពាក់ព័ន្ធទៅនឹងជនក្បត់១០រូបដែលឃុំខ្លួបត្រូវបែកបញ្ជូនកាលពីម្សិលមិញ ស្នើសមមិត្តសួរចម្លើយឲ្យបានហ្មត់ចត់ តឹងតែង ហើយរកឲ្យឃើញនូវបណ្ដាញទាំងអស់របស់ពួកវា"។ បញ្ចប់ការដកស្រង់។

[១១:០៨:៤៨]

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ទៅលើប្រធានបទមួយនេះ ដោយខ្ញុំលើកឡើងនូវឯកសារ E3/4166ៗ។ ជាឯកសារបង្ហាញពីការដឹងឮ និងការអនុវត្តគោលនយោបាយ ដោយប្រធានគុកក្រាំងតាចាន់ និងលេខាស្រុកត្រាំកក់។ E3/4166 គឺជារបាយការណ៍ថ្ងៃ២៥ ខែសីហា ៧៧ មកពីប្រធានគុកឈ្មោះ អាន់ ពាក់ព័ន្ធទៅនឹងសារភាពរបស់អតីតមន្ត្រីលន់ នល់ បីរូប។ ទី១ គឺស័ក្តិ១ និងពីរនាក់ទៀតអនុសេនីយ៍។ បន្ទាប់ពីបានរៀបរាប់ថាតើអតីតមន្ត្រីទាំងបីរូបនេះ ធ្វើយ៉ាងដូចម្ដេចប្រឆាំងនឹងអង្គការប្រឆាំងនឹងសហករណ៍ ព្រោះថាពួកគេធ្វើការដោយមិនយកចិត្តដាក់ ហើយមិនរីករាយជាមួយនឹងការងារ។ អាន់ បានសរសេរតទៅនេះ ខ្ញុំសូមដកស្រង់៖ "លើសពីនេះទៅទៀត អាទាំងបីនាក់នេះគឺជាមន្ត្រីមានបណ្ដាស័ក្តិ ដែលគួរតែនាំចូល ដែលគួរតែចាប់ខ្លួន"។

[១១:១០:១៥]

ហើយលោក លោកស្រីចៅក្រម ខ្ញុំគិតថាមានការបកប្រែខុសគ្នារវាងបារាំង និងភាសាអង់គ្លេស ដូច្នេះ ខ្ញុំនឹងស្នើសុំឲ្យសហការីរបស់ខ្ញុំអានជាភាសាខ្មែរ ដើម្បីឲ្យមានកំណត់ត្រាច្បាស់លាស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ លោកប្រធាន ខ្ញុំនឹងអានឯកសារ E3/4166 ឃ្លាចុងក្រោយនោះគឺ មានបានសរសេរថា "ម៉្យាងទៀត ពួកអាទាំងបីនាក់នេះ ជារដ្ឋការ មានបណ្ដាស័ក្តិ ដែលទិសអង្គការត្រូវប្រមូលយកមក"។ បាទ សូមអរគុណ។

**លោក ខេល លីសាក់៖**

លោក លោកស្រីចៅក្រម ក្នុងការឆ្លើយតបទៅនឹងរបាយការណ៍--

[១១:១១:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យមានការបញ្ជាក់បំភ្លឺបន្តិច។ ខ្ញុំហាក់ដូចជាមិនឃើញថាមានភាពខុសគ្នារវាងបារាំង និងភាសាអង់គ្លេសទេទាក់ទងនឹងការបកប្រែ ព្រោះខ្ញុំស្តាប់ទៅដូចជាច្របូកច្របល់បន្តិចដែលថាគាត់ -- វាហាក់ដូចជាមិនមានភាពច្បាស់លាស់ទាក់ទងទៅនឹងឃ្លាមួយនេះ។

**លោក ឌេល លីសាក់៖**

មេធាវី ការពិតខ្ញុំគ្រាន់តែចង់ឲ្យអានទូវឯកសារដើមភាសាខ្មែរចូលទៅក្នុងកំណត់ត្រាប៉ុណ្ណោះ យើងមិន -- យើងនឹងដោះស្រាយបញ្ហាបកប្រែនៅពេលក្រោយតែប៉ុណ្ណោះ។ ដូច្នេះ អ្វីដែលខ្ញុំចង់បញ្ជាក់គឺថាវាមានភាពខុសគ្នារវាងបារាំងនិងភាសាអង់គ្លេស ព្រោះថាខ្ញុំមិននិយាយភាសាបារាំងទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់មានការនិយាយយោងដែលថា ការចាប់ខ្លួនត្រូវធ្វើឡើងដោយគោរពទៅតាមផែនការរបស់អង្គការនេះគឺជាការបកប្រែដែលយើងធ្វើការផ្ទៀបជាមួយនឹងភាសាដើម គឺភាសាខ្មែរ។

លោក លោកស្រីចៅក្រម ជាការឆ្លើយតបទៅនឹងរបាយការណ៍នៅថ្ងៃ២៧ ខែសីហា ឆ្នាំ៧៧ គឺពីរថ្ងៃក្រោយមកគឺលេខាស្រុកឈ្មោះ គិត បានចេញសេចក្តីបង្គាប់ដូចតទៅនេះ ដែលសេចក្តីបង្គាប់នោះ គឺជាកំណត់ត្រាជាសរសេរដៃ ហើយមាននៅចុងទំព័រ។ "ចំពោះជនក្បត់ទាំងបីរូបនេះ បក្សសម្រេចកម្ទេចចោល" សូមបញ្ចប់ការដកស្រង់។

[១១:១៣:០០]

ឯកសារបន្ទាប់ដែលខ្ញុំចង់ធ្វើការបង្ហាញ គឺការកំណត់មុខសញ្ញាទៅប្រជាជនថ្មីនៅក្នុងស្រុកត្រាំកក់។ ជាដំបូងគឺឯកសារ E3/4120 គឺមានលេខ ERN ភាសាខ្មែរ 00270982 ដល់ 983, អង់គ្លេសមានលេខ 00322175, បារាំងមានលេខ 00623344។ ឯកសារនេះគឺជារបាយការណ៍មកពីមេឃុំស្រែរនោង ឈ្មោះឃុន ចុះថ្ងៃ៤ មករា ៧៧ ផ្ញើជូនអង្គការបក្សស្រុក១០៥ ដោយកំណត់អំពីប្រជាជនថ្មីគឺឈ្មោះ ពេជ សុវណ្ណ ដែលត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅមន្ទីរសន្តិសុខដើម្បីសួរចម្លើយ ដោយសារតែគាត់បានដេញទាចូលទៅក្នុងវាលស្រែឲ្យស៊ីស្រូវ។ ផ្នែកដែលសំខាន់នៃរបាយការណ៍នេះ គឺនៅត្រង់សេចក្តីសន្និដ្ឋានបញ្ចប់ដែលមេឃុំស្រែរនោងឈ្មោះ ឃុន បានសរសេរដូចតទៅនេះ៖ "ខ្ញុំចង់ឲ្យច្បាស់ចំពោះបក្ស ថាពាក់ព័ន្ធទៅនឹងប្រជាជនថ្មី គឺមានប្រជាជនជាច្រើនដែលនៅប្រឆាំងជាមួយអង្គការហើយនិងបក្ស ដូច្នេះខ្ញុំនឹងចាប់ពួកគេ ហើយនិងបញ្ជូនពួកគេទៅជាបន្តបន្ទាប់"។

[១១:១៥:០៨]

លោក លោកស្រីចៅក្រម ប្រជាជនថ្មីម្នាក់នេះដែលបានដេញទាចូលទៅក្នុងស្រែ ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅក្រាំងតាចាន់។ ហើយមានកំណត់ត្រាសួរចម្លើយរបស់គាត់នៅក្នុងសៀវភៅក្រាំងតាចាន់ គឺឯកសារ E3/2107 ដែលមានភាសាខ្មែរ មានលេខ 00068065, អង់គ្លេសមានលេខ 00290231 ដល់ 32 និងភាសាបារាំង 00655746។ ឯកសារបន្ទាប់ គឺសៀវភៅរបស់ក្រាំងតាចាន់ ឯកសារ E3/4095 គឺខ្មែរមានលេខ 00271106, បារាំងមានលេខ 00721-- អង់គ្លេសមានលេខ 00747263 គឺមានអ្នកទោសម្នាក់ឈ្មោះ កៅ ភឿន គឺអាយុ៤៤ឆ្នាំ ដែលមានកូនពីរនាក់មកពីតាខ្មៅ ដែលធ្វើការជាអ្នកបើកបរដឹកស្រូវពីបាត់ដំបងទៅភ្នំពេញ ហើយត្រូវបានគេជម្លៀសទៅឃុំញ៉ែងញ៉ង នៅស្រុកត្រាំកក់។ កំណត់ត្រាបានបញ្ជាក់ថា បក្សឃុំបានចាត់តាំងអ្នកភូមិឈ្មោះ ម៉េង ឲ្យបង្កប់ខ្លួនធ្វើជាប្រជាជនថ្មីដូចគាត់ ហើយទៅជជែកជាមួយគាត់។ ហើយលោក កៅ ភឿន ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅក្រាំងតាចាន់ ពីព្រោះនៅក្នុងពេលជជែកគ្នានេះ។ គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ខ្ញុំមកតែរូបរាងកាយនោះទេ ប៉ុន្តែចិត្តគំនិត និងអារម្មណ៍របស់ខ្ញុំនៅភ្នំពេញ។ ឥឡូវនេះ តើយើងអួតអំពីបក្ស អំពីការរំដោះដោយរបៀបណានៅពេលដែលកូនចៅរបស់យើងស្លាប់? ហើយតើយើងអួតអំពីការវិវឌ្ឍដោយរបៀបណា? ការវិវឌ្ឍរីកចម្រើន គឺគ្មាន។" សូមបញ្ចប់ការដកស្រង់។

[១១:១៨:១២]

បន្ទាប់គឺនៅក្នុងសៀវភៅក្រាំងតាចាន់ គឺឯកសារ E3/2107ៗ, មានលេខ ERN ភាសាខ្មែរ 000 68064, ភាសាអង់គ្លេសមានលេខ 00290229 និងបារាំងមានលេខ 00655744 ដល់ 45។ កំណត់ត្រានេះ គឺនិយាយអំពីអ្នកទោសម្នាក់ឈ្មោះ សុខ លាង គឺជាប្រជាជន១៧មេសា ដែលបានត្រឡប់មកពីភ្នំពេញ មកឃុំស្រែរនោងវិញ។ ហើយកំណត់ត្រាបានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់ "អង្គការចាត់តាំងគាត់ឲ្យយួរទឹកដាក់ស្រែ នៅក្នុងខែធ្នូ ជាមួយនឹងប្រជាជន១២នាក់ទៀត ទាំងប្រជាជនថ្មី និងប្រជាជនចាស់។ នៅពេលដែលប្រភពទឹករីងអស់ទៅ ពួកគេចាប់ត្រី ហើយបាចទឹកទៅលើភ្លឺ ហើយនិងចូលទៅក្នុងវាលស្រែ គឺថាពួកគេគិតតែរឿងចាប់ត្រីប៉ុណ្ណោះ។ អង្គការឃុំ គឺបងឃឿន។ នេះគឺជាការនិយាយយោងទៅលើមេឃុំស្រែរនោង "ឃឿន បានឃើញសកម្មភាពនេះ ហើយនិងសួរថាតើពួកគេមកពីភូមិណា? ហើយគាត់និយាយថា ខ្ញុំស្អប់ប្រជាជនថ្មីទាំងអស់នេះណាស់។ ខ្ញុំឲ្យពួកគេរែកទឹកមកដាក់ស្រែ ប៉ុន្តែពួកគេបែរជាបាចទៅលើទួលវិញ ហើយបន្ទាប់ក៏ដើរទៅបាត់ទៅ។ បន្ទាប់មក ក្រុមទាំងអស់គ្នានោះបាននិយាយថា ប្រព្រឹត្តកំហុស ហើយពួកគេរិះគន់តែប្រជាជនថ្មី ប៉ុន្តែពួកគេមិនដែល

និយាយអ្វីជាមួយប្រជាជនមូលដ្ឋាន។ ដល់ពេលក្រោយមក អង្គការភូមិបានធ្វើការប្រជុំ ហើយអប់រំគាត់អំពីបញ្ហាខាងលើ។ ហើយគាត់និយាយថាមិនចាំបាច់អប់រំខ្ញុំទេ ខ្ញុំដឹងច្បាស់ហើយ។ គាត់មិនពេញចិត្តជាមួយនឹងបដិវត្តន៍របស់យើង"។ បន្ទាប់មក គឺឯកសារទាក់ទងទៅលើប្រធានបទប្រជាជនថ្មី គឺឯកសារ E3/4164១ ដែលនេះគឺជាឯកសារដែលពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនផងដែរ។

[១១:២១:១៣]

គឺជាបញ្ជីអ្នកទោស២៨នាក់ ដែលមានចំណងជើងថា "ប្រវត្តិរូបសង្ខេបរបស់អ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់"។ បញ្ជីទាំងនេះ រួមមានឈ្មោះអ្នកទោស អាយុ ភេទ ភូមិ ឃុំ និងស្រុក ឋានៈ តួនាទី ឈ្មោះប្ដី ឬក៏ប្រពន្ធ និងតើពួកគេជាប្រជាជន១៧ មេសា ឬក៏ប្រជាជនមូលដ្ឋាន។ កាលបរិច្ឆេទនៃការមកដល់ និងបទដែលគេចោទប្រកាន់។

លោក លោកស្រីចៅក្រម នៅក្នុងចំណោមអ្នកទោស២៨រូបនេះ គឺ២១នាក់ គឺជាប្រជាជន១៧មេសា ប្រាំមួយនាក់គឺជាប្រជាជនមូលដ្ឋាន និងពីរនាក់ទៀត គឺជាកម្មាភិបាល។ គឺមន្ត្រី គឺជាកម្មាភិបាលពេទ្យស្ត្រីពីរនាក់។ អ្នកទោស១៨ គឺជាបុរស និង១១នាក់ជានារី។ ហេតុផលចំពោះការចាប់ឃុំឃាំងរួមមាន មនុស្សប្រាំមួយនាក់ត្រូវបានចាប់ឃុំ ដោយសារតែមានគម្រោងរត់ទៅវៀតណាម។ បួននាក់រិះគន់បដិវត្តន៍ មិនព្រមធ្វើការ ឬក៏មិនព្រមគោរពតាមមាគ៌ាបក្ស។ ពីរនាក់ទៀត ប្រព្រឹត្តអំពើសាហាយស្មន់។ ប្រាំពីររូបត្រូវបានគេចោទប្រកាន់ថាលួច ហើយនិងបីនាក់ទៀត គឺបទល្មើស គឺហិង្សា មន្ត្រីដែលមានបណ្ដាស័ក្ដិនៅក្នុងរបបមុន និងពីរត្រូវបានគេឆ្លើយតបដាក់ អ្នកទោសដទៃទៀតឆ្លើយដាក់។ ហើយមេភូមិមកពីស្រុក១០៨ ដែលបានចោទប្រកាន់ថាជាបណ្ដាញអង្គការរបស់យួន។ ហើយនៅក្នុងឯកសារនេះ អ្នកទោស១១នាក់ ក្នុងចំណោម២៨នាក់ ត្រូវបានគេកំណត់ថាជាអតីតទាហានរបប លន់ នល់ ហើយអ្នកដទៃទៀត ហើយម្នាក់ទៀតគឺលេខ១ នៅក្នុងបញ្ជីគឺជាកូនរបស់អតីតវរសេនីយ៍លន់ នល់ ដែលក្នុងបញ្ជីបានបញ្ជាក់ថា ត្រូវបានកម្ទេច។

[១១:២៣:៥៣]

លោក លោកស្រីចៅក្រម ក្រុមនៃឯកសារបន្ទាប់ដែលខ្ញុំនឹងបង្ហាញ គឺជាឧទាហរណ៍មួយចំនួនទាក់ទងទៅនឹងអ្នកដែលត្រូវបានគេចាប់ខ្លួន ដោយសារតែជំទាស់ ឬក៏រិះគន់បដិវត្តន៍។ ការជំទាស់ទៅលើបដិវត្តន៍របស់អង្គការ។ នៅក្នុងឯកសារ E3/4095 ដែលជាកំណត់ត្រា សៀវភៅកំណត់ត្រារបស់ក្រាំងតាចាន់ គឺមានលេខERN ភាសាខ្មែរ 00271131, ភាសាអង់គ្លេសមានលេខ 00747298 និង

បារាំងមានលេខ 00721271 ដល់ 72 គឺមានអតីតគ្រូបង្រៀនម្នាក់ឈ្មោះ ឡុង នោម ដែលត្រូវចាប់ខ្លួន ហើយបានឃុំខ្លួននៅក្រាំងតាចាន់។ ដោយសារតែគាត់ព្យាយាមធ្វើការជាក្រុមមនុស្ស ដើម្បីទាមទារឲ្យមានការបញ្ជូនត្រឡប់មកវិញនូវប្ដីប្រពន្ធ និងកូនរបស់អ្នកដែលបានបាត់ខ្លួន ហើយបានតវ៉ាអំពីកង្វះម្ហូបអាហារ ហើយនិងទាមទារឲ្យបើកសាលារៀនមកវិញ។

ហើយនៅក្នុងសៀវភៅដដែលនេះ ត្រង់ខ្មែរមានលេខ 00271113, បារាំងមានលេខ 00721 244 ដល់ 245, អង់គ្លេសមានលេខ 00747272 ដល់ 723។ គឺបានបង្ហាញអំពីអ្នកទោសម្នាក់ឈ្មោះ ខាត់ ភា ដែលជាផ្នែកនៃក្រុមមួយ ដែលពាក់អាំងស៊ីញ ឬក៏ពាក់មួយដែលមានរូបសម្ដេចឪ គឺសម្ដេចព្រះវររាជបិតានរោត្ដមសីហនុ ហើយនិងអ្នកទោសឈ្មោះ ហេង ងន ខ្មែរមានលេខ 00271130ៗ អង់គ្លេសមានលេខ 00747297 និងបារាំងមានលេខ 00721270។ ហេង ងន ត្រូវបានឃុំខ្លួននៅក្រាំងតាចាន់ ដោយសារតែគាត់សារភាពថា គាត់មិនចូលចិត្តបដិវត្តន៍បច្ចុប្បន្ន។

[១១:២៧:១២]

នៅក្នុងសៀវភៅកំណត់ត្រា E3/2107ៗ មានលេខ ERN ជាភាសាខ្មែរគឺ 00068062, អង់គ្លេសមានលេខ 00290226, បារាំងមានលេខ 00655742 បានកត់ត្រាអំពីការឃុំខ្លួនបុរសម្នាក់អាយុ៧៨ឆ្នាំ គឺអាយុ៧៨ឆ្នាំ ឈ្មោះ ចៅ ទិត។ គាត់ជាអតីតមន្ត្រីដែលកើតនៅវៀតណាម ហើយគេចោទប្រកាន់ថាគាត់បានរិះគន់បដិវត្តន៍។ ជាពិសេស ខ្ញុំសូមដកស្រង់៖ "គាត់និយាយថា បដិវត្តន៍អួតអាងថា វាគឺជាដែនដីរបស់ប្រជាជន ជាសិទ្ធិអំណាចរបស់ប្រជាជន ប៉ុន្តែតាមពិតទៅ គឺជារបស់អង្គការនោះទេ។ នៅពេលដែលធ្វើការបង្កាប់ឡើងវិញ គាត់និយាយថាគេមិនអនុញ្ញាតឲ្យហូបជាឯកជន ប៉ុន្តែនៅក្នុងវៀតណាម គឺមានដី មានផ្ទះ មានស្រូវ ហើយគេអនុញ្ញាតឲ្យធ្វើការជាឯកជន ប្រើប្រាស់លុយ មិនមែនដូចនៅទីនេះទេ"។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងឯកសារ D157.7 មានលេខ ERN ខ្មែរ 00270855, អង់គ្លេសមានលេខ 00866424 និងភាសាបារាំងមានលេខ 00872799។ គឺមានការបង្ហាញអំពីអ្នកទោសឈ្មោះ នៅ ម៉ុម គឺជាប្រជាជនថ្មី ដែលធ្វើការនៅក្នុងកងប្រមូលនារី គាត់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅក្រាំងតាចាន់ ដែលគាត់បាននិយាយដូចតទៅនេះ៖ "គាត់មិនអាចរស់នៅក្នុងសង្គមកខ្វក់បែបនេះទេ ដែលមានតែត្រកួន ហើយនិងស៊ុបល្ពៅ សម្លល្ពៅ មិនមានម្ហូបឆ្ងាញ់ៗហូប របបមិនប្រើប្រាស់លុយ ប្រជាជនពាក់ខោអាវតែមួយកំប្លេដែលមានក្លិនស្អុយគគ្រុក។ នៅពេលដែលយើងសួរគាត់អំពីអ្វីដែលគាត់បាននិយាយ គាត់បានឆ្លើយថា

គាត់មិនមានជំហររឹងមាំច្បាស់លាស់ឡើយ គាត់មិនចូលចិត្តបដិវត្តន៍"។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្ទាប់គឺ E3/2448។, ភាសាខ្មែរមានលេខ 00079102, អង់គ្លេសមានលេខ 0032 2157, បារាំងមានលេខ 00588784។ លោក លោកស្រីចៅក្រម ឯកសារនេះគឺជារបាយការណ៍មកពីឃុំត្រពាំងធំខាងជើងផ្ញើជូនអង្គការស្រុកចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ៧៧ ហើយបានរាយការណ៍អំពីយុវជនពីររូបដែលត្រូវបានឃុំខ្លួនដោយសារតែនិយាយថា "ខ្មែរក្រហមឈ្នះសង្គ្រាមដោយសារតែអាមេរិកបានឈប់ បញ្ឈប់ការទម្លាក់គ្រាប់បែក ហើយនិងដោយសារតែមានការតវ៉ារបស់សិស្សនិស្សិតនៅក្នុងសហគមន៍អន្តរជាតិ"។

[១១:៣១:៤១]

បញ្ជីឈ្មោះអ្នកទោសក្រាំងតាចាន់គឺ E3/4083។, ខ្មែរមានលេខ 00068036, អង់គ្លេសមានលេខ 00323975, បារាំងមានលេខ 00778877។ បញ្ជីអ្នកទោសនេះបានបង្ហាញអ្នកទោសស្ត្រីចំនួនបួនរូបគឺលេខ ២៤ ដល់ លេខ២៧ នៅក្នុងបញ្ជី ដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់ដោយសារតែការចោទប្រកាន់ដូចខាងក្រោម៖ "ស្ត្រីក្បត់ទាំងបួននាក់នេះ បានធ្វើឲ្យបាក់ស្លាបព្រារបស់សហករណ៍ដើម្បីបំផ្លាញសហករណ៍ ហើយនិងឲ្យកែប្រែទៅជាឯកជនឡើងវិញ"។ សូមបញ្ចប់ការដកស្រង់។

លោកប្រធាន ខ្ញុំសូមបញ្ចប់នូវផ្នែកមួយនេះ ហើយខ្ញុំនៅសល់ការដកស្រង់មួយទាក់ទងទៅនឹងប្រធានបទនេះ គឺជារបាយការណ៍របស់ ហង់រី ឡូកា ដែលសហការីរបស់ខ្ញុំបានបង្ហាញរួចមកហើយនៅពេលព្រឹកនេះ។ ដូច្នេះគឺឯកសារគឺ D313/1.2.16, ខ្មែរមានលេខ 00739046, អង់គ្លេសមានលេខ 00217701 និងបារាំងមានលេខ 00743760។ ហើយ ហង់រី ឡូកា បានសរសេរនៅក្នុងផ្នែកនេះពាក់ព័ន្ធទៅនឹងការចោទប្រកាន់ចំពោះមនុស្សដែលត្រូវបានគេបញ្ជូនមកក្រាំងតាចាន់ ខ្ញុំសូមដកស្រង់៖ "ជារួមគឺថាមានកង្វះអាហារ មានភាពធ្ងន់ធ្ងរ ប៉ុន្តែភាគច្រើនគឺដោយសារតែហេតុផលនយោបាយប្រឆាំងនឹងរបប ភាគច្រើននៃជនជាប់ចោទ បានបង្ហាញអំពីការមិនពេញចិត្តនឹងសង្គមបដិវត្តន៍" ហើយគាត់បាននិយាយថា៖ "ក្នុងចំណោមកំណត់ត្រា៤៧៧ ដែលគាត់បានមើលគឺថាមានតែអ្នកទោសបីនាក់ប៉ុណ្ណោះដែលត្រូវបានគេបញ្ជូនត្រឡប់ទៅវិញ"។ សូមបញ្ចប់ការដកស្រង់។

ខ្ញុំត្រូវបន្តទៅប្រធានបទថ្មី ប៉ុន្តែខ្ញុំសូមអនុញ្ញាតលោកប្រធាន ថាតើយ៉ាងដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:៣៥:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានសំណើមួយដើម្បីឲ្យអង្គជំនុំជម្រះក្នុងពេលសម្រាកធ្វើការពិនិត្យ ក៏ដូចជាដើម្បីឲ្យអ្នកទាំងអស់គ្នាមានគំនិតពិចារណាក្នុងពេល -- យើងពិនិត្យមើលទៅលើកាលវិភាគដែលយើងកែប្រែថ្មី។ ខ្ញុំគិតថាវាជាការល្អ ដែលយើងគួរតែមានការជំទាស់ ឬក៏យើងថាលើកយកការជំទាស់ឬក៏ការតវ៉ាទៅថ្ងៃព្រហស្បតិ៍ ដោយមិនមែននៅថ្ងៃពុធនោះទេ ដើម្បីឲ្យយើងអាចធ្វើបានល្អប្រសើរជាងបច្ចុប្បន្ននេះ ឬដើម្បីឲ្យយើងមានពេលនៅថ្ងៃនេះ និងថ្ងៃស្អែក ដើម្បីរៀបចំ ព្រោះថាយើងដឹងទាំងអស់អត់មានកាលវិភាគសម្រាប់សាក្សីនៅថ្ងៃព្រហស្បតិ៍ទេ។ ដូច្នេះ ខ្ញុំគិតថាវាជាការល្អដែលយើងលើកយកការជំទាស់ទៅថ្ងៃព្រហស្បតិ៍ ហើយថ្ងៃពុធ យើងអាចរៀបចំធ្វើការត្រៀម។ ដូច្នេះ ខ្ញុំសូមអនុញ្ញាត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកចង់លើកយកបញ្ហាមួយចំនួន ហើយបញ្ហាមួយចំនួនបានកំណត់រួចទៅហើយ។ ប៉ុន្តែប្រសិនបើលោកលើកយកនៅថ្ងៃព្រហស្បតិ៍ ចុះភាគីដទៃទៀតរៀបចំយ៉ាងដូចម្តេច?

[១១:៣៦:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

យើងធ្វើបទបង្ហាញនៅថ្ងៃស្អែក ហើយពួកគេអាចលើកឡើងនៅថ្ងៃព្រហស្បតិ៍តើ ហើយយើងថានៅថ្ងៃព្រហស្បតិ៍យើងឆ្លើយតបទៅនឹងពួកគេ។ មានន័យថា យើងមានពេលវេលាទំនេរមួយថ្ងៃបន្ថែម គឺភាគីទាំងអស់មានពេលវេលាមួយថ្ងៃដើម្បីលើកយកមតិយោបល់ទាក់ទងទៅនឹងបទបង្ហាញនៅថ្ងៃនេះ។ ព្រោះថានៅថ្ងៃស្អែក យើងនឹងមានបទបង្ហាញ ហើយព្រះរាជអាជ្ញានឹងតបនៅថ្ងៃស្អែក ហើយព្រះរាជអាជ្ញានិងដើមបណ្តឹងតប។ ដូច្នេះយើងគួរតែមាន -- ពេលនេះគឺជាការស្នើរបស់យើងតែប៉ុណ្ណោះ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមលើកដោយសង្ខេប ខ្ញុំមិនមានបញ្ហាទេ ទោះបីថ្ងៃពុធ ថ្ងៃព្រហស្បតិ៍ អាហ្នឹងស្រេចទៅលើឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះអាចសម្រេចថាថ្ងៃពុធ ឬថ្ងៃព្រហស្បតិ៍ក៏បានដែរ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខាងយើងក៏មិនមានបញ្ហាដែរ ថ្ងៃពុធក៏បាន ថ្ងៃព្រហស្បតិ៍ក៏បាន ក៏ប៉ុន្តែខ្ញុំមានសំណើតូចមួយដើម្បីយល់អំពីការរៀបចំសវនាការនេះ។ តើភាគីអាចមានឱកាសក្នុងការឆ្លើយតបទៅនឹងការលើកឡើងរបស់ភាគីបដិបក្ខដែរឬក៏អត់? ឧទាហរណ៍នៅពេលដែលខាងភាគីការពារក្តីគាត់ឆ្លើយតបមកយើង យើងមានឱកាសក្នុងការឆ្លើយតបទៅនឹងការឆ្លើយតបរបស់ខាងមេធាវីការពារក្តីដែរឬអត់? អ៊ីចឹងខ្ញុំចង់ដឹងចំណុចនេះ ដើម្បីឲ្យយើងរៀបចំចម្លើយរបស់យើងទៅនឹងការបង្ហាញឯកសាររបស់ភាគីផ្សេងៗ។

[១១:៣៨:១២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំនៅតែមិនប្រាកដថាតើលោកចង់ធ្វើអ្វីនៅថ្ងៃព្រហស្បតិ៍? លោកហាក់ដូចជាបញ្ជាក់ថានៅពេលដែលមានការឆ្លើយតបនឹងការដាក់ចម្លើយតប គឺវាកើតបន្តបន្ទាប់គ្នា តើវាអ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាគ្រាន់តែលើកអ្វីដែលយើងគ្រោងធ្វើនៅថ្ងៃពុធ ទៅថ្ងៃព្រហស្បតិ៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកអត់ចង់ឲ្យមានសវនាការថ្ងៃពុធ និងមានថ្ងៃព្រហស្បតិ៍ អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ។

[១១:៣៨:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយមុននឹងសម្រាកថ្ងៃត្រង់នេះ អង្គជំនុំជម្រះសូមជម្រាបជូនភាគីពាក់ព័ន្ធឲ្យដាក់សារណាតបជាលាយលក្ខណ៍អក្សរទៅនឹងសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ឯកសារ E348 ដែលបានសុំឲ្យមានការសួរតទល់គ្នា រវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សីស្រី ថន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង យ៉ាងយូរបំផុត ត្រឹមថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៥។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំ បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ភាគីកាលពីព្រឹកមិញ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ដែលបានស្នើសុំកំណត់កាលបរិច្ឆេទសវនាការ សម្រាប់យោបល់ឆ្លើយតបទៅនឹង ទៅលើការបង្ហាញឯកសារគន្លឹះដែលត្រូវកំណត់ធ្វើសវនាការនៅថ្ងៃពុធ ទី២៩ ខែមេសា ដែលប្តូរទៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា វិញ។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា ពេលវេលាដែលបានបែងចែកឲ្យភាគី ត្រូវបានរក្សាទុកដដែល។ អង្គជំនុំជម្រះនឹងមិនបន្ថែមពេលវេលាតាមសំណើសុំរបស់ភាគីណាមួយឡើយ ហើយភាគីទាំងអស់នឹងមានឱកាសក្នុងការធ្វើការឆ្លើយតបក្នុងអំឡុងពេលសវនាការ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលខាងមុខ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

[១៣:៣៤:៣៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះខ្ញុំសូមបង្ហាញឯកសារមួយចំនួនតូចពាក់ព័ន្ធទៅនឹងមនុស្សដែលត្រូវគេចាប់ខ្លួនដោយសារតែមានការត្អូញត្អែរអំពីកង្វះចំណីអាហារ ឬលក្ខខណ្ឌការងារ ឬក៏

ស្ថានភាពផ្សេងទៀតនៅក្នុងស្រុកត្រាំកក់។ សៀវភៅកំណត់ហេតុក្រាំងតាចាន់ គឺE3/4095 ដែលមានលេខ ERN ជាភាសាខ្មែរ 00271123, ភាសាបារាំង 00721260 ដល់ 61 និង ERN ជាភាសាអង់គ្លេស 00747287។ នេះគឺជាកំណត់ត្រានិយាយអំពីបុរសក្មេងម្នាក់ឈ្មោះ យ៉ាង កែវ កើតនៅភូមិត្រពាំងធំខាងជើង ក៏ត្រូវបានឈ្មោះ -- ដោយសារគាត់បានមានការពេញចិត្តនឹងរបបមុន។ សូមដកស្រង់ដូចតទៅ៖ "សម្រាប់របបអាហារប្រចាំថ្ងៃ គឺថាយើងដូចទាសករអ៊ីចឹង គឺថាយើងហូបបបរតែមួយពេលទេក្នុងមួយថ្ងៃ ហើយពេលខ្លះ គ្មានទាំងប្រហុក និងអំបិលទៀតផង។ យើងមិនមានកម្លាំងធ្វើការទេ"។ បញ្ចប់ការដកស្រង់។ ហើយនៅក្នុងសៀវភៅកត់ត្រារបស់មន្ទីរសន្តិសុខ ថាតើបុរសដែលមានអាយុ៦០ឆ្នាំហ្នឹង ត្រូវបានគេសួរចម្លើយដោយគេប្រើប្រាស់វិធីក្តៅ ដើម្បីជីកកកាយរកបណ្តាញរបស់គាត់ ប៉ុន្តែគាត់បានបដិសេធមិនព្រមឆ្លើយសារភាព"។ បញ្ចប់ការដកស្រង់។

[១៣:៣៦:៥១]

ឯកសារ E3/2477 ត្រង់ERN ជាភាសាខ្មែរ 00270733 ដល់34, អង់គ្លេស 00355474 និងបារាំង 00632162។ នេះគឺជារបាយការណ៍មួយមកពីឃុំលាយបូរដែលកំណត់សញ្ញាណយុវជនម្នាក់ដែលបាននិយាយតវ៉ាចំពោះការខ្វះ -- និយាយត្អូញត្អែរថាមិនមានម្ហូបអាហារគ្រប់គ្រាន់។ សូមដកស្រង់៖ "យើងមិនមានចំណីអាហារ ឬក៏មិនមានដំឡូងអីត្រូវហូបនោះទេ"។ គាត់បាននិយាយត្អូញត្អែរថានៅក្នុងរបបចាស់ យើងអាចហូបអីក៏បាន ឲ្យតែអ្នកចង់ ប៉ុន្តែឥឡូវនេះមិនមានអ្វីហូបទេ។ ហើយនៅក្នុងរបាយការណ៍ក៏គាត់បាននិយាយផងដែរថា សូមដកស្រង់ "នៅពេលនេះ គឺថាគាត់មិនចង់រស់តទៅទៀតទេ ស៊ូស្លាប់ប្រសើរជាង"។ ហើយនៅក្នុងរបាយការណ៍មកពីឃុំលាយបូរនេះផងដែរក៏សរសេរ សូមដកស្រង់៖ "ភី អេស បុគ្គលនេះគឺឈ្មោះ យួន – សូមបន្ថែមគឺបុគ្គលនេះ គឺជាយួន" ហើយនិងបញ្ចប់នៃរបាយការណ៍នេះ មានចំណារសរសេរដោយដៃឈ្មោះ គិត ដែលជាចៅហ្វាយស្រុក សរសេរនៅថ្ងៃទី៦ ខែកញ្ញា ពីរថ្ងៃក្រោយរបាយការណ៍ ដែល គិត ណែនាំឲ្យមេគុកក្រាំងតាចាន់ ឈ្មោះ អាន់ ធ្វើការសួរចម្លើយឲ្យបានហ្មត់ចត់ ដោយសារ សូមដកស្រង់ "គាត់គឺជាខ្សែរយៈ សេ.អ៊ី.អា ដែលមានការចាត់តាំងត្រឹមត្រូវ"។ បញ្ចប់ការដកស្រង់។

[១៣:៣៨:៤១]

ឯកសារ E3/2453 ត្រង់ERN ជាភាសាខ្មែរ 00270780 ដល់ 81, អង់គ្លេស 00388583 និងភាសាបារាំង 00611773។ នេះគឺជារបាយការណ៍នៃឃុំញ៉ែងញ៉ង ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៧

ដែលរាយការណ៍អំពីស្ត្រីបួននាក់ ដែលពីរនាក់គឺជាប្រពន្ធរបស់ទាហាន ហើយម្នាក់ទៀត ប្ដីគឺថារស់នៅក្នុងទឹកដីយួន ហើយអ្នកផ្សេងទៀត គឺថាប្តីត្រូវកម្ទេចអស់ហើយ។ មូលហេតុដែលស្ត្រីទាំងបួននាក់នេះត្រូវបានរាយការណ៍នេះ គឺដោយសារពួកគេបាននិយាយដូចតទៅ សូមដកស្រង់៖ “អ្នកទាំងបួននាក់នេះគឺថាគ្រាន់តែនិយាយថា ប្រកាសថាសង្គមនិយមគឺអស្ចារ្យ ប៉ុន្តែគ្មានសង្គមនិយមគឺអស្ចារ្យ ប៉ុន្តែគ្មានអ្វីសោះគឺមានតែហូបតែបបររាល់ព្រឹក រាល់ល្ងាច។ តើបដិវត្តន៍ហ្នឹង ជាបដិវត្តន៍ស្អីរបស់គេ? យើងមិនអាចរកអ្វីទៅហូបបាននោះទេ។ មិនមែនដូចកាលពីសង្គមចាស់នោះទេ សង្គមចាស់គឺយើងសប្បាយណាស់ ប្រសិនបើអ្នកចង់ហូបគុយទាវ ឬក៏នំប៉ុង គឺថាមានបរិបូណ៌ទាំងអស់ មិនដូចអ្វីដែលគេហៅថាបដិវត្តន៍របស់ពួកគេស្អីនោះទេ។ ហើយយើងគឺថាគេបញ្ចាំងកុន គេបញ្ចាំងខ្សែភាពយន្តចិនឲ្យយើងមើលហើយនេះ គឺមិនមែនដូចបដិវត្តន៍ដែលគេថានោះទេ”។

ឯកសារនៅក្រាំងតាចាន់ សៀវភៅកត់ត្រា E3/4083 ត្រង់ ERN ជាភាសាខ្មែរ 00068036, អង់គ្លេស 00323976 និងភាសាបារាំង 00778877 ដែលមានបញ្ជីអ្នកទោសចំនួន ២៩នាក់។ អ្នកទោសលេខរៀង២៨ នៅក្នុងបញ្ជីនេះ ជាបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅក្រាំងតាចាន់ ដោយសារតែគាត់ត្អូញត្អែរ គឺថាគ្មានអ្វីហូប គឺមានតែបបររាវៗតែប៉ុណ្ណោះ។

[១៣:៤១:៤៦]

លោក លោកស្រីចៅក្រមឯកសារបន្ទាប់ដែលយើងខ្ញុំសូមបង្ហាញផងដែរ ពាក់ព័ន្ធទៅនឹងប្រជាជនដែលត្រូវបានចាប់ខ្លួន ដែលព្យាយាមរត់គេចខ្លួន ឬគេចខ្លួនចេញពីកង -- ព្យាយាមរត់ចេញពីរបបកម្ពុជាប្រជាធិបតេយ្យឆ្លងកាត់ព្រំដែនចូលទៅប្រទេសថៃ ឬក៏ចូលទៅក្នុងប្រទេសវៀតណាម និងប្រជាជនដែលដើរហើរសេរី។ សៀវភៅកត់ត្រានៅគុកក្រាំងតាចាន់ E3/4083, ត្រង់ ERN ជាភាសាខ្មែរដូចដែលខ្ញុំទើបតែបញ្ចោអម្បាញ់មិញ គឺជាភាសាខ្មែរ 00068036, អង់គ្លេស 00323973 ដល់ 76, បារាំង 00778875 ដល់ 77។ នេះ គឺបញ្ជីអ្នកទោសដែលមានចំនួន២៩នាក់ដដែល អ្នកទោស២០នាក់ក្នុងចំណោមអ្នកទោសទាំង២៩នាក់ ត្រូវបានគេរៀបរាប់ថាជាខ្សែបណ្ដាញរបស់ពួកក្បត់២០នាក់ ដែលទោសរបស់គេគឺមានដូចតទៅ សូមដកស្រង់៖ “មានផែនការរត់គេទៅយួននិងសៀម ទៅប្រទេសថៃ”។

នៅក្នុងសៀវភៅកត់ត្រាគុកក្រាំងតាចាន់ E3/4095ៗ ត្រង់ ERN ជាភាសាខ្មែរ 00271095, បារាំង 00721215 ដល់ 16, អង់គ្លេស 00747245 ដល់ 46។ សៀវភៅកំណត់ត្រានេះ គឺនិយាយអំពីអ្នកទោសម្នាក់ឈ្មោះ ង៉ែត ភឿន សូមដកស្រង់ដូចតទៅ៖ “កំហុសទី១ គឺវាសេរីពេក ដើរចោលកង

និងទៅលេងនៅផ្ទះបងប្អូននៅឃុំពពេល។ កំហុសទី២ គឺថាវាសេរីហួសហេតុ ទៅលេងសាច់ញាតិ -- នៅផ្ទះសាច់ញាតិ។ ទី៣ វាដើរសេរី ដែលផ្ទុយទៅនឹងវិន័យ ហើយបន្ទាប់មកក៏រត់គេចខ្លួនមិនប៉ានវិលត្រឡប់មកកងរបស់វាវិញទេ”។

[១៣:៤៤:៣៥]

ឯកសារបន្ទាប់ គឺឯកសារ E3/2451 ត្រង់ ERN ជាភាសាខ្មែរ 00271005 ដល់ 06, អង់គ្លេស 00322172, បារាំង 00612447។ នេះ គឺជារបាយការណ៍ចុះថ្ងៃទី៦ តុលា ១៩៧៧ មកពីគណៈស្រុក ១០៥ ឈ្មោះ គិត គឺគោរពបក្សជាទីគោរព ស្នើសុំសេចក្ដីសម្រេចទាក់ទងទៅនឹងយោធិននារីដែលបាន -- ត្រូវបានឃុំខ្លួនបណ្ដោះអាសន្នដោយសារតែដើរសេរីមិនមានច្បាប់ និងពាក់ព័ន្ធនៅក្នុងអត្តចរិតមួយដែលមិនសមស្រប មានអត្តចរិកសមស្របចំពោះគណកម្មាធិការឃុំ។ របាយការណ៍របស់គេគឺមានចម្លើយតបសរសេរដោយដៃ សូមដកស្រង់៖ “សមមិត្តនារីនេះគឺជាខ្លាំង ស្នើសុំឲ្យសួរចម្លើយវាភ្លាមៗដើម្បីរកបណ្ដាញរបស់វា ហើយស្នើសុំឲ្យនគរបាលយើងធ្វើការសួរចម្លើយភ្លាមៗឲ្យបានហ្មត់ចត់”។

ឯកសារមួយទៀតគឺ E3/4164។ ឯកសារដែលខ្ញុំបានលើកឡើងពីខាងដើមគឺជាបញ្ជីរបស់អ្នកទោសនិយាយ មានចំណងជើងថា“ប្រវត្តិរូបសង្ខេបរបស់អ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់” ដែលនិយាយអំពីបទល្មើសរបស់អ្នកទោសទាំងនេះ។ អ្នកទោសទី១នៅក្នុងបញ្ជីនេះគឺមានហេតុផលទាំងស្រុងដែលសុំលើកឡើងថាហេតុអ្វីបានជាគាត់ -- គេត្រូវបានឃុំឃាំងខ្លួននៅគុកក្រាំងតាចាន់។ ដកស្រង់៖ “បុគ្គលនេះគឺថាមាន គឺថាមានស្មារតី មានជំហរសេរី មិនគោរពវិន័យរបស់អង្គការ”។ ហើយបញ្ជីសម្លាប់អ្នកទោសនៅក្រាំងតាចាន់ដែលប្រព្រឹត្តកំហុសតូចតាច គឺឯកសារ E3/4145។ ត្រង់ERN ជាភាសាខ្មែរ 00068737, អង់គ្លេស 00762845 ដល់ 46 និងភាសាបារាំង 00761101 ដល់ 02។ នេះគឺជាចំណែកមួយនៃបញ្ជីអ្នកទោសដែលមានចំនួន ៣៧នាក់ ដែលក្នុងនោះរួមមានឈ្មោះ អាយុ ឃុំ ស្រុក មុខងារ និងឋានៈ ហើយមានចំណារនៅលើបញ្ជីចុះថ្ងៃទី២២ ខែឧសភា ១៩៧៧ ដែលនិយាយដូចតទៅ សូមដកស្រង់៖ “មនុស្សទាំង៣៧នាក់នេះ ទាំងក្មេង ទាំងចាស់ គឺថាមានឈ្មោះនៅក្នុងបញ្ជីនេះត្រូវបានបោសសម្អាតរួចហើយ”។

[១៣:៤៨:២០]

លោក លោកស្រីចៅក្រម លេខរៀងទី៣៥ នៅលើបញ្ជីអ្នកទោសដែលសម្លាប់នេះ មានអ្នកទោសម្នាក់ឈ្មោះ ហ៊ឹម ឈុន ដែលមានអាយុ៣៧ឆ្នាំ មកពីស្រុកទ្រាំង បុគ្គលនេះត្រូវបានរាយការណ៍

ជូនអង្គការនៅថ្ងៃទី៥ ខែឧសភា ១៩៧៧ ប្រហែលជាពីរសប្តាហ៍មុននឹងគេត្រូវបានសម្លាប់ចោល។ គឺឯកសារE3/2048។ ឯកសារ E3/2048 ត្រង់ERN ជាភាសាខ្មែរ 00079095, អង់គ្លេស 00276566 ដល់ 67, បារាំង 00611664។ របាយការណ៍ដែលចុះថ្ងៃទី៥ ឧសភា ១៩៧៧ និយាយថា ហ៊ឹម ឈុន គឺជាឈ្មួញកណ្តាល អតីតឈ្មួញកណ្តាល ជាអ្នកដែលមានម៉ាស៊ីនកិនស្រូវមួយដែលបានចាកចេញពីឃុំពពេល ធ្វើដំណើរទៅជួបជីដូនរបស់គេដោយមិនមានលិខិតធ្វើដំណើរ ហើយត្រូវបានចាប់ខ្លួនដោយឈ្លបឃុំលាយបូរ គឺឯកសារ E3/4145 ដែលត្រូវបានសម្លាប់នៅក្រាំងតាចាន់ពីរសប្តាហ៍ក្រោយមក គឺនៅថ្ងៃទី២២ ខែឧសភា ១៩៧៧។ ពីរថ្ងៃក្រោយពេលចាប់ខ្លួន ដោយសារតែគេដើរហើរសេរី មិនមានលិខិតអនុញ្ញាតច្បាប់។

បញ្ជីអ្នកទោសដែលគេសម្លាប់មួយទៀតនៅគុកក្រាំងតាចាន់ ចុះថ្ងៃ២២ ឧសភា ១៩៧៧ គឺអ្នកទោសលេខរៀង៣៣ នៅលើបញ្ជីអ្នកទោសដែលប្រហារជីវិត គឺឯកសារ E3/4145 មានអាយុ២៩ឆ្នាំ មានឈ្មោះ ថាច់ វណ្ណា។ លោក ថាច់ វណ្ណា គឺជាខ្មែរក្រោមម្នាក់ដែលមាននៅក្នុងបញ្ជីរបស់ប្រជាជនខ្មែរក្រោមមកពីឃុំត្រពាំងធំខាងជើង ចុះថ្ងៃទី៤ ឧសភា ១៩៧៧ ដែលសហការីរបស់ខ្ញុំបានបង្ហាញជូនកាលពីព្រឹកមិញ គឺឯកសារ E3/2281។ ថាច់ វណ្ណា ស្ថិតនៅត្រង់លេខរៀង៤៤ នៃបញ្ជីដែលក្រុមគ្រួសារខ្មែរក្រោមដែលមាន៧៣គ្រួសារ មកពីត្រពាំងធំខាងជើង ដែលត្រូវកំណត់ថាមានអាយុ២៩ឆ្នាំ និងជាកម្មករជួសជុលម៉ូតូ។ ពីរសប្តាហ៍ក្រោយពីគាត់មានឈ្មោះនៅលើបញ្ជី គាត់ត្រូវបានសម្លាប់ចោលនៅគុកក្រាំងតាចាន់។

[១៣:៥១:៤៩]

ប្រធានបទមួយទៀត ដូចដែលអង្គជំនុំជម្រះបានឃើញជាច្រើនរួចមកហើយ គឺលិខិតឆ្នាំ១៩៧៨ មកពី តាសាន ដែលចៅហ្វាយស្រុកបញ្ជាឲ្យសម្លាប់ក្មេងៗ បើសិនណាបេះមិនចេញពីម្តាយ។ ឥឡូវខ្ញុំមិនត្រឡប់ទៅនិយាយហ្នឹងទេ ខ្ញុំគ្រាន់តែបង្ហាញនូវឧទាហរណ៍មួយចំនួនចេញពីឯកសារបន្ថែម ដែលផ្តុះបញ្ចាំងអំពីការចាប់ខ្លួន និងការឃុំឃាំងទាំងមនុស្ស ទាំងក្មេង ទាំងចាស់។ ឯកសារ D157.36 មានរបាយការណ៍ពីរមកពីប្រធានគុកនៅអង្គរកា ឈ្មោះ ម៉េង ផ្ញើជូនអង្គការ ចុះថ្ងៃទៅ២៣, ២៤ ខែមីនា ១៩៧៧ ទាក់ទងទៅនឹងការចាប់ខ្លួន ការសួរចម្លើយ និងចម្លើយសារភាពកុមារាម្នាក់ អាយុ10ឆ្នាំ ឈ្មោះ រ៉ា ដែលបទល្មើសនៃការចោទប្រកាន់នេះ គឺដោយសារតែថាគេព្យាយាមរត់ចេញពីក្រុមនោះ។ ហើយនៅក្នុងការឆ្លើយតបទៅនឹងរបាយការណ៍របស់ ម៉េង ហ្នឹង ចុះថ្ងៃទី២៨ មីនា ១៩៧៧ បន្ទាប់មក គិត

ដែលជាចៅហ្វាយស្រុកនោះបានណែនាំឲ្យមេគុកក្រាំងតាចាន់ឈ្មោះ អាន់ សួរចម្លើយគិញនេះឲ្យបានលម្អិត។

នៅក្នុងសៀវភៅកំណត់ត្រាគុកក្រាំងតាចាន់ E3/4095 ត្រង់ ERN ភាសាខ្មែរ 00271129, បារាំង 00721268, អង់គ្លេស 00747295។ សៀវភៅកំណត់ត្រានេះពាក់ព័ន្ធទៅនឹងអ្នកទោសម្នាក់ដែលមានអាយុ១៣ឆ្នាំ ឈ្មោះ កុក ឡេង ដែលឪពុកម្ដាយរបស់គេបានស្លាប់ទៅហើយ ហើយកុមារនេះត្រូវបានចាប់ខ្លួន ដោយសារតែគេព្យាយាមរត់គេចចេញ ដើម្បីស្វែងរកបងប្អូនរបស់គេ។

[១៣:៥៣:៥២]

សៀវភៅកត់ត្រានៅគុកក្រាំងតាចាន់ គឺE3/2107, ខ្មែរ 00068053, អង់គ្លេស 00290211, បារាំង 00655730។ សៀវភៅកំណត់ត្រានេះក៏បានកត់ត្រាការឃុំខ្លួន និងការសួរចម្លើយកុមារម្នាក់អាយុ១៣ឆ្នាំ ឈ្មោះ ង៉ែត ណែល ជាកូនរបស់វរៈសេនីយ៍ឯករបបលន់នល់ ម្នាក់ដែលត្រូវបានចាប់ខ្លួនដោយសារតែលួចដូង និងឪឡឹកយកទៅស៊ី។ ហើយបញ្ជីអ្នកទោសក្រាំងតាចាន់មួយទៀត គឺឯកសារ E3/4083, ខ្មែរ 00068036, អង់គ្លេស 00323976, បារាំង 00778877 គឺឯកសារ E3/4083។ អ្នកទោសរូបនេះ គឺស្ថិតនៅត្រង់លេខរៀង២៩ គឺអ្នកទោសម្នាក់ដែលមានលេខរៀង២៩ អាយុ៧៣ឆ្នាំ ឈ្មោះ សួង រដ្ឋ គឺជាអតីតប្រធានភូមិមកពីឃុំស្រែរនោង ត្រូវបានចោទប្រកាន់ថាលួចចំណីអាហារ។

ខ្ញុំសូមបង្ហាញឯកសារមួយចំនួនតូចទៀត ទាក់ទងទៅនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិកជន។ ឯកសារ D157.69 គឺជារបាយការណ៍ចុះថ្ងៃទី៣១ ខែសីហា ១៩៧៧ មកពី K105 – គឺមកពី ក១០៥ គឺមន្ទីរយោធាស្រុក ផ្ញើជូនអង្គការរាយការណ៍ ពីសេចក្ដីសម្រេចឲ្យចាប់ខ្លួនឈ្មោះ ភុំ អឿន។ រឿងហេតុផលដែលចាប់ខ្លួននេះគឺ ដូចតទៅនេះ សូមដកស្រង់៖ “អង្គការនិយាយថាគេបំបាត់តែពួកមូលធននិយម និងពួកទាហានទេ ក៏ប៉ុន្តែនៅពេលនេះគឺថាគ្មានព្រះពុទ្ធសាសនា គ្មានព្រះសង្ឃ គ្មានសាលា គ្មានគ្រូបង្រៀន ឬគ្មានផ្សារទេ វាជាការប្រសើរសិន ប្រសិនណាជាអង្គការអនុញ្ញាតឲ្យមានព្រះពុទ្ធសាសនា មានព្រះសង្ឃ មានសាលារៀន និងមានគ្រូបង្រៀនវិញនោះ”។ សូមបញ្ចប់ការដកស្រង់។

[១៣:៥៦:៣៣]

សៀវភៅកត់ត្រាមួយទៀត គឺឯកសារ E3/4095, ERN ជាភាសាខ្មែរ 00271117, បារាំង 00721250 ដល់ 51, អង់គ្លេស 00747277 ដល់ 78 គឺនិយាយអំពីអ្នកទោសពីរនាក់ ឈ្មោះ គឹម ង៉ិល និង ស៊ុំ សារ៉េត ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅគុកក្រាំងតាចាន់ ដោយសារចូលរួមជាមួយនឹង

ខ្មែរបក្សខ្មែរ-ស ដែលៗបក្សខ្មែរ-ស សម្រាប់ចលនារំដោះព្រះពុទ្ធសាសនា។ គឺឯកសារមួយទៀតគឺ E3/2818 ដែលមាន ERN 00 -- នៅក្នុងសៀវភៅនេះ អ៊ា ម៉េងទ្រី បានយោងទៅលើប្អូនស្រីរបស់តាម៉ុក គឺត្រង់ ERN ជាភាសាអង់គ្លេស 00416409 សូមដកស្រង់៖ "ព្រះពុទ្ធសាសនិកជនខ្លះ ជឿជាក់ថាការកម្ទេចព្រះពុទ្ធសាសនា ឬរូបសំណាកព្រះពុទ្ធគឺជាបាបកម្មមួយហើយ។ កូនស្រីរបស់ តាម៉ុក ឈ្មោះ ខុម ឆ្កួតដោយសារតែគេបានបញ្ជាឲ្យកម្ទេចវត្តអារាម ហើយនិងរូបសំណាកព្រះពុទ្ធ"។

ឥឡូវនេះ ប្រធានបទចុងក្រោយបំផុតរបស់ខ្ញុំ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិអំណាចនីតិវិធីក្នុងការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់អ្នកទោស។ ហើយនេះគឺជារបាយការណ៍មកពីស្រុកត្រាំកក់ នៅផ្នែកទី៤ នៃរបាយការណ៍នេះ គឺឯកសារដែលសហការីរបស់ខ្ញុំបានបង្ហាញពីខាងដើមហើយ គឺ E3/-- គឺខ្មែរ គឺ 00739070, អង់គ្លេស 00217718 និងបារាំង 007--។ សូមដកស្រង់៖ "ការពិតនោះគឺការស្លាប់ដោយសារការសម្លាប់ដោយការសងសឹកប្រឆាំងជាមួយនឹងប្រជាជនថ្មី គឺបានមកពីសាក្សីមកជាច្រើន។ ការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានផែនការ ហើយកាវិយាធិបតេយ្យរបស់ខ្មែរក្រហមពាក់ព័ន្ធទៅនឹងការបន្សុទ្ធសង្គមខ្មែរ ហើយវាស្រដៀងគ្នាទៅនឹងរបបណាហ្ស៊ី ឬក៏របបស្តាលីន ដែលកាវិយាធិបតេយ្យនិងការសម្លាប់ គឺដើម្បីឲ្យគេមានភាពឆន្ទៈស្មោះត្រង់ចំពោះបក្ស។ គេពិចារណាថា គឺគេត្រូវតែគោរពតាមបញ្ជារបស់បក្សទាំងស្រុង។ កម្មាភិបាលគឺប្រមូលព័ត៌មាន និងផ្លាស់ប្តូរព័ត៌មានធ្វើការចាប់ខ្លួន សួរចម្លើយ និងបញ្ជូនខ្លួនអ្នកដែលគេបានចាប់ខ្លួន។ អ្នកដែលត្រូវគេចោទប្រកាន់ត្រូវបានគេយកទៅសួរចម្លើយ។ ក្រោយពីគេសរសេររបាយការណ៍នោះមក គឺគេនឹងបញ្ជូនរបាយការណ៍នោះទៅថ្នាក់លើ"។ បញ្ចប់ការដកស្រង់។

[១៤:០០:៣៤]

លោក លោកស្រីចៅក្រម ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវវីដេអូឃ្លីប ហើយហៅថា *"ឌីគិន អូហ្វដេថ"*។ គឺE3/3126R – ឯកសារ E3/3126R។ ខ្សែវីដេអូនេះ និយាយអំពីពួកក្បត់ដែលត្រូវគេស្វែងរកចាប់ខ្លួន គឺពួកក្បត់នឹងខ្មែរក្រហមឈ្មោះ ការ៉ូប៊ី ដោយអ្នកថ្មីម្នាក់ឈ្មោះ សុខ ជា ដែលរស់នៅឃុំតាភេមគឺស្រុកត្រាំកក់នៅក្នុងរបបខ្មែរក្រហម ហើយសមាជិកគ្រួសាររបស់គាត់ត្រូវបានសម្លាប់ចោលនៅទីនោះ។ ការ៉ូប៊ី នេះ គេជាប្រធាន -- ដែលត្រូវបានប្រធានសន្តិសុខនៅតាភេម តាពី គឺនៅឃុំ ប្រធានឃុំតាភេមដាក់ថាកំណត់អត្តសញ្ញាណនៅក្នុងការសម្ភាសរបស់គណៈកម្មាធិការឃុំត្រពាំងធំ គឺឯកសារ E3/5519 ត្រង់ចម្លើយលេខ៥។ ការ៉ូប៊ី ក៏ត្រូវបានកំណត់ថា ពាក់ព័ន្ធជាមួយនឹង កែវ ច័ន្ទតារ៉ា ដែលជាកម្មាភិបាល

ម្នាក់ត្រូវបានចាប់ខ្លួនផងដែរ។ ហើយនៅក្នុងខ្សែវីដេអូទី១នោះ គឺលេខ២ ខ្សែវីដេអូលេខ២ ចាប់ផ្ដើមពីនាទី០០:៤៨:១២ ដល់ ០០:៤៩:១២ នៃខ្សែវីដេអូនេះ ហើយផ្នែកនៃខ្សែភាពយន្តមួយនេះ ឈ្មោះ សុខជា ដែលរស់រានមានជីវិត គឺថាបានមកវត្តចំប៉ា ទីតាំងនៅក្នុងឃុំតាភេម ដែលយើងបានឮសក្ខីកម្មនៅក្នុងសវនាការនោះហើយ ដែលបានរៀបរាប់ ថាគាត់បានកត់សម្គាល់អំពីរបបខ្មែរក្រហម។ ដូច្នេះ យើងខ្ញុំសូមការអនុញ្ញាតដើម្បីបញ្ចាំងខ្សែ វគ្គខ្សែភាពយន្តទី២។ សូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៣:០៣]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ខ្ញុំចាំតែពេលខ្ញុំឡើងលើវិហារហ្នឹង។ នេះបង្អួចនេះ ខ្ញុំអើត។ បង្អួចខាងហ្នឹង ដែលខ្ញុំលួចអើត។ គេធ្វើទារុណកម្មមនុស្សនៅក្នុងហ្នឹង។ ធ្វើទារុណកម្មនៅក្នុងហ្នឹង។ បង្អួចហ្នឹង គេបិតជិតតែម្ដង។ ចាស បិទជិតឈឹង។ ទាំងអស់បិទជុំវិញតែម្ដង។ ទាំងអស់ជុំវិញ ហើយមានឈ្លបគេដើរជុំវិញហ្នឹងទាំងអស់ពេលដែលគេកំពុងចាប់ផ្ដើមធ្វើមានសម្លាប់មនុស្សអីនៅក្នុងហ្នឹង គឺគេដើរជុំវិញហ្នឹង។ ហើយខ្ញុំចាំៗកងឈ្លបម្នាក់ វាដើរជុំវិញហ្នឹង ដល់ពេលដើរអ៊ីចឹងទៅ ស្រាប់វា -- ខ្ញុំឮសូរសំឡេងស្រែកក្នុងហ្នឹងអូយៗ ខ្ញុំក៏លួចមើលតាមប្រហោងទ្វារអ៊ីចឹង។ បង្អួចហ្នឹងវាអត់បើកទេ អត់ទេ។ ឃើញទេ យើងមើលឃើញតែតាមបង្អួចហ្នឹងបន្តិចទេ ឃើញទេ។ អ្ហែង! មើលឃើញទេ"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៤:០៤:១០]

**លោក ឌេល លីសាក់៖**

ហើយខ្សែវេដីអូទី២ ដែលខ្ញុំចង់បង្ហាញផងដែរ គឺជាកត់សម្គាល់លេខ៣ សម្រាប់ខាងសោតទស្សន៍ គឺចាប់ពីនាទី ៥២:១៣ ដល់នាទី ៥៧:១៧ គឺនាទីនៃខ្សែភាពយន្ត ដែលយើងនឹងឃើញអំពីការប្រឈម គឺការជជែកគ្នារវាង សុខ ជា ដែលជាអ្នកនៅរស់រានមានជីវិត ហើយនិងអតីតប្រធានខ្មែរក្រហមឈ្មោះ តាការ៉ូប៊ី នៅក្នុងវត្តចំប៉ា។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឱ្យខាងសោតទស្សន៍ចាក់នូវខ្សែវីដេអូទី២។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៥:០៤]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*“ការ៉ូប៊ី៖ ឧបមាដូចជា ទឹកស្អុយដែលប្រឡាក់ខ្លាយប្រឡាក់កន្ទេលហ្នឹង មិនអាចយកទឹកស្អុយមកលាងឲ្យជ្រះទឹកស្អុយហ្នឹងបានទេ លុះត្រាតែយកទឹកក្រអូបមកលាងបានបាត់អាជាតិស្អុយហ្នឹង។ បើយើងទ្រឹស្តីសាសនាសម្តែងថា បើយើងចងកម្មចងពៀរគ្នាតទៅទៀត គឺអត់មានទីបំផុត។ នៅតាមកាប់សម្លាប់គ្នា អត់មានទីបំផុតទេ។ ប៉ុន្តែបើអត់សោះ និយាយចំពោះធ្វើរហ្នឹង ចំពោះមុខព្រះ បើនៅសង្គ្រាមអាហ្នឹងបាញ់ទៅបាញ់មក អាហ្នឹងក្រែងលោកមានខ្លះ ហើយបើអត់សង្គ្រាមមកប្រជាជនអាសូរអាណិតដូចគ្នា អ្នកណាក៏ដូចអ្នកណា ប៉ុន្តែយើងមិនប៊ានថា មិនប៊ានស្តីជាមួយគេ ធ្វើម៉េចយើងក្រោមគេ។ យើងខ្លាចស្លាប់ដែរ ត្រូវតែទៅ ត្រូវតែដើរជាមួយគេ។ សុខ ជា៖ តែចំពោះតាៗខ្លាចស្លាប់ ប៉ុន្តែចំពោះអ្នកដទៃក៏គេខ្លាចស្លាប់ដូចគ្នាដែរ។ ខ្ញុំឆ្ងល់ហេតុអីបានជាគេធ្វើប្រព្រឹត្តអំពើព្រៃផ្សៃអ៊ីចឹង ធ្វើបាបប្រពលរដ្ឋអ៊ីចឹង? ការ៉ូប៊ី៖ ខ្ញុំវាមិនដឹងដែរ អាហ្នឹងវាផែនការរបស់គេ ទំនងអង្កាល់ទ៊ុង វាក្បត់ពីប្រជាជនទាំងអស់ហើយ។ ខ្ញុំម៉េចដឹង វាមិនដឹងផែនការ។ សុខ ជា៖ ខ្ញុំចង់គ្រាន់ឲ្យគាត់ ចង់ដូចថាសម្តែងការស្មោះត្រង់ដែលគាត់ឃើញ គាត់បានបញ្ជា ឬក៏គាត់បានចូលរួម ឬក៏យ៉ាងណា ខ្ញុំចង់ឲ្យគាត់សម្តែងការស្មោះត្រង់ប៉ុណ្ណឹងទេ។ ដូចថា ជំនាន់ទ៊ុងយើងមានអ៊ីចឹងមែន ហើយមានសម្លាប់មនុស្សអ៊ីចឹងមែន ហើយគេល្បីៗគ្រប់គ្នាថា តាមានផឹកស្រា ស៊ីថ្លើមមនុស្ស ផឹកជាមួយប្រមាត់មនុស្សទៀត។ ការ៉ូប៊ី៖ អត់ទេ ខ្ញុំអត់ដែលប៊ានទេ។ អ្នកណាថា? (មិនស្គាល់អត្តសញ្ញាណ)៖ អត់មានស្រាទេ ទឹកត្នោតជូរ ប៉ុន្តែអាចមានទេអ៊ំ អាចមានអ្នកអ៊ីចឹងខ្លះអីអត់ទេ ក្រែងអ៊ំអត់ដឹង កូនចៅអ៊ំនោះ? ការ៉ូប៊ី៖ អាចមានៗគេធ្វើនៅផ្សេងៗ បើកន្លែងយើងអត់មានទេ។ កន្លែងខ្ញុំហ្នឹង។ សុខ ជា៖ តាកុហកហើយ នៅកន្លែងហ្នឹងអត់មានម៉េច? ការ៉ូប៊ី៖ អត់មានទេ។ សុខ ជា៖ អត់មានម៉េច? ឥឡូវ ខ្ញុំមានអ្នកសាក្សីមួយដែលគេឃើញពួកហ្នឹងកំពុងតែនាថ្លើម លោតផ្លោតៗក្នុងផ្ទះ។ ការ៉ូប៊ី៖ ចេះតែចោទខ្ញុំហើយលោកស្រី។ បើមានខ្ញុំសារភាពហើយ។ សុខ ជា៖ ខ្ញុំមិនមែនចោទតាទេ។ ខ្ញុំគ្រាន់តែឲ្យតា-- ។ (មិនស្គាល់អត្តសញ្ញាណ)៖ អ៊ំធ្វើហ្នឹងជា សុជា លើកឡើងមិនមែនមានន័យថា អ៊ំអ្នកធ្វើទេ ប៉ុន្តែគេមានអ៊ីចឹង តើអ៊ំគាត់ថា វាអាចមាន ឬក៏អត់? ការ៉ូប៊ី៖ អាហ្នឹងវាអាចមានពីអ្នកដទៃ ហើយចំពោះខ្ញុំអត់។ អាហ្នឹងខ្ញុំឯកភាពហើយ។ សុខ ជា៖*

*គេមិនចោទថា តាអ្នកហូប ខ្ញុំមិនចោទថា តាអ្នកធ្វើទេ។ តាស្តាប់ឲ្យច្បាស់ ខ្ញុំមិនមែនចោទថាតាអ្នកធ្វើទេ។ កូនចៅតាអ្នកធ្វើ ប៉ុន្តែអាចមាន ឬក៏អត់អ៊ី? ការ៉ូប៊ីៈ អាហ្នឹងវាអាច តែខ្ញុំមិនដឹងកន្លងមកវា មនុស្សដឹងតែនៅជាមួយគ្នា ដល់គេចេញដើរមិនដឹងគេធ្វើអីខ្លះ។ ប៉ះពាល់យករបស់គេអីខ្លះ ខ្ញុំតែម្ជុលមួយដើម ចេសមួយដើមខ្ញុំអត់ប៉ានប៉ះពាល់យកដែរ។ និយាយឲ្យស្មោះត្រង់ តាំងពីបាតដៃទទេ ដើរសួរប្រជាជនដែលឃើញខ្ញុំយកអី។ អាងធ្វើមេមានបួនដប់ម្ភៃនាក់ អាកូនអាខ្លះល្អ អាខ្លះអាក្រក់។ អាហ្នឹងចង់សម្លាប់មេ។ ដូចសព្វថ្ងៃក៏ដោយ ប៉ូលិសអីក៏ដោយ អាខ្លះគេល្អទៅតាមយុត្តិធម៌ អាខ្លះគេក្បត់ទៅក៏មាន។ ចិត្តមនុស្សមើលមិនទៀងត្រង់ទេ ហើយខ្ញុំសច្ចាមុខព្រះអង្គអ៊ីចឹងបើសិនណាខ្ញុំធ្វើអំពើក្បត់នុំងវាតែហោងអស់ហើយ ហ្នឹងមិនមែនត្រឹមនៅតាំងចាប់ពី២០ឆ្នាំទល់នឹងថ្ងៃនេះ។ ប៉ុន្តែខ្ញុំកសាងល្អតាំងពីក្នុងសង្គ្រាមមកទល់នឹងថ្ងៃនេះ។ ហ្នឹង ខ្ញុំជម្រាបអ្នកស្រីត្រង់អ៊ីចឹងតែម្តង។ សុខ ជាៈ អ៊ីចឹងបានគេមិនតាមធ្វើតា បើតាមចិត្តដែលគេចង់សងសឹកវិញ គេខឹងគេកាត់ (សូមខមាទោស) កាត់កតាទម្លាក់មែនហ្នឹង។ សូមខមាទោស។ (មិនស្គាល់អត្តសញ្ញាណ)ៈ មកនេះ គឺគ្រាន់តែចង់បានចម្លើយមួយឲ្យលោកខាងនេះគាត់ឆ្លើយទទួលស្គាល់កំហុសអ្វីដែលគាត់បានធ្វើ។ ចង់បានតែប៉ុណ្ណឹងទេ។ អ៊ីចឹងឥឡូវនេះឃើញថាអាត្មាស្តាប់ទៅ គាត់ក៏មិនមែនមានៈអីរឹងត្អឹងថា មិនព្រមទទួលទេ។ អាត្មាស្តាប់មើលទៅ។ (មិនស្គាល់អត្តសញ្ញាណ)ៈ អ៊ីចឹងសម្រាប់ចិត្តអ្អែងឥឡូវហ្នឹងរៀងស្ងប់បន្តិចទេ? សុខ ជាៈ ស្ងប់ ខ្ញុំបានស្ងប់បន្តិចហើយ ព្រោះគាត់បានសារភាព គាត់បានប្រាប់ថានៅកន្លែងហ្នឹងពិតជាមានធ្វើអ៊ីចឹងមែន ពិតជាមានស្លាប់អ៊ីចឹងមែន។ ខ្ញុំធួរដែរ ខ្ញុំមិនចងកម្ម ចងពៀរអីជាមួយគាត់ទេ ចាស។ ការ៉ូប៊ីៈ ប៉ុន្តែដល់ដេកគិតវិភាគ ពិចារណាធ្វើអីខុសវត្ត ទីអារាមវត្ត វ៉ៃវិហារចោលហើយ ខុស ថាគ្រប់គ្នា ប៉ុន្តែគិតក្នុងចិត្តទៅថា សង្គមមិនអាយុវែងទេ គិតដូចតែគ្នាហ្នឹង”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១០:០៣]

**លោក ឌេល លីសាក់ៈ**

លោក លោកស្រីចៅក្រម នៅក្នុងពេលវេលាដែលនៅសល់ ខ្ញុំសូមបង្ហាញឯកសារមួយចំនួនបន្ថែមទៀតដែលបង្ហាញអំពីនីតិវិធីជាប្រព័ន្ធដែលគេចាប់មនុស្សសួរចម្លើយ និងសម្លាប់មនុស្សនៅស្រុកត្រាំកក់។ ឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារមួយចំនួន ក៏ដូចជាឯកសារយោងដែលបង្ហាញពីការដឹង និងប្រព័ន្ធនៃការសួរចម្លើយ ខ្ញុំសូមលើកយកទៅលើឯកសារទាំងអស់មួយចំនួនគឺ កំណត់ត្រាដែលនិយាយ

អំពីវិធីសាស្ត្រក្តៅ វិធីសាស្ត្រត្រជាក់។ ហើយឯកសារបន្ថែមទៀតដែលនិយាយអំពីការប្រើអំពើហិង្សា គឺសៀវភៅ E3/4095 ខ្មែរមានលេខ 00271117, បារាំងមានលេខ 00721251 ដល់ 52 និងភាសាអង់គ្លេសមានលេខ 00747279។ គឺពាក់ព័ន្ធទៅនឹងអ្នកទោសខ្មែរក្រោមឈ្មោះ ថាច់ អ៊ុក។ ឯកសារបានកត់ត្រាថា អ្នកទោសនេះ ត្រូវបានគេវាយក្នុងពេលសួរចម្លើយប៉ុន្តែមិនសារភាពទេ។ ហើយបន្តទៅទៀតគឺជាឯកសារដែលបង្ហាញថាមេឃុំ និងមេស្រុកក្នុងស្រុកត្រាំកក់ក៏បានដឹងអំពីវិធីសាស្ត្រនៃការសួរចម្លើយ ហើយនិងអំណាចក្នុងការប្រើប្រាស់វិធីសាស្ត្រសួរចម្លើយនេះដែរ។ ឯកសារ E3/2447ៗ ត្រង់ភាសាខ្មែរមានលេខ 00270731 ដល់ 732, អង់គ្លេសមានលេខ 00355473 និងភាសាបារាំងមានលេខ 00632161 នេះគឺជារបាយការណ៍ថ្ងៃទី២៣ ឧសភា ឆ្នាំ៧៦ មកពីមេឃុំអង្គតាសោមឈ្មោះ ឆោម ផ្ញើជូនមេស្រុកពាក់ព័ន្ធទៅនឹងវរសេនីយ៍ គឹង ហ៊ិន ដែលត្រូវបានរៀបរាប់ថាជាទាហានៗជើងកាងកើតស្វាយ គឺថានៅពេល -- នៅចុងបញ្ចប់មេឃុំ ឆោម បានរាយការណ៍ដូចតទៅនេះ៖ "យើងឲ្យឈ្លបនាំគាត់មកសួរចម្លើយដែលប្រើប្រាស់វិធីសាស្ត្រត្រជាក់ ហើយគាត់បដិសេធមិននិយាយអ្វីទាំងអស់ដូច្នេះ ខ្ញុំចង់ស្នើមិត្តឲ្យសួរវាពីព្រោះប្រពន្ធបុគ្គលម្នាក់នេះនៅក្នុងផ្នែកដាំដុះ ហើយបានជេរអង្គការស្រុក ហើយពួកគេធ្វើស្រីដោយតាមៗចិត្ត"។

[១៤:១៣:២៨]

ឯកសារ E3/4126ៗ ដែលមានខ្មែរមានលេខ 00270931 ដល់ 32, អង់គ្លេសមានលេខ 00366714 និងបារាំងមានលេខ 00632501 ដល់ 02 នេះគឺជារបាយការណ៍មកពីមេគុកក្រាំងតាចាន់ឈ្មោះអាន់ ចុះថ្ងៃ២៦ ធ្នូ ៧៧ បានរៀបរាប់ពីការសួរចម្លើយអ្នកទោសស្ត្រីម្នាក់ ហើយខ្ញុំសូមដកស្រង់៖ "នៅពេលដែលកម្មាភិបាលក្នុងកងទ័ពរបស់យើងសួរចម្លើយវាៗយំរហូត ហើយមុខវាឡើងខ្មៅ ដែលនេះគឺជាការធ្វើពុត ហេតុដូច្នេះតាមការពិនិត្យរបស់ខ្ញុំ មានតែប្រើវិធីក្តៅប៉ុណ្ណោះទើបវាឆ្លើយសារភាពនៅក្នុងកន្លែងធ្វើការរបស់ទាហាននៅអង្គតាសោម គឺមិនមានទីកន្លែងសម្ងាត់ដើម្បីធ្វើការសួរចម្លើយឡើយ ហេតុដូច្នេះហើយ ខ្ញុំសូមធ្វើការលើកជូនភាគីដើម្បីជាព័ត៌មាន ថាតើភាគីសម្រេចយ៉ាងដូចម្តេច ថាតើបក្សសម្រេចយ៉ាងដូចម្តេងខ្ញុំចាំការសម្រេច"។

ឯកសារ E3/2445ៗ នៅភាសាអង់គ្លេសមានលេខ 00363653, ខ្មែរមានលេខ 00270984, បារាំងមានលេខ 00612444។ ឯកសារនេះបានបញ្ជាក់ថា ពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់ មឿង សុន ជាអ្នកទោសដែលត្រូវបានចាប់ខ្លួន នៅថ្ងៃ១៦ ខែកញ្ញា ឆ្នាំ៧៧ បានដកស្រង់ "យើងបានអនុវត្ត

វិធីក្ដៅ វិធីត្រជាក់ ដើម្បីសួរចម្លើយ មឿង សុន។ គាត់សារភាពថា ពួកគេត្រូវបានតែងតាំង ដោយ អាភឿង តាំងពីខែវិច្ឆិកា ឆ្នាំ៧៦".

[១៤:១៦:០៤]

លោក លោកស្រីចៅក្រម យើងនៅមានឯកសារ ដែលបង្ហាញថាចម្លើយសារភាពពីក្រាំងតាចាន់ ត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋានក្នុងការចាប់ខ្លួនអ្នកដែលនៅក្នុងស្រុក ដែលត្រូវបានឆ្លើយដាក់ ឬក៏ ឈ្មោះដែលមាននៅក្នុងចម្លើយសារភាព។ ដូច្នេះ ខ្ញុំលើកយកឯកសារ E3/2012 នៅត្រង់ខ្មែរមានលេខ 00082726, អង់គ្លេសមានលេខ 00276595 និងបារាំងមានលេខ 00797685។ នេះគឺជារបាយ-ការណ៍ថ្ងៃទី១១ ខែកក្កដា ឆ្នាំ៧៧ ពី អាន់ ទាក់ទងទៅនឹងចម្លើយសារភាពរបស់អ្នកទោស សិន យ៉ាង។ ហើយនៅក្នុងចំណុចនេះ យើងឃើញថាមានចំណារសរសេរផ្ទាល់ដៃនៅផ្នែកខាងលើ ខាងឆ្វេងដែល បញ្ជាក់ថា "ត្រូវកម្ទេច" ហើយនៅផ្នែកខាងក្រោមនៃរបាយការណ៍នេះ គឺនៅកណ្ដាល គឺមានឈ្មោះ មន្ត្រីលន់នល់ ពីរនាក់ទៀត ដែលគេកំណត់ថាជាអ្នកទោស គឺជាវរសេនីយ៍ និងអនុសេនីយ៍ត្រី។ ហើយ នៅក្បែរឈ្មោះនោះ គឺមានចំណារមួយផងដែរ ដែលសរសេរថា "ត្រូវចាប់ខ្លួន"។ ដូច្នេះ ដំណើរការនៃ ការចាប់ខ្លួនត្រូវបន្តទៅមុខទៀត។

ខ្ញុំបានលើកឡើងច្រើនដងអំពីឯកសារដែលបង្ហាញថា ការអនុម័តពីខាងតំបន់ គឺត្រូវការឲ្យមាន ការអនុម័តពីខាងតំបន់ ដើម្បីចាប់ខ្លួន ឬក៏សម្លាប់។ ហើយមុននឹងពេលបញ្ចប់ ខ្ញុំសូមលើកយកឧទា-ហរណ៍មួយចំនួនទាក់ទងទៅនឹងថ្នាក់ស្រុក ដែលរាយការណ៍ពីខាងភូមិភាគ ទៅទីក្រុងភ្នំពេញ។ យើង បានឃើញជាច្រើនដងរួចមកហើយនូវរបាយការណ៍ ខែវិច្ឆិកា ឆ្នាំ៧៧ ពីក្រាំងតាចាន់ គឺឯកសារ E3/2109, ខ្មែរមានលេខ 00068014, អង់គ្លេសមានលេខ 00276555 និងបារាំងមានលេខ 00290272។ របាយការណ៍នេះបានរាយការណ៍ថា នៅក្នុងខែវិច្ឆិកា ឆ្នាំ៧៧ គឺមានអ្នកទោស៧៥នាក់ ទៀត ត្រូវបានគេបញ្ចូល ហើយអ្នកទោ៨២ ត្រូវបានគេសម្អាត ប្រាំមួយនាក់ស្លាប់ដោយសារជំងឺ ហើយ ម្នាក់ត្រូវបានគេដកទៅតំបន់។ ហើយមានឧទាហរណ៍មួយទៀត នៅរបាយការណ៍ប្រចាំខែ មកពីក្រាំង តាចាន់ ដែលខ្ញុំនឹងលើកបង្ហាញនៅពេលនេះ គឺរបាយការណ៍ខែកក្កដា ឆ្នាំ៧៧។ នៅក្នុងឯកសារ E3/4085 ត្រង់ភាសាខ្មែរមានលេខ 00068017, អង់គ្លេសមានលេខ 00276558 និងបារាំងមានលេខ 00850346។ ឯកសារនេះបង្ហាញនូវព័ត៌មានប្រហាក់ប្រហែលគ្នាដែលត្រូវបញ្ជូនទៅមេដឹកនាំបក្ស ជារៀងរាល់ខែដែលវាជារបាយការណ៍ប្រចាំខែ ដែលថាអ្នកទោស១៨រូបចូល អ្នកទោស៣៩ ត្រូវបាន

បោសសម្អាត ពីរស្លាប់ដោយសារជំងឺ ហើយនៅសល់៤0អ្នកទោសទៀតដែលនៅសល់នៅចុងខែនោះ។

[១៤:២០:១៥]

ហើយជាចុងក្រោយគឺឯកសារ E3/853១។ នេះគឺជារបាយការណ៍មកពីភូមិភាគនីរតី ផ្ញើជូនអង្គការចុះថ្ងៃទី៣ មិថុនា ឆ្នាំ១៩៧៧។ របាយការណ៍នេះ គឺធ្វើតាមបែបបទនៃរបាយការណ៍របស់ភូមិភាគទាំងអស់នានា ផ្ញើជូនមជ្ឈិម ដោយចាប់ផ្ដើម របាយការណ៍អំពីស្ថានភាព ការពារជាតិ ឬសេដ្ឋកិច្ច បន្ទាប់មកទៀត គឺនិយាយអំពីសេដ្ឋកិច្ច គឺការបណ្ដាំដកស្រូវ និងកសាងទំនប់ប្រឡាយ ហើយបញ្ចប់ដោយរបាយការណ៍អំពីជីវភាពប្រជាជន។ របាយការណ៍មកពីខាងនីរតី គឺរៀងរាល់ពីគ្រប់តំបន់ និងស្រុកទាំងអស់នៅក្នុងភូមិភាគនីរតីរួមបញ្ចូលទាំងតំបន់តាកែវគឺ តំបន់១៣ នៅស្រុកត្រាំកក់។ ឧទាហរណ៍នៅក្នុងផ្នែកទី១ នៃរបាយការណ៍ ពីភូមិភាគនីរតីគឺនិយាយអំពីស្ថានភាពការពារជាតិ រាយការណ៍អំពីការចាប់ខ្លួនខ្មាំង និងការសារភាពដែលទទួលបានពីការសួរចម្លើយខ្មាំង ដែលបញ្ជាក់ដូចតទៅនេះ។ ខ្ញុំសូមដកស្រង់៖ “យោងតាមសារភាពរបស់ខ្មាំង ដែលចាប់បាននៅក្នុងខេត្តតាកែវ និងកំពត ខ្មាំងបានបង្កើតបណ្ដាញនីរសារ ដែលមាន ដែល១នៅក្នុងស្រុកគិរីវង់ ទូកមាស អង្គរជ័យ និងភ្នំដំរី។ ខ្មាំងជំរុញឲ្យមានការផ្លាស់ទីពីមួយកន្លែងទៅមួយកន្លែង ឧទាហរណ៍ដូចជាពីតំបន់៣៥ ទៅតំបន់១៣ និងពី១៣មក១៥ ឬក៏ផ្លាស់ទីទៅភ្នំ។ កន្លងមកយើងបានចាប់ខ្មាំងដោយជោគជ័យនៅពេលដែលពួកវាធ្វើសកម្មភាពដូចដែលបានបញ្ជាក់ខាងលើ”។

[១៤:២២:១៤]

របាយការណ៍ថ្ងៃ -- នៅរបាយការណ៍ខែមិថុនា ឆ្នាំ៧៧ ពីភូមិភាគទៅមជ្ឈិម គឺរាយការណ៍អំពីការដាំដុះស្រូវ នៅឃុំលាយបូរ ក៏ដូចជាផែនការជីកទំនប់ប្រឡាយនៅក្នុងស្រុកត្រាំកក់។ ពាក់ព័ន្ធទៅនឹងការរស់នៅ និងសុខភាពរបស់ប្រជាជន នៅចុង១បំផុតនៃទំព័រនេះ គឺភូមិភាគបានរាយការណ៍ថា៖ “ឥឡូវនេះនៅក្នុងកំពត កំពង់ស្ពឺ និងតាកែវ ប្រជាជន មានជំងឺអាសន្នរោគ ហើយអ្នកខ្លះស្លាប់”។

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់នៅត្រង់ចំណុចនេះ។ ហើយខ្ញុំសូមប្រគល់វេទិកានេះជូនទៅខាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើបទបង្ហាញអំពីឯកសារគន្លឹះ ហើយយើងសូមបញ្ចប់ការធ្វើបទបង្ហាញរបស់ខាង សហព្រះរាជអាជ្ញា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

សម្រាប់សវនាការពាក់ព័ន្ធនឹងឯកសារគន្លឹះនេះ យើងខ្ញុំគឺៗជាអ្នកនាំពាក្យរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងព្យាយាម -- យើងបានសម្រេចចិត្តអាននូវសម្រង់ប្រាំជាអាទិភាព គឺជាពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលយក ដោយសារតែគាត់បានឈឺចាប់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសហករណ៍ត្រាំកក់។ ក្រៅពីសម្រង់ទាំងប្រាំនេះ យើងនឹងអានសម្រង់មួយទៀតនៃកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃសមាជិកឃុំតាភេម ដែលស្របទៅនឹងអ្វីដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាក្សីមួយចំនួនដែលយើងបានស្តាប់នៅសវនាការនេះ។ យើងបែងចែកវេទិកានេះរវាងខ្ញុំ និងមេធាវី ហុង គឹមសួន។

ជាដំបូងខ្ញុំទុកឱកាសនេះឲ្យ លោកមេធាវី ហុង គឹមសួន ជាមុនសិន ដើម្បីឲ្យគាត់អាននូវសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបីជាភាសាខ្មែរ។ បន្ទាប់មកទៀត ខ្ញុំនឹងបន្តពីគាត់ដើម្បីអាននូវសម្រង់មួយចំនួនជាភាសាបារាំង។

ដូច្នេះ ខ្ញុំសូមធ្វើការអនុញ្ញាតប្រគល់វេទិការនេះទៅសហភាតារបស់ខ្ញុំ គឺលោកមេធាវី ហុង គឹមសួន។ សូមអរគុណលោកប្រធាន។

[១៤:២៤:៥៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោក ហុង គឹមសួន។ សូមអញ្ជើញមេធាវីការពារក្តីលោក នួន ជា លោក វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងមិនជំទាស់ទេ ប៉ុន្តែយើងចង់ឲ្យមានការណែនាំទាក់ទងទៅនឹងលក្ខណៈនៃការធ្វើបទបង្ហាញឯកសារ។ យើងនៅទីនេះធ្វើការបង្ហាញអំពីឯកសារ ដើម្បីបង្ហាញឯកសារជូនអង្គជំនុំជម្រះ ប៉ុន្តែនៅពេលដែលយើងពិនិត្យមើលទៅលើបញ្ជីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឯកសារភាគច្រើនដែលលើកយកមកបង្ហាញ គឺហាក់ដូចជាការដកស្រង់ចេញពីពាក្យសុំតាំងខ្លួន។ ដូច្នេះខ្ញុំគិតថា វាមិនមែនជាគោលដៅនៃការធ្វើបទបង្ហាញឯកសារនៅពេលនេះទេ។ គឺថាយើងគ្រាន់តែចង់ធ្វើ

បទបង្ហាញ ដើម្បីបង្ហាញលក្ខណៈរបស់ឯកសារ ព្រោះឯកសារទាំងអស់គឺមាននៅក្នុងសំណុំរឿងអស់ទៅហើយ។ ប្រសិនបើអង្គជំនុំជម្រះនិយាយថា អត់បញ្ហា អាចឲ្យដើមបណ្ដឹងរដ្ឋប្បវេណី គាត់លើកយកផ្នែកនៃព័ត៌មាន។ ដូច្នេះ ខាងមេធាវីការពារក្ដីក៏ប្រហែលជាអាចនឹងលើកយកកំណត់ហេតុស្ដាប់ចម្លើយ ឬក៏ព័ត៌មានផ្សេងៗយកមកធ្វើបទបង្ហាញផងដែរ។

ដូច្នេះខ្ញុំគិតថា ចំពោះយើងនៅក្នុងការធ្វើបទបង្ហាញនៅពេលនេះ គឺយើងគ្រាន់តែលើកយក ប៉ុន្តែថាតើដើមបណ្ដឹងរដ្ឋប្បវេណីគាត់លើកយកនូវសម្រង់ចេញពីពាក្យសុំតាំងខ្លួន ឬក៏កំណត់ហេតុស្ដាប់បាន ឬក៏អត់?

[១៤:២៦:៣៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ខ្ញុំយល់ឃើញថា អ្វីៗដូចជាច្បាស់រួចទៅហើយ ដោយអនុវត្តដោយពិនិត្យមើលការអនុវត្តមុនៗរបស់អង្គជំនុំជម្រះដែលបានយើងខ្ញុំបង្ហាញនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមរំឭកថា ពាក្យសុំទាំងអស់នេះជាឯកសារ ដែលជាឯកសារជាលាយលក្ខណ៍អក្សរ ហើយជាឯកសារនៅក្នុងសំណុំរឿង ហើយយើងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការបង្ហាញឯកសារទាំងអស់នេះ នៅក្នុងសវនាការ។ យើងមិនដែលទទួលបានការបញ្ជាពីអង្គជំនុំជម្រះថាយើងមិនអាចបង្ហាញឯកសារទាំងនុ៎ងបានទេ ពីព្រោះថាយើងធ្លាប់បានបង្ហាញមកហើយ នៅក្នុងការជំនុំជម្រះ ក្ដីមុនៗនោះ។ ដូច្នេះ ខ្ញុំគិតថាយើងអាចបង្ហាញទាំងនេះបាន អង្គជំនុំជម្រះនឹងមានឱកាសក្នុងការសម្រេចអំពីតម្លៃជាភស្តុតាង។ ដូច្នេះ ខ្ញុំមើលទៅដូចជាគ្មានមូលដ្ឋានអីទេ ដែលខាងមេធាវីការពារក្ដី គាត់ជំទាស់នោះ។

ដូច្នេះ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតៗឲ្យខ្ញុំធ្វើដូចអ្វីដែលបានធ្វើកាលពីសវនាការមុនៗ។ គឺអនុញ្ញាតឲ្យយើងខ្ញុំបង្ហាញឯកសារដែលពាក់ព័ន្ធបំផុតសម្រាប់ផ្នែកនេះនៃសវនាការរបស់យើង។ សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:១២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតដល់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញ

នូវឯកសារដកស្រង់ចេញពីឯកសារជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលខ្លួនយល់ឃើញថាសំខាន់ ឬចាំបាច់ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើការដាក់បង្ហាញគន្លឹះ ឯកសារគន្លឹះនៅពេលនេះ។ សូមអញ្ជើញ!

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោកស្រី លោកចៅក្រម អង្គជំនុំជម្រះជាទីគោរព និងសូមគោរពដល់អង្គសវនាការជាទីគោរព។

ខ្ញុំបាទ ហុង គឹមសួន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការអានជាភាសាខ្មែរនូវអត្ថបទទាក់ទងជាមួយនឹងវត្តមានដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូននៅក្នុងអង្គជំនុំជម្រះរួចមកហើយដូចតទៅនេះ។ ទី១ ខ្ញុំសូមលើកអានអំពីឯកសាររបស់ឈ្មោះ ឆឹង ផល ភេទស្រី ដែលជាឯកសារ E3/6143 ជាឯកសារក្នុង ERN ជាភាសាខ្មែរ 00552296 ដល់98, ជាភាសាអង់គ្លេស 01076692 ដល់93 ដែលមានខ្លឹមសារខ្លះៗដូចតទៅនេះ៖ "នាងខ្ញុំឈ្មោះ ឆឹង ផល សព្វថ្ងៃរស់នៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ។ នៅមុនឆ្នាំ១៩៧៥ ប្តីរបស់នាងខ្ញុំធ្វើជាទាហានផ្នែកទូរគមនាគមន៍តខ្សែទូរស័ព្ទ ឯខ្ញុំជាមេផ្ទះមើលកែកូនស្រីម្នាក់ ប្រុសម្នាក់។ ថ្ងៃ១៧ មេសា ១៩៧៥ ក្រុមគ្រួសារបានត្រូវពួកខ្មែរក្រហមស្លៀកពាក់ខ្មៅ កាន់កាំភ្លើងអាកាបាញ់ទទឹងទទែង បណ្តេញប្រជាជន និងក្រុមគ្រួសារខ្ញុំឲ្យចេញ។ គេថាពួកវាត្រូវរៀបចំបោសសម្អាតក្រុងមួយ ឬពីរថ្ងៃ អាចត្រឡប់មកវិញហើយ។ ខ្ញុំនឹងក្រុមគ្រួសារបានទៅនៅស្រុកកំណើតប្តីខ្ញុំនៅស្រុកត្រាំកក់ ភូមិត្រពាំងរនាត ខេត្តតាកែវ។ ពេលទៅដល់ពីរយប់គេមិនឲ្យធ្វើអីទេ គេឲ្យអង្កររបបបីកំប៉ុង សម្រាប់គ្រួសារខ្ញុំ ហើយបន្ទាប់មកគេឲ្យខ្ញុំទៅបេះស្លឹកមនសម្រាប់ចិញ្ចឹមដង្កូវនាង ដាំដំណាំក្នុងស្រែ។ ក្រោយមកគេឲ្យច្រូត ស្ទូង១៥នាក់ពាហិកតាក្នុងមួយថ្ងៃ បើមិនរួចគេមានផែនការថ្មី។ ក្រៅពីនោះ គេប្រើឲ្យជីកប្រឡាយទទឹង ៣ម៉ែត្របណ្តោយវែងរាប់គីឡូ ទោះជាធ្វើការនឿយអត់ហួសកម្លាំងយ៉ាងណាក៏ខ្ញុំ ក៏ខំប្រឹងព្រោះខ្លាចគេយកប្តីយកកូនទៅសម្លាប់។ ពេលខ្ញុំអង្គុយតែម្នាក់ឯង ប្រធានភូមិឈ្មោះ តាង៉ង់ និង ងឹម បានចោទ ខ្ញុំថា -- បានចោទខ្ញុំពាក្យគំរោះគំរើយថា ង៉ែងមិនចង់ -- ង៉ែងមិនសប្បាយចិត្តធ្វើបដិវត្តន៍នឹងគេ ទើបអង្គុយដាច់ពីគេដូច្នេះ។ ខ្ញុំព្យាយាមឆ្លើយថា ខ្ញុំខ្លាចនិយាយលេងប៉ះពាល់មាគ៌ាបដិវត្តន៍ ទើបខ្ញុំអង្គុយតែឯង។ ខ្ញុំសប្បាយចិត្តនឹងធ្វើបដិវត្តន៍នឹងគេ។ នៅដើមខែមាឃឆ្នាំ១៩៧៧ គេបានមកចាប់ខ្ញុំចងពេលខ្ញុំសម្រាកហូបបាយនៅកន្លែងធ្វើប្រឡាយ។ មានបីនាក់ឈ្មោះ តាង៉ង់ ប្រធានភូមិ ងឹម ប្រធានឈ្លប និងប្រធាន

យុវជនមកចងស្លាបសេកបណ្ដើរខ្ញុំទៅដោយមិនប្រាប់ខ្ញុំខុសអីទេ។ ទៅឆ្ងាយពីទីនោះ ជាងមួយគីឡូ នៅលើទួលមានសុទ្ធតែដើមឈើ មានរណ្ដៅអាបេ ពួកវាធាក់ខ្ញុំឱ្យអង្គុយ ហើយចោទសួរខ្ញុំ៖ តើឯងធ្វើគិញលន់ នល់ ឬ? ទី២ តើចង់កម្ទេចបដិវត្ត? ទី៣ ឯងចង់វាយប្រហារអង្គការ? ពេលសួរខ្ញុំនោះ ពួកវាបានវាយខ្ញុំនឹងដំបងឫស្សី។ ខ្ញុំឆ្លើយថា៖ ខ្ញុំមិនបានធ្វើគិញទេ វាថាខ្ញុំធ្វើស្រីទាហាន រឹងរូសណាស់ទើបវាយខ្ញុំថែមទៀតឱ្យឆ្លើយ។ តែខ្ញុំមិនឆ្លើយ ព្រោះខ្ញុំមិនបានធ្វើ។ វាបង្ខំឱ្យឆ្លើយដោយនិយាយថា៖ បើឆ្លើយវានឹងដោះលែង។ តែខ្ញុំប្រកែកមិនព្រមឆ្លើយ។ ចំណុចទី២ ខ្ញុំសួរវាវិញថា៖ កម្ទេចបដិវត្តន៍យ៉ាងម៉េច? ខ្ញុំមិនដឹងថាម៉េចទេ។ ពួកវាចោទខ្ញុំថា ពេលអង្គការឱ្យសំពុតមកខ្ញុំ ខ្ញុំមិនស្លៀក ថាខ្ញុំយកទៅកាត់កម្ទេចធ្វើខ្មៅ ធ្វើពូកខ្នើយកើយ តែខ្ញុំប្រាប់ថា៖ ឱ្យពូទៅមើលទៅ ខ្ញុំមិនបានធ្វើដូចពាក្យគេវាយការណ៍ទេ។ ងឹម នោះបានស្ទុះមកវាយតប់ធាក់ខ្ញុំមួយជើងចាំដើមទ្រូងដួលទៅក្រោយ មាត់ខ្ញុំហូរឈាម អណ្ដាតរួញនៅបំពងក។ ទី៣ ខ្ញុំសួរទៅវិញថា៖ វាយប្រហារអង្គការយ៉ាងម៉េច ខ្ញុំមិនដឹងទេ។ គេថា ខ្ញុំបាននិយាយប្រាប់គេថាអង្គការមិនឱ្យទឹកត្នោតប្រជាជនផឹក ឱ្យតែប្រពន្ធកូនអង្គការ។ ខ្ញុំឆ្លើយថា៖ នរណាដែលរស់នៅក្រោមបដិវត្តន៍ហើយហ៊ាននិយាយដូច្នេះ។ ពួកវាថាខ្ញុំជាស្រីទាហានរឹងក្បាលណាស់ ពេលដែលកំពុងធ្វើបាបខ្ញុំនោះ មានតាម្នាក់ឈ្មោះ វង្ស ទៅបោចល្ពក់មកធ្វើដែបង្កី។ ឃើញព្រឹត្តិការណ៍នេះក៏ទៅចាប់វាយគាត់រហូតដល់ស្លាប់ ដោយចោទគាត់ថាជាអ្នកស៊ើបការណ៍។ ពេលជាមួយនោះ មានកូនក្មេងអាយុជា១០ឆ្នាំ ជិះកង់មកជួបពួកវា ហើយពួកវានិយាយថា ឯងសំណាងហើយដែលអង្គការបានដោះលែង។ គ្រាន់តែឱ្យកសាង ព្រោះរកកម្លាំងជំនួសមិនបាន។ ហើយវាសម្លុតខ្ញុំថា បើហ៊ានតែត្រឡប់ទៅវិញនិយាយប្រាប់ប្ដី កូន និងអ្នកដទៃឱ្យបាក់ទឹកចិត្តធ្វើការ យើងនឹងសម្លាប់ឯងចោលភ្លាម។ ក្រោយពីនោះមក គេបញ្ជាឱ្យខ្ញុំទៅធ្វើការជាមួយកងប្រមូលផ្ដុំ ដែលគេយកប្ដីទៅសម្លាប់ឱ្យធ្វើជីលាមក ដោយយកលាមក មកលាយដីដំបូក និងហាលឱ្យស្ងួត កើបដាក់ជង្រុកទុក។ ទោះជាមានក្លិនស្អុយយ៉ាងណាក៏ខ្ញុំសុខចិត្តទ្រាំ ខាំមាត់ដែរ។ បន្ទាប់មក ពីនោះមក គេបញ្ជាឱ្យខ្ញុំធ្វើប្រឡាយទឹកនៅឆ្ងាយពីភូមិ រហូតដល់វៀតណាម និងកងទ័ពរណសិរ្សមករំដោះ។ ពេលនោះ ខ្ញុំឮគេថាគេធ្វើនំបញ្ចុកដាក់ថ្នាំ សម្លាប់ប្រជាជន១៧មេសា។ តែខ្ញុំនិងប្រជាជន មិនទាន់បានហូបផង ក៏វៀតណាមមករំដោះទាន់។ ពេលកងទ័ពមកពួកវារត់ឡើងភ្នំ តែពួកកៀងពួកប្រជាជនទៅតាមវា។ ប៉ុន្តែខ្ញុំគិតជាមួយប្ដីខ្ញុំថា យើងទៅ យើងនឹងស្លាប់ព្រោះអត់មានអីហូបទេ។ និយាយអំពីឪពុកខ្ញុំ អ្នកស្រុកកណ្ដឹងបានប្រាប់ថា គាត់សម្លាប់ដោយក្រុមខ្មែរក្រហមសម្លាប់។ ម្នាក់ទៀតរស់នៅព្រែកតូចជាប់គុកជាមួយឪពុកខ្ញុំ គេប្រាប់ថា ឪពុកខ្ញុំស្លាប់ដោយ

វេទនាណាស់ ដោយគេចងស្លាបសេកធាក់ទម្លាក់ទឹកទន្លេព្រែកតូចពីរដងអត់ស្លាប់ ទើបគេយកទៅដាក់វិហារកោះគរ ដើម្បីសម្លាប់ចោល។ វិហារនោះជាគុកពេលឪពុកខ្ញុំសម្រាន្តយប់ឡើង សង្កើចវារឡើងខ្លួនគាត់ គាត់បោសចេញ ធ្វើឲ្យពួកវាយល់ថា គាត់ចង់រត់ទើបវាយគាត់នឹងដែកផ្លូវរទេះ លានភ្នែកចេញមកក្រៅ។ ស្អែកគេយកគាត់ទៅសម្លាប់ទៀត”។ ហើយចុងបញ្ចប់របស់គាត់ ក៏សុំឲ្យតុលាការរកយុត្តិធម៌ឲ្យគាត់ផង។

[១៤:៤០:០០]

ខ្ញុំបាទសូមបន្តទៅទី២ ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កែវ ហ៊ន ភេទស្រី។ ឯកសារលេខ E3/6057, ERN ជាភាសាខ្មែរ 00541106 ដល់ 07, ERN ជាភាសាអង់គ្លេស 01069297 ដល់ 98។ កែវ ហ៊ន បានមាន -- បាន -- នៅក្នុងឯកសាររបស់គាត់បាននិយាយថា ថ្ងៃ១៧ មេសា ១៩៧៥ ជម្លៀសទៅនៅភូមិត្រាំកក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ នៅក្នុងសម័យខ្មែរក្រហម ខ្ញុំបានបាត់បង ប្តីឈ្មោះ ឃុត ឃន ស្លាប់ដោយសារពួកវាយកទៅសម្លាប់។ កូនស្រីឈ្មោះ ឃុត ហ៊ី ស្លាប់ដោយសារការធ្វើទារុណកម្មនិងបង្អត់អាហារ។ កូនស្រីឈ្មោះ ឃុត ហ៊ំ ស្លាប់ស្លាប់ដោយសារការធ្វើទារុណកម្មនិងបង្អត់អាហារ។

ដំណើររឿងរបស់គាត់គឺមានខ្លីទេ គឺគាត់សរសេរ -- ខ្ញុំបាទមិនអានទាំងអស់ទេ “គឺនៅថ្ងៃទី១៧ ខែមេសា ១៩៧៥ ខ្ញុំនិងគ្រួសារខ្ញុំត្រូវពួកខ្មែរក្រហម ជម្លៀសឲ្យទៅនៅភូមិត្រាំកក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំនិងគ្រួសារខ្ញុំទៅដល់ទីនោះ គឺជាប្រជាជនថ្មី។ ពេលនោះពួកប្រជាជនចាស់បានបញ្ជាឲ្យខ្ញុំរែកអាចម៍គោ លើកភ្លឺស្រែ ជីកប្រឡាយធ្វើស្រែ ដកស្ទូង រួចហើយពួកខ្មែរក្រហមបានឲ្យខ្ញុំនិងប្រជាជនថ្មីហូបបបរជាមួយព្រលឹតនិងត្រកួន។ ឆ្នាំ១៩៧៦ ពួកខ្មែរក្រហម មិនបានធ្វើការជម្លៀសគ្រួសារខ្ញុំនិងប្រជាជននៅទីនោះឲ្យទៅក្នុងទីណានោះទេ គឺឲ្យពួកយើងរស់នៅក្នុងភូមិ ឃុំ ស្រុកត្រាំកក់ ខេត្តតាកែវនេះដដែល។ ចំណែកការហូបចុកវិញ គឺបបរជាមួយត្រកួនដដែល ហើយនៅពេលនោះក៏មានការសម្លាប់មនុស្សខ្លះៗដែរ។ ពេលនោះប្តីរបស់ខ្ញុំត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ដោយនិយាយថាយកទៅឲ្យធ្វើស្រែ។ ចាប់ពីពេលនោះមកប្តីរបស់ខ្ញុំបានបាត់ដំណឹងរហូតមកទល់សព្វថ្ងៃនេះ។ គាត់ឈ្មោះ ឃុត ឃន អាយុ៤៧ឆ្នាំ មុខរបរកសិករ ត្រូវពួកវាយកទៅសម្លាប់។ បន្ទាប់មកកូនស្រីទី១ ឈ្មោះ ឃុត ហ៊ី នៅកងកុមារក៏បានស្លាប់ដែរ គឺស្លាប់ដោយសារការធ្វើទារុណកម្មខ្លាំងពេក ទ្រាំនឹងការឈឺចាប់មិនបាន ព្រមទាំងគ្មានថ្នាំព្យាបាលផងនោះនាងក៏បានស្លាប់ទៅ។ ហើយការកាប់សម្លាប់មនុស្សគឺ

កាន់តែច្រើនឡើងៗ រីឯអាហារគឺបបរទទេ លែងមានត្រកួនទៀតហើយ។ ឆ្នាំ១៩៧៧ ពួកវាបានធ្វើការជម្លៀសខ្ញុំ និងប្រជាជននៅក្នុងភូមិនោះឲ្យទៅនៅក្នុងភូមិរលាក ឃុំតាអូរ ស្រុកគិរីវង់។ ខ្ញុំបាទសូមបញ្ចប់ត្រឹមនេះ ព្រោះឆ្លងអង្គហេតុបន្តិចបាទ។

តទៅនេះ ខ្ញុំបាទសូមបន្តមួយទៀត--

[១៤:៤៤:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ ទៅលើសំណើរបស់មេធាវីការពារក្តីនួន ជា សូមឲ្យចៅក្រមអង្គជំនុំជម្រះនិងភាគីនានាចុះពិនិត្យមន្ទីរសន្តិសុខក្រាំងតាចាន់។

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ មេធាវីការពារក្តី នួន ជា បានស្នើឲ្យចៅក្រម និងភាគីផ្សេងទៀតចុះពិនិត្យទីតាំងដែលជាអតីតមន្ទីរសន្តិសុខក្រាំងតាចាន់។ មេធាវីការពារក្តី នួន ជា បានពន្យល់ពីសារៈសំខាន់ក្នុងការពិនិត្យដោយផ្ទាល់ទៅលើបរិវេណ និងចម្ងាយរវាងទីតាំងផ្សេងៗនៅក្នុង និងជុំវិញមន្ទីរសន្តិសុខក្រាំងតាចាន់នេះ។ មេធាវីការពារក្តី ខៀវ សំផន ក៏បានគាំទ្រសំណើសុំនេះដែរ។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានរំឭកទៅមេធាវីការពារក្តី នួន ជា អំពីរបាយ-

ការណ៍កំណត់អត្តសញ្ញាណទីតាំងនេះ ដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន។ អង្គជំនុំជម្រះបានស្នើដល់ភាគីនានាឲ្យផ្ដល់មតិយោបល់បន្ថែមទៅលើរបាយការណ៍នេះ។ មេធាវីការពារក្ដី នួន ជា បានរក្សាសំណើសុំរបស់ខ្លួន និងបានលើកឡើងថា ការទៅពិនិត្យទីតាំងដោយផ្ទាល់មានសារៈសំខាន់យ៉ាងខ្លាំងជាងការគ្រាន់តែពិនិត្យមើលរបាយ-ការណ៍ដែលមាននៅក្នុងសំណុំរឿង។

ដោយផ្អែកទៅលើវិសាលភាពនៃទីតាំងនេះជាក់ស្ដែងមេធាវីការពារក្ដី នួន ជា ក៏បានលើកឡើងផងដែរថា ការចុះពិនិត្យមើលទីតាំងនេះ នឹងបង្ហាញថាសាក្សីដែលបានផ្ដល់សក្ខីកម្មអំពីការសម្លាប់ ការធ្វើទារុណកម្ម។ល។ មិនគួរឲ្យគួរជាក់បានទេ នៅពេលដែលក្រោយមកទៀត សាក្សីលើកឡើងថា ខ្លួនមិនបានឃើញការសម្លាប់ និងការធ្វើទារុណកម្មដោយផ្ទាល់ភ្នែកនោះទេ។

មេធាវីការពារក្ដី នួន ជា បានលើកឡើងបន្ថែមទៀតថា ការចុះពិនិត្យទីតាំងនឹងអាចឲ្យអង្គជំនុំជម្រះប៉ាន់ស្មានបានអំពីចំនួនមនុស្សដែលត្រូវបានសម្លាប់ ឬកប់នៅទីនោះ។ ប្រតិចារឹកសវនាការថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៥ ទំព័រ៦៧ ដល់ ៦៩។

[១៥:០៩:០៥]

ការិយាល័យសហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើសុំនេះ ដោយអះអាងថារបាយការណ៍កំណត់អត្តសញ្ញាណទីតាំងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមានភាពលម្អិត ហើយមានភ្ជាប់ដោយរូបថតថែមទៀតផង។ សហព្រះរាជអាជ្ញាបានលើកឡើងថា មិនមានតម្លៃបន្ថែមអ្វីទៀតទេក្នុងការចុះទៅពិនិត្យមើលទីតាំងឧក្រិដ្ឋកម្ម ពីព្រោះថាអ្វីៗមាននៅក្នុងរបាយការណ៍រួចហើយ ប្រតិចារឹកសវនាការថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ទំព័រ៧០។

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជំទាស់ ទៅនឹងសំណើសុំឲ្យចុះពិនិត្យទីតាំងនេះ ដោយហេតុថាសំណើនេះត្រូវបានធ្វើឡើងយឺតពេល ហើយមេធាវីការពារក្ដី នួន ជា គួរតែបានស្នើសុំចុះពិនិត្យក្នុងអំឡុងពេលស៊ើបអង្កេត មិនមែនក្នុងអំឡុងពេលសវនាការនេះទេ។ ប្រតិចារឹកសវនាការថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ទំព័រ៩១។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើដល់អង្គជំនុំជម្រះឲ្យថ្លឹងថ្លែងអំពីសារប្រយោជន៍នៃការចុះពិនិត្យទីតាំងធៀបទៅនឹងការលំបាកនានានៃការចុះពិនិត្យជាក់ស្ដែង ប្រតិចារឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ទំព័ត៧១។ វិធាន៨៧(៣)នៃវិធានផ្ទៃក្នុង អ.វ.ត.ក ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្ដុតាង

បើយល់ឃើញថាជាការស្នើសុំជាន់គ្នា ឬមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ អង្គជំនុំជម្រះកត់សម្គាល់ថា របាយការណ៍កំណត់អត្តសញ្ញាណទីតាំងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត រួមមានការពណ៌នាលម្អិតអំពីទីតាំងឧក្រិដ្ឋ ផែនទីបង្ហាញពីចម្ងាយនៅក្នុង និងជុំវិញទីតាំងឧក្រិដ្ឋនេះ។

[១៥:១១:១០]

របាយការណ៍កំណត់ទីតាំងក៏លើកឡើងថា រចនាសម្ព័ន្ធដើមដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបាត់បង់ស្ទើរតែទាំងស្រុងហើយ ហើយថាទីតាំងនោះ -- ហើយថាតាំងពីពេលនោះមកមានអគារថ្មីជាច្រើនត្រូវបានសាងសង់។ ដោយសារមេធាវីការពារក្តីមិនបានបញ្ជាក់ពីចម្ងាយនានាដែលត្រូវវាស់វែងនៅពេលចុះពិនិត្យទីតាំង ហើយដោយសារតែរបាយការណ៍កំណត់អត្តសញ្ញាណទីតាំងនេះបានបានបង្ហាញអំពីចម្ងាយសំខាន់ៗរួចហើយនោះ អង្គជំនុំជម្រះយល់ឃើញថា ការចុះពិនិត្យទីតាំងគឺមានភាពច្រំដែល។ លើសពីនេះទៀត មេធាវីការពារក្តី នួន ជា មិនបានពន្យល់ឲ្យបានគ្រប់គ្រាន់ថាតើការចុះពិនិត្យទីតាំងនឹងជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីចំនួនមនុស្សដែលត្រូវបានសម្លាប់ ឬកប់នៅទីតាំងនោះដោយរបៀបណា។ ហេតុដូច្នេះ ការចុះពិនិត្យទីតាំងនឹងមិនសមស្របសម្រាប់បញ្ជាក់នូវភស្តុតាងដែលមេធាវីការពារក្តីស្នើសុំឲ្យពិនិត្យឡើយ។

ដោយសារតែសំណើសុំមិនអនុលោមតាមវិធានអនុវត្តជាធរមាន អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើការថ្លឹងថ្លែងអំពីសារប្រយោជន៍ នៃការចុះពិនិត្យទីតាំងធៀបទៅនឹងការលំបាកនានាក្នុងការពិនិត្យនេះទេ។ អាស្រ័យហេតុនេះអង្គជំនុំជម្រះសម្រេចបដិសេធសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំឲ្យមានការចុះពិនិត្យមន្ទីរក្រាំងតាចាន់។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ។ សូមបន្តការងាររបស់ខ្លួន ក្នុងការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

[១៥:១៣:០៦]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអានបន្តនូវឯកសាររបស់ដើមបណ្តឹងមួយទៀតដែលមានឈ្មោះថា ខែម ខុន ភេទស្រី។ ឯកសារនេះមានលេខ E3/4988, ERN ជាភាសាខ្មែរ 00556131 ដល់ 32, ERN ជាភាសាអង់គ្លេស 01060616 មានតែមួយទំព័រទេភាសាអង់គ្លេស។ នៅក្នុងឯកសារ

នេះគឺគាត់បានថ្លែងថា "ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នាងខ្ញុំបានរស់នៅក្នុងភូមិត្រពាំងដងទឹក ឃុំពោបែក ស្រុកត្រាំកក់ ខេត្តតាកែវ។ រយៈពេលមួយរស់នៅជាមួយឪពុកម្ដាយ មេភូមិឈ្មោះ តាយ៉ន, មេឃុំឈ្មោះ តាចំ, ប្រធានឈ្លបឈ្មោះ មិត្ត, មេស្រុកឈ្មោះ តាចាយ, ប្រធានតំបន់ តាមុត។ ពេលនោះពួកមេភូមិប្រមូលទ្រព្យសម្បត្តិ ដូចជា គោមួយនឹម កង់មួយ មាសប្រាក់មួយចំនួន។ វាបាននិយាយថា យកទៅដាក់សម្ងហភាព។ ក្រោយមក ពួកគេបានបញ្ជូនទៅរស់នៅតាមកងកុមារចម្ការលេខ១៥០។ ប្រធានកងនារីឈ្មោះ ឡាយ នៅពេលពួកគេប្រើឱ្យធ្វើការ ធ្វើពលកម្មហួសកម្លាំង មិនថាយប់ ឬថ្ងៃ គ្មានពេលសម្រាក ហូបមិនឆ្អែត ធ្វើឱ្យរូបរាងស្គមស្គាំង ឈឺគ្មានថ្នាំព្យាបាល អ្នកឈឺប្រើពលកម្ម ហើយដកបាយ មិនឱ្យហូបបាយ ប្រមាថថាគេឈឺពុត។ ដូចជាបងប្រុសរបស់នាងខ្ញុំ ប្រធានកងយុវជនឈ្មោះ លឹម បានវាយធ្វើបាបទៅលើរូបរាងរបស់បងនាងខ្ញុំ ពីគាត់រើសក្បាលដំឡូងយកហូប។ ប្រធានកងថា ពួក១៧ឯងនេះ ស៊ីអីចឹងបានជាហើម។ ឆ្នាំ១៩៧៧ ដល់១៩៧៨ អង្គការ ពួកគេបានជម្លៀសក្រុមគ្រួសារនាងខ្ញុំរស់នៅភូមិត្រពាំងឫស្សី ឃុំត្រាំកក់ ខេត្តតាកែវ។ មេភូមិឈ្មោះ យ៉ាន មេឃុំឈ្មោះ តាជឹម មេស្រុកឈ្មោះ តាចាយ មកដល់ភូមិនេះបានពីរថ្ងៃ ពួកគេបានបញ្ជូនឱ្យទៅរស់នៅតាមកងកុមារព្រៃលើ ឃុំត្រាំកក់។ ឈ្មោះប្រធានកងឈ្មោះ នារីឯម ហើយនិងនារីទូច។ ប្រធានកងប្រើឱ្យធ្វើការជាទម្ងន់ ដូចជាជីកប្រឡាយ ប្រព័ន្ធភ្លឺស្រែ រែកដី ដីដំបូក រែកអាចម៍គោលាយអាចម៍មនុស្ស។ ប្រធានកងកុមារបានវាយកប់ដីលើរូបរាងកាយប្អូនប្រុសនាងខ្ញុំ។ អ្នកវាយឈ្មោះ ង៉ែត ជាប្រធានកងនៅក្នុងបន្ទុកគ្រួសារ បានយកទៅវាយចោលអស់ចំនួនបីនាក់ជាពូរបស់នាងខ្ញុំ បន្សល់ទុកនៅកូនកំព្រាគ្មានឪមកដល់សព្វថ្ងៃ។ ការឈឺចាប់របស់ខ្ញុំធ្វើឱ្យសុខភាពមិនសូវល្អ ព្រាត់ប្រាសគ្រួសារ ធ្វើឱ្យនាងខ្ញុំកើតទុកមិនសុខចិត្ត--" សូមទោស នេះដល់ចំណុចទាមទារសំណង ខ្ញុំបាទមិនអានតទៅទៀតទេ។ ខ្ញុំបាទសូមបញ្ចប់ត្រឹមប៉ុណ្ណេះ។ បាទ សូមអរគុណ។

សូមលោកប្រធានអនុញ្ញាតបន្តទៅសហភាតារបស់ខ្ញុំទៀតបាទ។

[១៥:១៩:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាតសូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ដូច្នេះ ខ្ញុំនឹងអានសម្រង់ពីរនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋ-

ប្បវេណី និងមួយទៀតគឺជាសម្រង់ចេញពីកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ខ្ញុំនឹងចាប់ផ្តើមដោយឯកសារ E3/6222, ERN ជាភាសាបារាំង 00861019 ទៅដល់ 1021, ជាភាសាអង់គ្លេស 0086 6048 ទៅដល់ 50, ជាភាសាខ្មែរ 00560523 ទៅដល់ 25។ ឯកសារនេះគឺជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ សុខ សង្វារ៉ាន ដែលត្រូវបានជម្លៀសទៅកាន់ភូមិតាតឹម ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំសូមអានសម្រង់ពាក់ព័ន្ធនឹងអ្វីដែលគាត់រៀបរាប់ក្រោយពីការជម្លៀសទៅកាន់ភ្នំពេញ។ រឿងរ៉ាវរបស់គាត់មានដូចតទៅ៖ "ភ្ញាក់ឡើង គេប្រមូលឲ្យទៅធ្វើពលកម្មលើកទំនប់។ ថ្ងៃត្រង់ឈប់សម្រាកមួយភ្លែត ម៉ោងពីរចាប់ធ្វើការរហូតដល់យប់។ គ្មានអនាម័យ ហេវហត់ អស់កម្លាំង ឃ្លានស្រែក ក្តៅមុខ ក្តៅហត់។ មេកងបញ្ជាឲ្យធ្វើការទាំងឈឺ។ មេកងនារី ឈ្មោះ យាយមាយ គាត់ជេរស្តីដូចខ្ញុំកំដរគេ។ នារីក្នុងកងស្ទើរទាំងអស់ត្រូវគេជេរស្តី។ ខ្វត់ចំណីអាហារណាស់ បបរមួយវែក សម្លព្រលឹត គ្មានថ្នាំពេទ្យ ពេលឈឺ ខ្មែរក្រហមប្រើថ្នាំខ្មែរ។ ពួកវាអប់រំឲ្យស្រឡាញ់អង្គការ ហើយខំធ្វើការ។ ពេលឈឺគេយកទៅកសាងឲ្យចេះអត់ធ្មត់ កុំឧស្សាហ៍ឈឺពេក។ មួយសប្តាហ៍ អង្គការហៅទៅប្រជុំរួមម្តងនៅព្រៃធាតុ ក្បែរវត្ត។ នាងខ្ញុំព្រាត់ប្រាសឪពុកម្តាយ ប្អូនប្រុស ដែលពួកវាសម្លាប់។ ពួកវាតែងតាមដាននាងខ្ញុំជារឿយៗ ព្រោះវាថានាងខ្ញុំជាមនុស្សពាក់ព័ន្ធខ្លាំង ឪពុកខ្ញុំត្រូវវាសម្លាប់នៅឆ្នាំ៧៣ នៅពេលបែកអង្គតាសោម។ ហូបតែបបរមិនឆ្អែត មិនឲ្យនិយាយស្តី មិនឲ្យស្តាប់វិទ្យុ រស់ដូចទាសករ គ្មានសិទ្ធិសេរីភាព។ វាបង្ខំឲ្យធ្វើការគ្មានពេលសម្រាក គំរាមកំហែងជាខ្លាំង រស់ដូចសត្វតិរច្ឆាន ខ្វះអនាម័យ ខ្វះទីជម្រក"។ ដើម្បីបញ្ចប់នូវការអាននៃដកស្រង់នេះ ខ្ញុំសូមបន្តទៀត "ខ្ញុំឃើញមនុស្សគេយកទៅសម្លាប់នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦, ១៩៧៧"។

[១៥:២៤:៥២]

សម្រង់ទី២ដែលខ្ញុំចង់អាននៅថ្ងៃនេះ គឺឯកសារលេខ E3/5069, ERN ជាភាសាបារាំង 0095 0316 ទៅដល់ 17, ERN ជាភាសាអង់គ្លេស 00950316 ទៅដល់ 17, ជាភាសាខ្មែរ 00567640 ទៅដល់ 43។ នេះគឺជាសម្រង់មួយចេញពីពាក្យសុំខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក មៀច ប៉ុណ្ណ (គាត់ស្លាប់ហើយឥឡូវនេះ)។ ខ្ញុំសូមអាននូវសម្រង់នេះ ដោយចាប់ផ្តើមនូវឃ្លាមួយពាក់ព័ន្ធនឹងស្រុកគិរីវង់ ដើម្បីឲ្យអង្គជំនុំជម្រះយល់ថាតើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានទៅដល់ស្រុកត្រាំកក់ដោយរបៀបណា។

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់ដូចតទៅ៖ "ខ្ញុំត្រូវជម្លៀសទៅប៉ែកខាងត្បូងនៃប្រទេស

តែចិត្តចង់ទៅរកប្រពន្ធកូន ប៉ុន្តែអ្នកប៉ានប្រឆាំងគឺត្រូវបាញ់សម្លាប់។ នេះហើយជាមូលហេតុដែលធ្វើឲ្យខ្ញុំបែកចេញពីប្រពន្ធកូន នៅខេត្តកំពង់ធំដែលខ្ញុំត្រូវទៅដល់ភូមិខ្វាវ ឃុំព្រៃអំពក ស្រុកគិរីវង់ ខេត្តតាកែវ។ ពេលខ្ញុំទៅដល់ភ្លាមគេឲ្យខ្ញុំទៅធ្វើការនៅក្នុងក្រុមទី៦ នៅភូមិខ្វាវ ធ្វើការដូចជាជីកប្រឡាយស្ទូង ដក ភ្ជួររាស់។ ខ្ញុំត្រូវធ្វើការចាប់ពីម៉ោងប្រាំព្រឹក រហូតដល់ម៉ោងដប់មួយកន្លះថ្ងៃ សម្រាកបានបបរហើយបន្តធ្វើការពីម៉ោងដប់ពីរ រហូតទៅដល់ម៉ោងប្រាំល្ងាច។ ខ្ញុំធ្វើការនេះរហូតទៅដល់ឆ្នាំ១៩៧៧ ទើបក្រោយមកមានការស៊ើបអង្កេតលើសាវតាររបស់ខ្ញុំ ដោយខ្ញុំជាសាស្ត្រាចារ្យភាសាបារាំង ប្រធានភូមិសម័យនោះឈ្មោះ ប្រាក់ នី ខ្ញុំមិនដឹងថាគេចង់យកខ្ញុំទៅសម្លាប់ទេ តែខ្ញុំឮគេបែងចែកមនុស្សជាប្រភេទផ្សេងៗ ដូចជាពួកសក្តិភូមិជាដើម។ ហើយការសម្លាប់គឺជារឿងសម្ងាត់បំផុត កាលដែលខ្ញុំរស់នៅខេត្តតាកែវ ខ្ញុំសែនទឹកកូននិងប្រពន្ធខ្លាំងណាស់ ដែលពួកគេនៅខេត្តកំពង់ធំ។ ខ្ញុំបានសុំប្រធានភូមិជាច្រើនលើក ហើយខ្ញុំដេកយំ ខ្ញុំសែនទឹកណាស់ តែគេមិនឲ្យទេ។ ខ្ញុំសូមបញ្ជាក់បន្តិច មុនពេលគេយកខ្ញុំទៅសម្លាប់ គេឲ្យខ្ញុំទៅចាំចំការនៅភូមិខ្វាវ ពេលល្ងាចគេប្រកាសថាឲ្យអ្នកនៅចាំចម្ការទៅផ្ទះក្នុងភូមិវិញ ហើយឲ្យខ្ញុំនៅចាំចម្ការតែម្នាក់ឯង ពេលនោះហើយ ទើបខ្ញុំដឹងថា ខ្ញុំនឹងត្រូវសម្លាប់នៅយប់នេះពីព្រោះខ្ញុំដឹងថាពីមុនៗមានអ្នកគេទុកឲ្យនៅចាំចម្ការត្រូវគេយកទៅសម្លាប់។ ដោយភ័យពេក ខ្ញុំត្រូវតស៊ូបន្តិចក្រែងបានរស់។ ខ្ញុំបានរៀបចំអាហារបន្តិចបន្តួច កាន់ ពូថៅ និងលីកាំបិត ចេញពីភូមិ -- ចេញពីចម្ការទៅភូមិវិញ ដើម្បីលាបងៗខ្ញុំ។ តែសំណាងល្អមានក្មួយខ្ញុំម្នាក់ជាមេក្រុមក្នុងរបបខ្មែរក្រហមឈ្មោះអ៊ុន ផន បានជួយខ្ញុំ។ ក្រោយមកប្រហែលជាចុងឆ្នាំ១៩៧៧ មានគេយកទង់ជ័យពណ៌ស មកដាក់តាមមុខភូមិ ឃើញហេតុការណ៍នេះ ពួកខ្មែរក្រហមដឹងថានឹងមានចលនារណសិរ្សតស៊ូនឹងរបប ប៉ុល ពតទើបទាហាន ប៉ុល ពត ជម្លៀសអ្នក១៧ មេសាចេញពីភូមិនោះ ក្រែងអ្នកនោះចូលដៃជាមួយរណសិរ្សរំដោះជាតិ។ ខ្ញុំក៏ជាអ្នកត្រូវគេជម្លៀសចេញដែរ គឺទៅនៅភូមិចំការអង្គ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ពេលនោះហើយដែលខ្ញុំមានជីវិតរស់នៅដល់សព្វថ្ងៃ។

ខ្ញុំសូមនិយាយពីគ្រួសារខ្ញុំម្តង ខ្ញុំដឹងរឿងរ៉ាវភាគច្រើនតាមបងថ្លៃស្រីខ្ញុំឈ្មោះ ស្នួង ហោ និងក្មួយស្រីអ៊ុល ចន្ថា ក៏ដូចជាក្មួយប្រុស អ៊ុល សំអាត។ ព្រោះពេលនោះខ្ញុំរស់នៅខេត្តតាកែវទេ។ នៅឆ្នាំ១៩៧៥ពួកខ្មែរក្រហមបានជម្លៀសប្រពន្ធកូនខ្ញុំទៅភូមិព្រៃតាត្រាវ ឃុំកំពង់ថ្ម ស្រុកបារាយណ៍ ខេត្តកំពង់ធំ”។

[១៥:៣០:២២]

ជាចុងក្រោយលោកប្រធាន ខ្ញុំសូមអានកំណត់ហេតុស្តាប់ចម្លើយ ដែលបន្តទៅនឹងដើមបណ្តឹងរដ្ឋ

ឬវេណីដែលយើងបានស្តាប់នៅក្នុងសវនាការនេះ គឺកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ សុខ ស៊ីម ដែលជាសមាជិកឃុំតាភេម ជាអ្នកទទួលខុសត្រូវចង្ក្រានបាយនៅឃុំតាស្វ ស្រុកត្រាំកក់។ ដូច្នេះ ខ្ញុំសូមអានឯកសារ E3/5519, ERN ជាភាសាបារាំង 00434593 ទៅដល់ 595, ERN ជាភាសាអង់គ្លេស 00414077 ទៅដល់ 79, ERN ជាភាសាខ្មែរ 00408334 ទៅដល់ 35។ "សំណួរ តើអ្នកណាជាអ្នកដាក់ផែនការធ្វើស្រែឲ្យបាន៣តោនក្នុង១ហិកតា? ចម្លើយ -- គឺខ្ញុំដកស្រង់នូវចម្លើយទី៣៥ នៃឯកសារ -- ចម្លើយ៖ គឺប្រធានសហករណ៍ ឈ្មោះ តាគិ។ សួរ៖ តើ តាគិ មាននីរសារដែរឬទេ? ឆ្លើយ៖ គាត់មាននីរសារ ប៉ុន្តែខ្ញុំមិនដឹងប៉ុន្មាននាក់ទេ។ នីរសាររបស់ តាគិ ជាអ្នកដើរចែកសំបុត្រ តែខ្ញុំមិនស្គាល់ឈ្មោះនីរសារទាំងនេះទេ។ សំណួរ៖ ក្នុងប្រជុំនោះ តើគេមាននិយាយអំពីការបែងចែករបបឲ្យប្រជាជនហូបចុកដែរឬទេ? ចម្លើយ៖ គេអត់មាននិយាយអំពីបញ្ហានេះទេ។ សំណួរ៖ តើអ្នកណាជាអ្នកសម្រេចបើករបបហូបចុកទៅឲ្យប្រជាជននៅតាមសហករណ៍? ចម្លើយ៖ គណៈឃុំជាអ្នកសម្រេច។ សំណួរ៖ ផែនការ៣តោនក្នុង១ហិកតានេះចេញមកពីថ្នាក់ណាដែរ? បើធ្វើមិនបានមានរឿងអ្វីកើតឡើង? ចម្លើយ៖ ចេញមកពីថ្នាក់លើ បើករណីដែលយើងធ្វើមិនបានតាមផែនការគឺមិនមានរឿងអ្វីកើតឡើងទេ គឺគ្រាន់តែយើងធ្វើមិនបានតាមផែនការ គេឲ្យយើងហូបបបរ។ អង្ករស្រូវដែលធ្វើបានត្រូវគេនាំយកចេញទៅក្រៅ អ្នកដែលដឹកអង្ករចេញគឺមកពីថ្នាក់លើ។ សំណួរ៖ តើថ្នាក់លើនិងជាថ្នាក់ណាដែរ? ចម្លើយ៖ គឺថ្នាក់ស្រុក ឬថ្នាក់ខេត្ត។ សំណួរ៖ តើប្រជាជនមានការហូបចុកគ្រប់គ្រាន់ដែរឬទេ? ចម្លើយ៖ មិនគ្រប់គ្រាន់ទេ គឺហូបតែបបរ។ សំណួរ៖ ពេលដែលអត់មានអង្ករហូបគ្រប់គ្រាន់ដូចនេះ តើប្រជាជនមានជំងឺ ឬស្លាប់ដោយសារអត់បាយដែរឬទេ? ចម្លើយ៖ មានអ្នកឈឺច្រើននិងស្លាប់ដោយសារជំងឺ។ អ្នកខ្លះដែលហូបមិនគ្រប់គ្រាន់ក៏ដើររកអ្វីផ្សេងៗទៀតដើម្បីហូប ដូចជាជីកដំឡូងអីជាដើម។ សំណួរ៖ តើលោកមានស្គាល់អ្នកណាដែលស្លាប់ដោយសារការអត់បាយដែរឬទេ? ចម្លើយ៖ បាទ ខ្ញុំស្គាល់ មានឈ្មោះ តាប៊ិន, តាម៉ាក, យាយតង។ល។ សំណួរ៖ តើលោកមានដឹងថា អ្នកដែលឈឺហ្នឹងគេយកទៅមន្ទីរពេទ្យដែរឬទេ? ចម្លើយ៖ បាទ គេយកទៅមន្ទីរពេទ្យនៅវត្តចំប៉ា។ សំណួរ៖ តើអ្នកជំងឺនៅក្នុងមន្ទីរនោះស្លាប់ច្រើនដែរឬទេ? ចម្លើយ៖ បាទ មានស្លាប់ច្រើន។ សំណួរ(ចុងក្រោយ)៖ ក្នុងចន្លោះឆ្នាំ៧៥ដល់ឆ្នាំ៧៩ តើមានថ្នាំពេទ្យគ្រប់គ្រាន់ដែរឬទេ? ក្នុងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ គេមានថ្នាំអាចម៍ទន្សាយ។ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ គេមានថ្នាំពេទ្យដែរ ប៉ុន្តែខ្ញុំមិនដឹងថាគ្រប់គ្រាន់ឬអត់ទេ ពេទ្យក៏មានដែរ ប៉ុន្តែមិនមានចំណេះដឹងអ្វីទេ"។ ខ្ញុំសូមបញ្ចប់ដោយសារការអានឯកសារដែលយើងចង់សង្កត់ធ្ងន់។ ខ្ញុំសូមបញ្ជាក់ថា ឥឡូវ

នេះយើងអស់ឯកសារហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញនូវឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងសហករណ៍ត្រាំកក់និងមន្ទីរសន្តិសុខក្រាំងតាចាន់បានចប់មុនពេលកំណត់។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៧:៣៧]

បាទ ហើយនៅសល់ពេលវេលាប្រហែលជាជាង២០មីនុតដែរ អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីលោក នួន ជា តើមានបំណងលើកឡើងបង្ហាញនូវឯកសារគន្លឹះនៅពេលនេះដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ឥឡូវនេះយើងកំពុងតែត្រៀមរៀបចំបញ្ចប់ឯកសារយើង ដូច្នេះយើងស្នើសុំបន្តទៅថ្ងៃស្អែកវិញចុះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដោយសារសវនាការនៅថ្ងៃនេះ ភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់នូវកិច្ចការរបស់ខ្លួនបានមុនពេលកំណត់។ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ សូមភាគីជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និង នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៣៩ នាទី)*